ក្រសួងអប់រំ យុវជន និងកីឡា
Ministry of Education Youth and sport

វិទ្យាស្ថានជាតិអប់រំ
National Institute of Education

# និក្ខេបបទ

# ប្រសិទ្ធភាពនៃការខារគ្រប់គ្រងសាលារៀន
# ផ្អែកលើលទ្ធផលនៅមធ្យមសិក្សា ក្នុងរាជធានីភ្នំពេញ”

# THE EFFECTIVENES OF SCHOOL BESED MANAGEMENT IN SECONDARY SCHOOL IN PHNOM PENH

ដោយ/ By

**ញ៉ែម ពៅ/NHEM POUV**

**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧**
**ឯកទេស៖ គ្រប់គ្រងអប់រំ**

**ឆ្នាំសិក្សា ២០១៩-២០២០**

ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education Youth and sport


វិទ្យាស្ថានជាតិអប់រំ

National Institute of Education


# និក្ខេបបទ

# ប្រសិទ្ធភាពនៃការងារគ្រប់គ្រងសាលារៀន ផ្អែកលើលទ្ធផលនៅមធ្យមសិក្សា ក្នុងរាជធានីភ្នំពេញ

# THE EFFECTIVENES OF SCHOOL BESED MANAGEMENT IN SECONDARY SCHOOL IN PHNOM PENH


ដោយ/ By

**ញ៉ែម ពៅ/NHEM POUV**


**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧**

**ឯកទេស៖ គ្រប់គ្រងអប់រំ**

**ឆ្នាំសិក្សា ២០១៨-២០២០**


គ្រូដឹកនាំបង្គោល ៖ ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា

គ្រូដឹកនាំរង ៖ លោក ម៉ៅ សារឿន

# **សេចក្ដីប្រកាសអះអាងរបស់បេក្ខជន**

ខ្ញុំបាទឈ្មោះ **ញៀម ពៅ** សូមបញ្ជាក់ថា និក្ខេបបទស្រាវជ្រាវដែលមានចំណងជើង " **ប្រសិទ្ធភាពនៃការគ្រប់គ្រងសាលារៀន ផ្ដោតលើលទ្ធផលនៅមធ្យមសិក្សា ក្នុងរាជធានីភ្នំពេញ** " សម្រាប់បំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ គឺជាស្នាដៃរបស់ខ្ញុំបាទទាំងស្រុង។ ស្នាដៃនេះមិនដែលត្រូវបានគេយកមកប្រើប្រាស់ ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់ទទួលសញ្ញាបត្រនៅវិទ្យាស្ថាននេះ ឬនៅសាកលវិទ្យាល័យណាមួយឡើយ។ លើសពីនេះទៅទៀត ក៏ពុំមានសេចក្ដីដកស្រង់ ឬខ្លឹមសារណាមួយត្រូវបានយកមកប្រើប្រាស់ក្នុងការស្រាវជ្រាវនេះ ដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះបញ្ជីឯកសារយោងឡើយ។ និក្ខេបបទស្រាវជ្រាវខាងលើនេះ ពិតជាស្រាវជ្រាវដោយខ្ញុំបាទផ្ទាល់ប្រាកដមែន។

ថ្ងៃ......................ខែ.........ឆ្នាំ ...........ស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញថ្ងៃទី...........ខែ..............ឆ្នាំ២០

ហត្ថលេខាបេក្ខជន

**ញៀម ពៅ**

# លិខិតបញ្ជាក់

**ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា** គ្រូដឹកនាំបង្គោល

**លោក ម៉ៅ សារឿន** គ្រូដឹកនាំរង

សូមបញ្ជាក់ និងទទួលស្គាល់ថា

លោក **ញ៉ែម ពៅ** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ "**ប្រសិទ្ធភាពនៃការគ្រប់គ្រងសាលារៀន ផ្អែកលើលទ្ធផលនៅមធ្យមសិក្សា ក្នុងរាជធានីភ្នំពេញ**" ប្រាកដមែន។

ថ្ងៃ.....................ខែ.................ឆ្នាំ ............ស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃ ទី ខែ ឆ្នាំ២០២០

............................................. ...........................................

**ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា** — នាយកវិទ្យាស្ថានជាតិអប់រំ

**លោក ម៉ៅ សារឿន** — ប្រធានដេប៉ាតឺម៉ង់អប់រំ

# លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខ:** ៥៧៣៤៧ **អយក.ឧទន**

(**ការសម្ងាត់**)

**លិខិតឧទ្ទេសនាម**

យោង ៖ -លិខិតលេខ២៩៥៥ អយក.វជអ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០។

-បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ និងទី៨ ឆ្នាំសិក្សា២០១៩-២០២០ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារសារណា** ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី២៤-២៥ ខែតុលា ឆ្នាំ២០២០ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-ឯ.ឧបណ្ឌិត | សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២-ឯកឧត្តមបណ្ឌិត | ម៉ុក សារ៉ុម | អគ្គ.អប់រំ | អនុប្រធាន |
| ៣- ឯកឧត្តម | នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៤-លោក | ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-លោកបណ្ឌិត | នូវ វីរ៉ា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦-លោកស្រី | ប៊ុន សុផានី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៧-លោក | ថៃ ហេង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-លោកបណ្ឌិត | នី រដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៩-លោក | ម៉ន មុនិទ្ធ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១០-លោក | ចាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១១-លោកបណ្ឌិត | ឈាង សង្ហាត | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១២-លោកបណ្ឌិត | អាន វ៉ូប្រាវ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោកស្រី | នូ ចន្ទី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤-លោក | សៀង វាសនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារសារណា របស់និស្សិតពីថ្ងៃទី២៤-២៥ ខែតុលា ឆ្នាំ២០២០ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ ចន្ទ ៣ កើត ខែ កត្តិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ២០២០

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

-អគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
"ដើម្បីជ្រាបជាព័ត៌មាន"

-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ
"ដើម្បីជ្រាបជាព័ត៌មាន"

-សាមីខ្លួន "ដើម្បីអនុវត្ត"

-កាលប្បវត្តិ -ឯកសារ វជអ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

# សេចក្តីថ្លែងអំណរគុណ

ជាបឋមខ្ញុំបាទឈ្មោះ **ញ៉ៀម ពៅ** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ នៃវិទ្យាស្ថានជាតិអប់រំជំនាន់ទី៧ ឯកទេសគ្រប់គ្រងអប់រំ។

*សូមថ្លែងអំណរគុណជាអនេកប្បការជូនចំពោះ៖*

-លោកឪពុក **ញ៉ៀម ឡេង** និងអ្នកម្តាយ **យ៉េម ដា** ដែលបានផ្តល់កំណើតចិញ្ចឹមបីបាច់រូបខ្ញុំ ព្រមទាំងបានផ្តល់នូវជំបូន្មានល្អៗ និងបានបញ្ជូនខ្ញុំឱ្យចូលរៀនតាំងពីថ្នាក់បឋមសិក្សា រហូតដល់ថ្នាក់ឧត្តមសិក្សា ដោយមិនគិតពីការនឿយហត់ និងតស៊ូគ្រប់ឧបសគ្គដើម្បីកូនទទួលបាននូវអនាគតរុងរឿង។

-ថ្លែងអំណរគុណចំពោះឯកឧត្តមថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា ដែលបានរៀបចំបង្កើតឱ្យមានថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំសម្រាប់បុគ្គលិកអប់រំនេះឡើង ក្នុងន័យសម្រាប់យកទៅបម្រើការងារឱ្យវិស័យអប់រំប្រកបដោយប្រសិទ្ធភាព និងគុណភាព។

-ថ្លែងអំណរគុណចំពោះឯកឧត្តមបណ្ឌិត **សៀង សុវណ្ណារា** នាយកវិទ្យាស្ថានជាតិអប់រំ ជា គ្រូដឹកនាំបង្គោល ដែលជានិច្ចកាល ឯកឧត្តមបណ្ឌិត តែងតែឆ្លៀតពេលដ៏មានតម្លៃរបស់លោក ក្នុងការ ផ្តល់គំនិតណែនាំ និងផ្តល់ទាំងកម្លាំងចិត្ត កម្លាំងកាយ បញ្ញាស្មារតី សម្ភារៈ បច្ចេកទេស វិធីសាស្រ្តផ្សេងៗ មិនតែប៉ុណ្ណោះ លោកបានជួយផ្តល់ជាឯកសារផ្សេងៗទាក់ទងនឹងប្រធានបទព្រមទាំងជួយបង្ហាញទិសដៅនៃការស្រាវជ្រាវប្រកបដោយគតិបណ្ឌិតដល់រូបខ្ញុំ រហូតដល់ការសិក្សាស្រាវជ្រាវនេះទទួលបានជោគជ័យជាស្ថាពរ។

-ថ្លែងអំណរគុណចំពោះលោក **ម៉ៅ សារឿន** ជាគ្រូដឹកនាំរង ដែលលោកតែងតែឆ្លៀតពេលដ៏មានតម្លៃ ក្នុងការផ្តល់គំនិត ណែនាំ និងផ្តល់វិធីសាស្រ្តផ្សេងៗ មិនតែប៉ុណ្ណោះលោកបានជួយប្រាប់ពីប្រភពដើម្បីស្វែងរកឯកសារផ្សេងៗ ដែលទាក់ទងនឹងប្រធានបទ ព្រមទាំងជួយបង្ហាញទិសដៅនៃការស្រាវជ្រាវ ប្រកបដោយគតិបណ្ឌិតដល់រូបខ្ញុំ រហូតដល់ការសិក្សាស្រាវជ្រាវនេះទទួលបានជោគជ័យជាស្ថាពរ។

-ថ្លែងអំណរគុណចំពោះឯកឧត្តម លោក លោកស្រី ជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់ នៃវិទ្យាស្ថានជាតិអប់រំ ដែលបានផ្តល់ទីតាំង និងសម្របសម្រួលដល់ដំណើរការនៃការបណ្តុះបណ្តាលក្នុងវគ្គនេះប្រកបដោយជោគជ័យគួរជាទីមោទនៈ។

-ថ្លែងអំណរគុណចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ ដែលបានផ្តល់ព័ត៌មានយ៉ាងលម្អិត និងគ្រប់ជ្រុងជ្រោយចំពោះការសម្ភាសយកព័ត៌មានមកសរសេរក្នុងនិក្ខេបបទនេះ រហូតបានបញ្ចប់ជាស្ថាពរ។

-ថ្លែងអំណរគុណចំពោះ លោក លោកស្រី សាស្ត្រាចារ្យជាតិ អន្តរជាតិទាំងអស់ ដែលបានខិតខំអស់ពីកម្លាំងកាយចិត្ត សម្ភារៈ ក្នុងការផ្តល់ពុទ្ធិ ចំណេះធ្វើ ឥរិយាបថ ពិសេសផ្តល់ជាទ្រឹស្តី និងបទពិសោធន៍ល្អៗដែលទាំងនេះជាចំណេះដឹងមួយដ៏សំខាន់ និងចាំបាច់បំផុតសម្រាប់អនុវត្ត ព្រមទាំងឆ្លុះបញ្ចាំងពីការអនុវត្តការងារបច្ចុប្បន្ន។

ជាទីបញ្ចប់ ខ្ញុំបាទសូមគោរពជូនពរ និងប្រសិទ្ធពរ លោកអ្នកមានគុណទាំងពីរ ឯកឧត្តមលោកជំទាវ លោក លោកស្រី ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា ឯកឧត្តមបណ្ឌិតសាស្ត្រាចារ្យជាតិ និងអន្តរជាតិទាំងអស់នៃវិទ្យាស្ថានជាតិអប់រំ សូមឱ្យជួបប្រទះតែសេចក្តីសុខគ្រប់ប្រការ មានសុខភាពល្អសម្រេចជោគជ័យគ្រប់ភារកិច្ច និងទទួលបាននូវពុទ្ធពរទាំង៤ ប្រការគឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូមអរគុណ !

# មូលន័យសង្ខេប

ប្រទេសជាច្រើននៅក្នុងពិភពលោក ក្នុងនេះក៏មានប្រទេសកម្ពុជាផងដែរ បាននឹងកំពុងតែអនុវត្ត ការគ្រប់គ្រងតាមសាលារៀនតាមរយៈការធ្វើវិមជ្ឈការនៃការអប់រំ។ ដោយយល់ឃើញថា ការគ្រប់គ្រងតាមសាលារៀនមានសារៈសំខាន់បែបនេះហើយ ទើបអ្នកសិក្សាស្រាវជ្រាវបានជ្រើសរើសប្រធានបទ "ប្រសិទ្ធភាពនៃការគ្រប់គ្រងសាលារៀន ផ្អែកលើលទ្ធផលនៅមធ្យមសិក្សាក្នុងរាជធានីភ្នំពេញ" មកសិក្សាស្រាវជ្រាវ ។ ការសិក្សាស្រាវជ្រាវនេះមានគោលបំណង៖ (១) ស្វែងយល់ពីស្ថានភាពនៃការគ្រប់គ្រងស្ថានភាពបច្ចុប្បន្ននៃដំណើរការគ្រប់គ្រងសាលារៀនមធ្យមសិក្សា ក្រៅពីសាលាជំនាន់ថ្មី សាលាធនធាន និងសាលាគម្រោងSIEP ពិសេសលើការអនុវត្តស្តង់ដាសាលាមធ្យមសិក្សាចំណោះទូទៅទាំង៩ និង (២) រកឱ្យឃើញបញ្ហាប្រឈមនានា ក្នុងដំណើរការគ្រប់គ្រងសាលារៀនប្រកបដោយគុណភាព ផ្អែកលើលទ្ធផល នៃការដឹកនាំ និងគ្រប់គ្រងរបស់នាយកសាលា ការរៀននិងបង្រៀន លទ្ធផលសិក្សារបស់សិស្ស និងការចូលរួមរបស់សហគមន៍មាតាបិតាអាណាព្យាបាល និងអាជ្ញាធរ។ ការសិក្សាស្រាវជ្រាវនេះ បានធ្វើឡើងក្នុងសាលារៀនចំនួន១២ មានអនុវិទ្យាល័យ៦ និងវិទ្យាល័យ៦ ស្ថិតក្នុងរាជធានីភ្នំពេញ។ ភាគសំណាកក្នុងការស្រាវជ្រាវនេះ មាននាយកសាលា១២នាក់ គ្រូ១១៩នាក់ សិស្សានុសិស្ស១៧១នាក់ គណៈកម្មការគ្រប់គ្រងសាលារៀន សហគមន៍មាតាបិតាសិស្ស១៨នាក់។ វិធីសាស្ត្រប្រមូលទិន្នន័យគឺបានមកពីកម្រងសំណួរបំពេញនិងកម្រងសំណួរសម្ភាសន៍សម្រាប់នាយកសាលា គ្រូ សិស្ស គណៈកម្មការទ្រទ្រង់សាលា ឬសហគមន៍។ ទិន្នន័យដែលប្រមូលបាន អ្នកស្រាវជ្រាវបានយកទៅវិភាគតាមមធ្យមភាគ បណ្តុំគំនិត និងការបង្ហាញជាតារាង ។

លទ្ធផលនៃការស្រាវជ្រាវនេះបានបង្ហាញថា៖ ការអនុវត្តការគ្រប់គ្រងតាមសាលារៀននៅកម្រិតមធ្យមសិក្សា ក្នុងរាជធានីភ្នំពេញ មិនទាន់បានបំពេញនូវស្តង់ដាសាលាមានប្រសិទ្ធភាពទាំង៩នោះទេ។ ចំពោះបញ្ហាប្រឈម នៃការអនុវត្តការគ្រប់គ្រងតាមសាលារៀន ជារួមមានខ្វះគ្រូឯកទេសផ្នែកព័ត៌មានវិទ្យា លើសគ្រូ និងខ្វះគ្រូឯកទេស ខ្វះកុំព្យូទ័រ គ្រូមិនបានប្រើប្រាស់សម្ភារពិសោធន៍ និងកិច្ចតែងការក្នុងម៉ោងបង្រៀន ដំណើរការក្លឹបសិក្សាលើដំណើរការ សេវាសិស្សជួយសិស្សនៅមានកម្រិតទាប ខ្វះបន្ទប់ពិសោធន៍

បណ្ណាល័យមានដែរតែនៅមិនទាន់មានកម្រិតស្តង់ដា ខ្វះការចូលរួមនិងតាមដានជាប្រចាំចំពោះសិស្សរៀនយឺត ដែលធ្វើឱ្យមានអត្រាបោះបង់ សមត្ថភាពនាយកសាលាក្នុងការធ្វើផែនការអភិវឌ្ឍន៍សាលាផ្អែកលើស្តង់ដាទាំង៩ មិនទាន់បានល្អនៅឡើយ។

ដើម្បីឆ្លើយតបនឹងបញ្ហាប្រឈមខាងលើ ការស្រាវជ្រាវនេះសូមសំណូមពរមួយចំនួនៈ(១) ក្រសួងអប់រំ យុវជន និងកីឡាបើកវគ្គបំប៉ន និងបណ្តុះបណ្តាលបន្ថែម លើសមត្ថភាពពីវិធីសាស្ត្រក្នុងការធ្វើឱ្យសម្រេចបាននូវសូចនាករទាំងអស់ក្នុងស្តង់ដាទាំង៩ (២) ក្រសួងសហការជាមួយមន្ទីរអប់រំ យុវជន និងកីឡាដើម្បីផ្សព្វផ្សាយនិងណែនាំពីសារៈសំខាន់ នៃការគ្រប់គ្រងតាមសាលារៀនដល់នាយកសាលា គ្រូ សិស្ស សហគមន៍ អាណាព្យាបាលសិស្ស ដើម្បីឱ្យពួកគាត់ទាំងអស់ ជំរុញលទ្ធផលនៃការសិក្សាឱ្យកាន់តែប្រសើរឡើង (៣) សាលារៀន ត្រូវខិតខំលើកទឹកចិត្ត ដល់ភាគីពាក់ព័ន្ធ ជាពិសេសគណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូ ឱ្យខិតខំបំពេញភារកិច្ច ប្រកបដោយប្រសិទ្ធភាព និងគុណភាព ឆ្លើយតបទៅនឹងគោលនយោបាយអប់រំ និងតម្រូវការមូលដ្ឋាន។

# Abstract

Cambodia, as well as many countries around the world have been implementing the School-based management throung the Decentralization and Deconcentration of Education. Knowing the importance of such school-based management, the researcher chooses the topic "The Effectivenes of School based management in Secondary School in Phnom Penh". This research aims to ( 1 ) Study the situation of implementation of school based management at secondary School and implementation of the effective school standards beside the New Generation School, Resources Schools and SIEP Schools ( 2 ) Identify the challeges of implementing Effective School management based on the Result of Mangement and leading of school Principals, Teaching and Learning, Student achievements and the participation of parent and communities. This research was conducted at twelve schools ( six lower secondary Schools and six high schools ) in Phnom Penh by providing the questionaires to 12 principals, 119 teachers, 171 students and 18 community management committtees as well as interviews. The researcher analyzed data collected by Average and ideas-collected by presenting with tables.

The study found that the implementation of effective school management in secondary schools in Phnom Penh was not all effective. The facing problems are lack of ICT teachers, computers, students'dropout, teaching without using materials, using lesson plans, study clubs not working for students helping students, lack of laboratory, standard library, lack of encouraging from parents and principals are not good at Eduction Stratgic planning for School Development based on 9 elements of effective School Standards.

In response to the challenges above, the study made the following recommendations: (1) The Ministry of Education Youth and Sport should provide more training for principals to be able to make a good plan for school development to apply indicators in 9 effective school standards and training for teachers to make a good lesson study and lesson plan (2) Ministry of Education Youth and sport should cooperate with Department of Education Youth and sport in conduting the orientation of important of School based management to principals, teachers, students, parents and communities in order to improve students learning outcomes. (3). School must motivate for all relatationship and partnership to workhard and worksmart to implement with effectiveness and quality to repond to Education Policy and communities´needs.

## មាតិកា


សេចក្តីប្រកាសអះអាងរបស់បេក្ខជន ..... i

លិខិតបញ្ជាក់ ..... ii

លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ ..... iii

សេចក្តីថ្លែងអំណរគុណ ..... iv

មូលន័យសង្ខេប ..... vi

Abstract ..... viii

មាតិកា ..... x

ជំពូកទី១ ..... 1

សេចក្តីផ្តើម ..... 1

១.១ សាវតារនៃការស្រាវជ្រាវ ..... 2

១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ..... 5

១.៥ សារៈសំខាន់នៃការស្រាវជ្រាវ ..... 7

១.៦ ដែនកំណត់នៃការស្រាវជ្រាវ ..... 8

ជំពូកទី២ ..... 12

រំលឹកទ្រឹស្តី ..... 12

២.១.១ ការដឹកនាំ និងគ្រប់គ្រងរបស់នាយកសាលា ..... 14

២.១.២ ការគ្រប់គ្រងការរៀន និងបង្រៀន ..... 20

២.១.៣ លទ្ធផលសិក្សារបស់សិស្ស ..... 21

២.១.៤ ការចូលរួមរបស់សហគមន៍ មាតាបិតាសិស្ស និងអាជ្ញាធរមូលដ្ឋាន ..... 21

២.២ ស្តង់ដានាយកសាលាមធ្យមសិក្សា ..... 22

ស្តង់ដាទី១៖ កម្រិតវប្បធម៌ និងបទពិសោធការងារ ..... 23

ស្តង់ដាទី២៖ សមត្ថភាព និងគុណសម្បត្តិរបស់នាយកសាលារៀន ..... 23

ស្តង់ដាទី៣៖ បំណិនត្រិះរិះពិចារណា និងនវានុវត្តន៍ ..... 23

ស្តង់ដាទី៤៖ ភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរដ្ឋបាលសាលារៀន ...... 24
ស្តង់ដាទី៥៖ ភាពជាអ្នកដឹកនាំលើកម្មវិធីសិក្សា ការបង្រៀន និងរៀន ...... 25
ស្តង់ដាទី៦៖ ការផ្សារភ្ជាប់សាលារៀន ទៅនឹងសហគមន៍ ...... 26
**២.៣ ប្រសិទ្ធភាពនៃស្តង់ដាសាលាមធ្យមសិក្សា** ...... 26
**២.៣.១ វត្ថុបំណងគោលនយោបាយសាលារៀន** ...... 27
**២.៣.២ ការបង្រៀន និងបំណែងចែកកម្មវិធីសិក្សា** ...... 27
**២.៣.៣ មាតាបិតា និងសហគមន៍ជួយដល់ការរៀនសូត្រ** ...... 28
**២.៣.៤ សិស្ស និងសេវាជួយសិស្ស** ...... 29
**២.៣.៥ ការដឹកនាំ និងគ្រប់គ្រង** ...... 30
**២.៣.៦ ធនធានមនុស្ស** ...... 31
**២.៣.៧ សៀវភៅសិក្សាគោល និងសម្ភារបង្រៀន និងរៀន** ...... 31
**២.៣.៨ ហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានសាលារៀន** ...... 33
**២.៣.៩ ហិរញ្ញប្បទាន និងការគ្រប់គ្រងហិរញ្ញវត្ថុ** ...... 33
**២.៤. បទពិសោធនៃការគ្រប់គ្រងផ្អែកលើលទ្ធផល និងការចូលរួម នៅប្រទេសនានា** ...... 34
**២.៥ កត្តាចាំបាច់សម្រាប់អនុវត្តការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផលនៅកម្ពុជា** ...... 36
**ជំពូកទី៣** ...... 39
**វិធីសាស្ត្រស្រាវជ្រាវ** ...... 39
**៣.១ ព័ត៌មានទូទៅនៃគម្រោងស្រាវជ្រាវ** ...... 39
**៣.២ ទីកន្លែងសិក្សាស្រាវជ្រាវ** ...... 39
**៣.៣ ការជ្រើសរើសសំណាក** ...... 40
**៣.៤ ឧបករណ៍នៃការស្រាវជ្រាវ** ...... 41
**៣.៥ កម្រងសំណួរ និងគោលបំណងនៃកម្រងសំណួរ** ...... 41
៣.៥.២ កម្រងសំណួរសម្រាប់គ្រូ ...... 42
៣.៥.៣ កម្រងសំណួរសម្រាប់សិស្សានុសិស្ស ...... 42
៣.៥.៣ កម្រងសំណួរសម្រាប់គណៈកម្មការគ្រប់គ្រង/ទ្រទ្រង់សាលា ...... 43
**៣.៦ ដំណាក់កាលនៃការប្រមូលទិន្នន័យ** ...... 43

៣.៧ ការវិភាគទិន្នន័យ ........ 44
៣.៨ ក្រមសីលធម៌នៃការស្រាវជ្រាវ ........ 44
ជំពូកទី៤ ........ 47
លទ្ធផលនៃការស្រាវជ្រាវ និងការពិភាក្សា ........ 47
៤.១ លទ្ធផលនៃការស្រាវជ្រាវ ........ 47
៤.១.១ អ្នកចូលរួមក្នុងការផ្តល់ព័ត៌មានក្នុងការស្រាវជ្រាវ ........ 47
៤.១.២ ប្រសិទ្ធភាពនៃការអនុវត្តការគ្រប់គ្រងតាមសាលា ផ្អែកតាមស្តង់ដាទាំង៩ ........ 50
៤.២ លទ្ធផលនៃការអនុវត្តស្តង់ដាទាំង៩តាមសាលារៀននីមួយៗ ........ 63
៤.៣ បញ្ហាប្រឈមនៃការអនុវត្តស្តង់ដាទាំង៩គិតជារួម ........ 64
ជំពូកទី៥ ........ 67
សេចក្តីសន្និដ្ឋាន និងសំណូមពរ ........ 67
៥.១ សេចក្តីសន្និដ្ឋាន ........ 67
៥.២ សំណូមពរ ........ 71
ឯកសារយោង ........ 74
ឧបសម្ព័ន្ធ ........ 76

# បញ្ជីតារាង


– តារាងទី១៖ ចំនួនអ្នកចូលរួមផ្តល់ព័ត៌មានសម្រាប់ការស្រាវជ្រាវ.........................................47

– តារាងទី២ កម្រិតវប្បធម៌អ្នកចូលរួមឆ្លើយកម្រងសំណួរ.....................................................48

– តារាងទី៣ កម្រិតវិជ្ជាជីវៈនាយក គ្រូបង្រៀន.......................................................................48

– តារាងទី៤ អតីតភាពការងារមុខតំណែងរបស់នាយកសាលា និងគ្រូបង្រៀន........................49

– តារាងទី៥ ចំនួនសិស្សតាមកម្រិតថ្នាក់ ..............................................................................50

– តារាងទី៦៖ វត្ថុបំណងគោលនយោបាយសាលារៀន ..........................................................50

– តារាងទី៧ ការបង្រៀន និងរៀន..........................................................................................52

– តារាងទី៨ មាតាបិតា និងសហគមន៍ជួយដល់ការរៀនសូត្រសិស្ស .......................................56

– តារាងទី៩ សិស្សនិងសេវាជួយសិស្ស ..................................................................................57

– តារាងទី១០ ការដឹកនាំ និងការគ្រប់គ្រងសាលារៀន..........................................................58

– តារាងទី១១៖ ធនធានមនុស្ស ...............................................................................................60

– តារាងទី១២៖ សៀវភៅសិក្សាគោល និងសម្ភាររៀន និងបង្រៀន..........................................61

– តារាងទី១៣៖ ហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានសាលារៀន.................................................62

– តារាងទី១៤៖ ហិញ្ញប្បទាន និងការគ្រប់គ្រងហិរញ្ញវត្ថុ .......................................................63

– តារាងទី១៥៖លទ្ធផលនៃការស្រាវជ្រាវលើការអនុវត្តស្តង់ដាទាំង៩ តាមសាលារៀននីមួយៗ....63

# ជំពូកទី ១
# សេចក្តីផ្តើម

# ជំពូកទី១

# សេចក្តីផ្តើម

វិស័យអប់រំ ជាឆ្អឹងខ្នងនៃការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ដោយសារប្រទេសកម្ពុជាជាប្រទេសមួយដែលបានឆ្លងកាត់សង្គ្រាមជាច្រើនទៅតាមសម័យកាលជាអាទិ៍ ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ (ខ្មែរក្រហម) បានបំផ្លិចបំផ្លាញ ស្ទើរទាំងស្រុង រួមមានវប្បធម៌ ប្រពៃណីទំនៀមទំលាប់ខ្មែរ ហេដ្ឋារចនាសម្ព័ន្ធ មន្ទីរពេទ្យ វត្តអារាម សាលារៀន បង្ខំមនុស្សឱ្យធ្វើការជាទម្ងន់ បង្អត់អាហារ កាប់សម្លាប់មនុស្សជាច្រើនយ៉ាងសាហាវយោរឃៅ ដែលក្នុងនោះក៏មានគ្រូបង្រៀនមួយចំនួនធំផងដែរ (Dykstra,A.H,& Kucita.P, 1997)។ ចាប់ពីថ្ងៃរំដោះ៧មករា១៩៧៩ និងកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស១៩៩១ ការអប់រំត្រូវបានគេចាត់ទុកជាវិស័យដ៏សំខាន់បំផុត ក្នុងការស្តារនិងអភិវឌ្ឍប្រទេសជាតិ ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានសម្តេចអគ្គមហាសេនាបតីតេជោហ៊ុនសែនជាប្រមុខ ទើបកម្ពុជា មានការរីកចម្រើន និងអភិវឌ្ឍន៍លើគ្រប់វិស័យ ។ យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ បាននិងកំពុងផ្តោតការយកចិត្តទុកដាក់ជាចម្បងលើការអភិវឌ្ឍធនធានមនុស្ស។ ដើម្បីគាំទ្រនិងចូលរួមអនុវត្តយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជាដំណាក់កាលទី៤នេះ ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតនូវផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ ដោយផ្តល់អាទិភាពទៅលើ (១) ការយកចិត្តទុកដាក់លើគ្រូបង្រៀន (២) ការពង្រីកវិសាលភាពសាលារៀនគ្រប់កម្រិត (៣) ការពង្រឹងអធិការកិច្ចគ្រប់ជ្រុងជ្រោយលើការគ្រប់គ្រងសាលារៀន (៤) ការជំរុញការអបរំ បច្ចេកទេសនៅមធ្យមសិក្សាទុតិយភូមិ (៥) ការអប់រំបំណិនឱ្យស្របតាមទីផ្សារការងារ (៦) ការអភិវឌ្ឍកម្មវិធីសិក្សា និងសៀវភៅសិក្សាគោលគ្រប់ជ្រុងជ្រោយ និង (៧) ការត្រៀមប្រកួតស៊ីហ្គេមឆ្នាំ២០២៣ និងបានកំណត់គោលនយោបាយចំនួន២ គឺ (១) ធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាប័ន្ន និងលើកកម្ពស់ឱកាសសម្រាប់ការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា (២) ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំនិងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ និងបានដាក់ចេញនូវយុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំចំនួន៤ ក្នុងនោះមានយុទ្ធសាស្ត្រកំណែទម្រង់ការគ្រប់គ្រងអប់រំផងដែរ(យុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ,២០១៩-២០២០)។

ក្រសួងអប់រំ យុវជន និងកីឡា បាននិងកំពុងព្យាយាមអស់រយៈពេលជាច្រើនឆ្នាំ ក្នុងគោលបំណងដើម្បីឱ្យការអប់រំនៅកម្ពុជាមានគុណភាព។ គុណភាពអប់រំគឺអាស្រ័យលើគុណភាពនាយកសាលារៀន និងគុណភាពគ្រូបង្រៀន។ នាយកសាលារៀន ត្រូវបានគេចាត់ទុកថាជាអ្នកមានសក្តានុពល ក្នុងការបង្កើនគុណភាពអប់រំ និងជាអ្នកកំណត់នូវចក្ខុវិស័យ និងបេសកកម្មរបស់សាលារៀន។ នាយកសាលារៀនត្រូវមានកិច្ចសហការជិតស្និទ្ធជាមួយមាតាបិតា អ្នកអាណាព្យាបាលសិស្ស សហគមន៍ និងស្ថាប័នពាក់ព័ន្ធដទៃទៀតក្នុងការជួយដល់ការសិក្សារបស់សិស្សទទួលបានលទ្ធផលល្អប្រសើរ ឆ្លើយតបទៅនឹងតម្រូវការរបស់សិស្ស គ្រួសារ និងសហគមន៍។ ក្នុងន័យនេះ ដើម្បីសម្រេចបាននូវគុណភាពអប់រំ ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានបំណងរួមគ្នា គឺធ្វើឱ្យសាលារៀនក្លាយជាកន្លែងផ្តល់សេវាអប់រំប្រកបដោយគុណភាព បរិយាបន្ន ប្រសិទ្ធភាព និងលើកកម្ពស់ការអប់រំពេញមួយជីវិត សម្រាប់ទាំងអស់គ្នា តាមរយៈការអនុវត្តការគ្រប់គ្រងសាលារៀនប្រកបដោយប្រសិទ្ធភាពផ្អែកលើលទ្ធផល ឬការគ្រប់គ្រងតាមសាលារៀន (ក្រសួងអប់រំយុវជននិងកីឡា, សៀវភៅប្រតិបត្តិស្តីពីការគ្រប់គ្រងតាមសាលារៀន, ២០១៨) ។ ការដាក់ឱ្យអនុវត្តការគ្រប់គ្រងសាលារៀនប្រកបដោយប្រសិទ្ធភាព តាមរយៈគោលនយោបាយវិមជ្ឈការនៅក្នុងការអប់រំ។ក្រសួងបានផ្តល់នូវប្រតិភូកម្មអំណាចនិងការទទួលខុសត្រូវកាន់តែច្រើនឡើង ដល់ថ្នាក់រាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងសាលារៀនផងដែរ ដើម្បីឆ្ពោះទៅរកការគ្រប់គ្រងតាមសាលារៀនប្រកបដោយប្រសិទ្ធភាព ឱ្យស្របទៅនឹងគោលនយោបាយ និងយុទ្ធសាស្ត្រវិស័យអប់រំ (ក្រសួងអប់រំយុវជននិងកីឡា, គោលនយោបាយនិងផែនការយុទ្ធសាស្ត្រវិស័យអប់រំ, ២០០៥)។

## ១.១ សាវតារនៃការស្រាវជ្រាវ

ដោយសារតែការរីកចម្រើនផ្នែកបច្ចេកវិទ្យាព័ត៌មាន វិទ្យាសាស្ត្រ សេដ្ឋកិច្ច និងនយោបាយទាមទារឱ្យសាលារៀនក៏ត្រូវតែមានគណនេយ្យភាព និងប្រសិទ្ធភាពផងដែរ។ ប្រទេសកម្ពុជាត្រូវបានធ្វើកំណែទម្រង់វិស័យអប់រំជាច្រើនដំណាក់កាល ដោយមានការជួយគាំទ្រទាំងបច្ចេកទេស និងហិរញ្ញវត្ថុ ពីបណ្តាដៃគូនានា ដូចជាធនាគារពិភពលោកលើគម្រោងកែលម្អគុណភាពអប់រំ (EQIP) ចាប់តាំងពីឆ្នាំ១៩៩៨ ធនាគារអភិវឌ្ឍន៍អាស៊ីលើការពង្រឹងគុណភាពអប់រំនៅមធ្យមសិក្សា ប្រទេសស៊ុយអែតលើគម្រោងមូល

និធិកែលម្អសាលារៀន (SIG) និងប្រទេសជប៉ុនលើការអភិវឌ្ឍគុណវុឌ្ឍិគ្រូបង្រៀនជាដើម។ ទាំងអស់នោះ គឺក្នុងគោលបំណង ដើម្បីជំរុញឱ្យមូលដ្ឋានលើកកម្ពស់គុណភាពអប់រំ ដោយមានការសម្រេចចិត្តចូលរួមពីសហគមន៍ និងដៃគូ ក្នុងការចូលរួមចំណែកធ្វើឱ្យប្រសើរឡើង នូវការបែងចែកធនធានដែលមានកម្រិត សម្រាប់ចូលរួមកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា កាត់បន្ថយការបោះបង់ការសិក្សា និងជំរុញឱ្យប្រជាពលរដ្ឋត្រូវតែទទួលការអប់រំជាមូលដ្ឋានយ៉ាងតិច៩ឆ្នាំ។ ការចូលរួមយ៉ាងសំខាន់នេះក៏ជាការឆ្លើយតប ក្នុងការសម្រេចគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ និងគោលដៅអប់រំទាំងអស់គ្នាផងដែរ (Shoraku, 2008)។ ដើម្បីសម្រេចបាននូវគោលនយោបាយអប់រំ ក្រសួងបានដាក់ឱ្យអនុវត្តការគ្រប់គ្រងតាមសាលារៀន។ ការដាក់ឱ្យអនុវត្តបែបនេះមានគោលបំណង២គឺ (១) រៀបចំសាលារៀនឱ្យបំពេញបាននូវស្តង់ដាសាលារៀនមានប្រសិទ្ធភាពនិងជាសាលាកុមារមេត្រី តាមរយៈការកសាងសមត្ថភាពដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងថ្នាក់សាលារៀន ដើម្បីធានាថាការគាំទ្រ ត្រូវផ្តល់ឱ្យសាលារៀនទាន់ពេលវេលា និង (២) កសាងសមត្ថភាពគ្រូបង្រៀនដើម្បីអនុវត្តកម្មវិធីសិក្សារបស់ជាតិ។ សម្រេចបាននូវគោលបំណងទាំងពីរនេះ ត្រូវមានសកម្មភាពចំនួន៣សម្រាប់អនុវត្ត (១) ពង្រឹងការគ្រប់គ្រងតាមសាលារៀន (២) បំប៉នបន្ថែម និងផ្តល់ការគាំទ្រផ្ទាល់ដល់គ្រូបង្រៀន និង (៣) សាងសង់ និងកែលម្អអគារសិក្សា និងបរិស្ថានសិក្សា (ក្រសួងអប់រំយុវជននិងកីឡា, សៀវភៅប្រតិបត្តិស្តីពីការគ្រប់គ្រងតាមសាលារៀន, ២០១៨)។ កម្មវិធីមួយក្នុងចំណោមកម្មវិធីអាទិភាព ដែលផ្តោតទៅលើ២៥រាជធានីខេត្តទូទាំងប្រទេស ហើយកំពុងត្រូវបានអនុវត្ត តាំងពីឆ្នាំ២០០០មកនោះ គឺការផ្តល់ការអប់រំសម្រាប់សេវាកម្មដល់កុមារកម្ពុជាទាំងអស់ និងកាត់បន្ថយបន្ទុកចំណាយរបស់ក្រសួង (Ministry of Education, 2000)។ កម្មវិធីអាទិភាពនេះបានចូលរួមចំណែកក្នុងការលើកកម្ពស់សេវាកម្មគ្រប់គ្រងអប់រំនៅថ្នាក់មូលដ្ឋាន តាមរយៈមជ្ឈមណ្ឌលគ្រប់គ្រងថវិកាថ្នាក់មូលដ្ឋាននិងស្ថាប័នផ្ទាល់ (ADB, 2002)។

បន្ទាប់មកការគ្រប់គ្រងតាមសាលារៀនក៏អាចត្រូវបានគេហៅថាជាកម្មវិធីសាលាគ្រប់គ្រងដោយខ្លួនឯងផងដែរ (Gamage, 2009)។ គំនិតនៃការធ្វើប្រតិភូកម្ម ពាក់ព័ន្ធនឹងការផ្តល់អំណាចដល់មន្ត្រីឬអង្គភាពថ្នាក់ក្រោមមានសិទ្ធិអំណាចដើម្បីបំពេញមុខងារទាំងអស់ ឬមុខងារមួយចំនួន គឺដើម្បីឱ្យពួកគេ

មានសិទ្ធិសម្រេច និងមានការទទួលខុសត្រូវ ក្នុងការបំពេញតួនាទី និងភារកិច្ចដោយខ្លួនឯង។ ក្នុងបរិបទនេះ មន្ត្រីឬអង្គភាពទទួលបន្ទុកត្រូវបំពេញមុខងារ ដែលមានកំណត់ក្នុងល័ក្ខខ័ណ្ឌជាក់លាក់ហើយត្រូវទទួលខុសត្រូវចំពោះអាជ្ញាធរជាន់ខ្ពស់។ ទោះជាយ៉ាងណាក៏ដោយប្រសិនបើមានអ្វីខុសឆ្គងអាជ្ញាធរជាន់ខ្ពស់ដែលបានផ្ទេរភារកិច្ចនិងមុខងារត្រូវបានគេរំពឹងថានឹងទទួលខុសត្រូវចុងក្រោយ។

ការដកហូតអំណាច ឬផ្ទេរអំណាចទៅឱ្យអង្គភាពវិមជ្ឈការដែលធ្វើឱ្យអង្គភាពនោះមានប្រសិទ្ធភាព ក្នុងការបំពេញភារកិច្ច និងមុខងារជាក់លាក់ដោយមានទំនួលខុសត្រូវពេញលេញ ចំពោះសកម្មភាពអាចចាត់ទុកថាជាជំហានជាក់លាក់ពិតប្រាកដ។ ដំណោះស្រាយនេះអាចមានដល់ថ្នាក់ខេត្ត ថ្នាក់តំបន់ ឬថ្នាក់ស្ថាប័ន ។ ចំពោះករណី ការគ្រប់គ្រងតាមសាលារៀន ឬការគ្រប់គ្រងសាលាដោយខ្លួនឯង ការលះបង់សិទ្ធិអំណាចគឺទៅសាលារៀនដែលធ្វើឱ្យវាក្លាយជាសាលាគ្រប់គ្រងដោយខ្លួនឯង។ វាជាការផ្តល់អំណាចដល់សហគមន៍សាលារៀនដើម្បីអនុវត្តមុខងារភាគច្រើន ហើយមានការទទួលខុសត្រូវលើសកម្មភាពនៃមុខងារពិសេសទាំងនោះ (David_Gamage, 2009)។

យុទ្ធសាស្ត្រកំណែទម្រង់ថ្មីនេះត្រូវបានគេហៅថាជាការគ្រប់គ្រងតាមសាលារៀន ប្រកបដោយប្រសិទ្ធភាព តាមរយៈការចូលរួមពីភាគីពាក់ព័ន្ធក្នុងដំណើរការសាលារៀន តាមមូលដ្ឋាន រឺតាមតំបន់ដែលត្រូវតែគោរពក្របខណ្ឌគោលនយោបាយ និងបទដ្ឋានគតិយុត្តិនានារបស់ក្រសួង។ គោលគំនិតនៃការធ្វើវិមជ្ឈការ ការធ្វើប្រតិភូកម្មអំណាច ការរកដំណោះស្រាយ និងការគ្រប់គ្រងតាមសាលារៀន ឬគេហទំព័រ SBM ឬសាលាគ្រប់គ្រងដោយខ្លួនឯង (SGS)នេះ អាចត្រូវបានចាត់ទុកថា ជាដំណាក់កាលអភិវឌ្ឍន៍ផ្សេងៗគ្នាក្នុងការធ្វើវិមជ្ឈការ និងវិសហមជ្ឈការ ។

ការផ្តល់សេវាអប់រំ ប្រកបដោយប្រសិទ្ធភាព និងទន់ភ្លន់ គឺផ្តោតទៅលើការគ្រប់គ្រង និងការផ្តល់សេវាប្រកបដោយភាពស័ក្តិសិទ្ធិបំផុត សម្រាប់កែលម្អគោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធីទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ការគ្រប់គ្រងគ្រឹះស្ថានសិក្សាប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិត្រូវបង្កើនស្វ័យភាព និងការទទួលខុសត្រូវប្រកបដោយគណនេយ្យភាពចំពោះលទ្ធផល និងគុណភាពនៃការសិក្សា សម្រាប់ទាំងអស់គ្នា (យុទសាស្រ្តកំណែទម្រង់វិស័យអប់រំ, ២០១៨-២០២៣)។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

ក្រសួងអប់រំ យុវជន និងកីឡា បាន និងកំពុងខិតខំព្យាយាមអស់រយៈពេលជាច្រើនឆ្នាំក្នុងគោលបំណងឈានទៅសម្រេចបាននូវគោលដៅនៃការអប់រំសម្រាប់ទាំងអស់គ្នា និងបានផ្ដល់អាទិភាពដល់ការអប់រំ សម្រាប់ធ្វើឱ្យប្រសើរឡើងនូវការទទួលបានសេវាអប់រំប្រកបដោយគុណភាព តាមរយៈការអភិវឌ្ឍស្ថាប័ន ការកសាងសមត្ថភាព និងការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ (MoEYS, 2001)។ ការគ្រប់គ្រងសាលារៀនប្រកបដោយប្រសិទ្ធភាពគឺជាអ្វីដែលក្រសួងខិតខំពង្រឹង និងយកចិត្តទុកដាក់ ដើម្បីធានាឱ្យការអប់រំមានគុណភាព និងប្រសិទ្ធភាពខ្ពស់។ នៅតាមសាលារៀននីមួយៗ ត្រូវបានក្រសួងធ្វើប្រតិភូកម្មសិទ្ធិអំណាច ផ្ដល់ធនធាន និងកសាងសមត្ថភាព ដើម្បីបង្កើនលទ្ធផលសិក្សា ឱ្យឆ្លើយតបបានច្រើនជាងមុន ក្នុងការផ្ដល់សេវាអប់រំនៅតាមសាលារៀន បានទាន់ពេលវេលា និងមានប្រសិទ្ធភាព ដើម្បីកាត់បន្ថយនូវភាពតានតឹងសង្គម នយោបាយ និងធានានូវស្វ័យភាព តម្លាភាពមូលដ្ឋាន ដោយមានការចូលរួមពីសាធារណៈជន ក្នុងការរួមចំណែកទទួលខុសត្រូវ និងដោះស្រាយបញ្ហារបស់រដ្ឋផងដែរ។ វិមជ្ឈការនៃសេវាអប់រំ ត្រូវបានធ្វើឡើង ដើម្បីកៀរគររកធនធានក្នុងស្រុក ក្នុងមូលដ្ឋាន និងទាក់ទាញការចូលរួមរបស់សហគមន៍ អាជ្ញាធរដែនដី មាតាបិតា និងអ្នកអាណាព្យាបាលសិស្ស។ គណៈកម្មការទ្រទ្រង់សាលារៀនក្នុងតំបន់ ឬក្នុងមូលដ្ឋាន ត្រូវបានក្រសួងប្រកាសឱ្យជ្រើសរើសចេញពីសហគមន៍សាលារៀនតាំងពីឆ្នាំ ១៩៩៤។ នៅឆ្នាំ២០០៩ សមាជិកនៃគណៈកម្មការទ្រទ្រង់សាលារៀនត្រូវតែនាយកសាលាជាប្រធាន អាជ្ញាធរមូលដ្ឋាន(ប្រធានភូមិ មេឃុំ ឬចៅសង្កាត់) ជាអនុប្រធាន តំណាងសហគមន៍ មាតាបិតា ឬអ្នកអាណាព្យាបាល និងតំណាងសិស្សជាសមាជិក។ គណៈកម្មការត្រូវតែរួមគ្នាធ្វើផែនការអភិវឌ្ឍន៍សាលារៀន និងសកម្មភាពផ្សេងៗទៀត ដើម្បីឱ្យសាលារៀនមានការរីកចម្រើន។ ទោះជាយ៉ាងណាក៏ដោយ តួនាទីរបស់សមាជិកនីមួយៗ ក្នុងការចូលរួមនៅមានកម្រិត ក្នុងការអនុវត្តការធ្វើផែនការសកម្មភាពអភិវឌ្ឍន៍សាលាក្នុងមូលដ្ឋានរបស់ខ្លួនដែលនាំឱ្យមានភាពយឺតយ៉ាវ។ គោលការណ៍នេះក៏អាចបណ្ដាលមកពី កង្វះថវិកា និងគោលការណ៍ណែនាំមិនច្បាស់លាស់ ទាក់ទងទៅនឹងតួនាទី ភារកិច្ច និងការទទួលខុសត្រូវជាដើម (MoEYS, 2001) ។ តាមរយៈការអនុវត្តកម្មវិធីវិមជ្ឈការអំណាចដល់សាលារៀន នៅមានបញ្ហា

ប្រឈមមួយចំនួនដែលធ្វើឱ្យប៉ះពាល់ដល់ប្រសិទ្ធភាពនៃការអនុវត្ត។ ក្រុមប្រឹក្សាភិបាលនៃធនាគារពិភពលោកបានអនុម័តនូវទឹកប្រាក់ចំនួន៩០លានដុល្លារអាមេរិក ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់ប្រទេសកម្ពុជា ក្នុងការលើកកម្ពស់គុណភាពអប់រំ និងការស្រាវជ្រាវជាន់ខ្ពស់នៅក្នុងប្រទេស និងពង្រីកលទ្ធភាពទទួលបានការអប់រំខ្ពស់សម្រាប់និស្សិតដែលជួបការលំបាក តាមរយៈគម្រោងគាំទ្រវិស័យអប់រំលើកទី២។ គម្រោងនេះ គឺដើម្បីជួយរដ្ឋាភិបាលកម្ពុជា ក្នុងការពង្រីកលទ្ធភាពទទួលបានការអប់រំ (សម្រាប់កុមារ អាយុពី ៣ ទៅ៥ ឆ្នាំ) និងបង្កើនការទទួលបានគុណភាពនៃការអប់រំជាមូលដ្ឋាន សម្រាប់សិស្ស (Tandon,Prateek. Fukao Tsuyoshi, 2015)។ បច្ចុប្បន្ន ក្រសួងបាននិងកំពុងអនុវត្តគម្រោងកែលម្អសាលារៀន(SEIP)ដែលគាំទ្រថវិកាដោយធនាគារពិភពលោក។ ការគ្រប់គ្រងតាមសាលារៀនបាននិងកំពុងអនុវត្តនៅសាលារៀនមធ្យមសិក្សាមួយចំនួនក្នុងរាជធានីខេត្តទូទាំងប្រទេស។ ដោយឡែកនៅរាជធានីភ្នំពេញមានវិទ្យាល័យចំនួន៧បានអនុវត្ត ការគ្រប់គ្រងតាមសាលារៀន និងកំពុងពង្រីកទៅសាលាមធ្យមសិក្សាថែមចំនួន១០០សាលារៀនក្នុងរាជធានីភ្នំពេញ ដើម្បីឱ្យការគ្រប់គ្រងតាមសាលារៀនប្រកប ដោយប្រសិទ្ធភាព។ ក្នុងការអនុវត្តនេះ កម្មវិធីអន្តរាគមន៍សម្រាប់អភិវឌ្ឍន៍សាលារៀនឱ្យមានគុណភាពនិងប្រសិទ្ធភាពលើការបណ្តុះបណ្តាលសិស្សានុសិស្ស ឆ្លើយតបទៅនឹងគោលដៅអប់រំជាតិ និងគោលដៅអប់រំចំណេះទូទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា។ កម្មវិធីអន្តរាគមន៍មាន៤ផ្នែកសំខាន់ៗ ដូចជា (១)ការគ្រប់គ្រងរដ្ឋបាលសាលារៀន (២) ការងាររៀន និងបង្រៀន និងការអនុវត្តកម្មវិធីសិក្សា (៣) ការអភិវឌ្ឍសមត្ថភាពគ្រូ និងការងារអធិការកិច្ចគ្រូបង្រៀន និង (៤)ការរៀបចំផែនការកអភិឌ្ឍន៍សាលារៀននិងការគ្រប់គ្រងថវិកាសាលារៀន។ ដើម្បីម្រេចបាននូវសាលារៀនមានប្រសិទ្ធភាព សាលារៀននីមួយៗអាចប្រើស្តង់ដាសាលាមធ្យមសិក្សាចំណេះទូទៅ សម្រាប់ធ្វើស្វ័យវាយតម្លៃដែលមាន៩ផ្នែកសំខាន់ៗ (ក្រសួងអប់រំយុវជននិងកីឡា ស្តង់ដាសាលាមធ្យមសិក្សា, ២០១៨)។ ស្តង់ដាទាំងប្រាំបួននោះរួមមានៈ ស្តង់ដាទី១ វត្ថុបំណងគោលនយោបាយសាលារៀន ស្តង់ដាទី២ ការបង្រៀននិងបំណែងចែកកម្មវិធីសិក្សា ស្តង់ដាទី៣ មាតាបិតា និងសហគន៍ជួយដល់ការរៀនសូត្រ ស្តង់ដាទី៤ សិស្សនិងសេវាសិស្សជួយសិស្ស ស្តង់ដាទី៥ ការដឹកនាំនិងគ្រប់គ្រង ស្តង់ដាទី៦ ធនធានមនុស្ស ស្តង់ដាទី៧ សម្ភារបង្រៀននិងរៀន ស្តង់ដា

ទី៨ ហេដ្ឋារចនាសម្ព័ន្ធនិងបរិស្ថាន ស្តង់ដាទី៩ ហិរញ្ញប្បទាននិងការគ្រប់គ្រងហិរញ្ញវត្ថុ។ ការសិក្សានេះនឹងផ្តោតទៅលើប្រសិទ្ធភាពនៃការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផលនៅសាលាមធ្យមសិក្សា ក្នុងរាជធានីភ្នំពេញ ពិសេសលើការអនុវត្តស្តង់ដាសាលាមធ្យមសិក្សាចំណេះទូទៅទាំង៩ និងគោលការណ៍នៃការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល (SBM)។

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះមានគោលបំណងសំខាន់២គឺ

- ស្ថានភាពបច្ចុប្បន្ននៃដំណើរការគ្រប់គ្រងសាលារៀនមធ្យមសិក្សា ក្រៅពីសាលាជំនាន់ថ្មី សាលាធនធាន និងសាលាគម្រោងSIEPពិសេសលើការអនុវត្តស្តង់ដាសាលាមធ្យមសិក្សាចំណេះទូទៅទាំង៩។
- សិក្សារកឱ្យឃើញនូវបញ្ហាប្រឈមនានា ក្នុងដំណើរការគ្រប់គ្រងសាលារៀន ប្រកបដោយគុណភាពផ្អែកលើលទ្ធផល ការដឹកនាំនិងគ្រប់គ្រងរបស់នាយកសាលា ការរៀននិងបង្រៀន លទ្ធផលសិក្សារបស់សិស្ស និងការចូលរួមរបស់សហគមន៍មាតាបិតាអាណាព្យាបាល និងអាជ្ញាធរ។

## ១.៤ សំណួរស្រាវជ្រាវ

ដើម្បីឆ្លើយតបនឹងគោលបំណងនៃការសិក្សាស្រាវជ្រាវខាងលើ អ្នកសិក្សាស្រាវជ្រាវបានកំណត់លើកយកសំណួរចំនួនពីរមកពិភាក្សាដូចខាងក្រោម៖

១. តើការគ្រប់គ្រងតាមសាលារៀនប្រកបដោយប្រសិទ្ធភាពនៅមធ្យមសិក្សាក្នុងរាជធានីភ្នំពេញស្ថិតនៅកម្រិតណា បើផ្អែកលើស្តង់ដាសាលាមធ្យមសិក្សាចំណេះទូទៅទាំង៩?

២.តើមានបញ្ហាប្រឈមអ្វីខ្លះក្នុងការគ្រប់គ្រងសាលាប្រកបដោយប្រសិទ្ធភាព នៅមធ្យមសិក្សាចំណេះទូទៅ ក្រៅពីសាលារៀនមធ្យមសិក្សាទាំង៧ ដែលកំពុងអនុវត្តគម្រោង SEIP សាលាធនធាន និងសាលាជំនាន់ថ្មី ក្នុងរាជធានីភ្នំពេញ?

## ១.៥ សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ មានសារៈសំខាន់ដូចតទៅ៖

**ចំពោះសាលារៀន**

- ជួយសាលារៀនឱ្យចូលរួមចំណែកក្នុងការអភិវឌ្ឍគុណភាពអប់រំ និងដកស្រង់បទពិសោធន៍ល្អៗតាមរយៈការប្រែក្លាយបញ្ហាប្រឈមទៅជាកាលានុវត្តភាព ក្នុងការគ្រប់គ្រងសាលារៀនប្រកបដោយប្រសិទ្ធភាព។

- ជួយសាលារៀនរកបាននូវដំណោះស្រាយសមស្របនិងទាន់ពេលវេលា ក្នុងការពង្រឹងនូវភាពជាអ្នកដឹកនាំលើការគ្រប់គ្រង ការងាររៀននិងបង្រៀន ការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស និងការទាក់ទាញសហគមន៍ចូលរួមអភិវឌ្ឍន៍សាលារៀន។

-ជួយដោះស្រាយនូវបញ្ហាប្រឈមនានាក្នុងដំណើរការគ្រប់គ្រងសាលារៀនឱ្យឆ្លើយតបទាន់ពេលវេលានូវតម្រូវការ និងសំណូមចាំបាច់ ក្នុងការអប់រំ ដើម្បីឆ្ពោះទៅរកគុណភាពអប់រំ។

**ចំពោះក្រសួងអប់រំយុវជននិងកីឡា**

- ការស្រាវជ្រាវនេះនឹងផ្តល់ព័ត៌មានដ៏មានប្រយោជន៍សម្រាប់ក្រសួងក្នុងការពង្រឹងបន្ថែមនិងរិះរកយុទ្ធសាស្ត្រផ្សេងៗដើម្បីជួយជំរុញការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល ឱ្យកាន់តែមានប្រសិទ្ធភាពឆ្លើយតបទៅនឹងគោលដៅអប់រំរបស់ក្រសួង។

**ចំពោះអ្នកសិក្សាស្រាវជ្រាវ**

- ជាធនធានឯកសារ សម្រាប់ជំនួយដល់អ្នកសិក្សាក្រោយៗ ក្នុងការសិក្សាស្រាវជ្រាវបន្តទៀតពិសេសលើរបៀបនៃការគ្រប់គ្រងសាលាប្រកបដោយប្រសិទ្ធភាពផ្អែកលើលទ្ធផល។

## ១.៦ ដែនកំណត់នៃការស្រាវជ្រាវ

ដោយសារកត្តាពេលវេលា ឯកសារ និងធនធានមានកំណត់ ដែលពាក់ព័ន្ធក្នុងការស្រាវជ្រាវពិបាករកនិងដោយកង្វះលទ្ធភាពចុះប្រមូលទិន្នន័យឱ្យបានគ្រប់សាលាមធ្យមទាំងអស់ ក្នុងរាជធានីភ្នំពេញ ដែលត្រូវការចំណាយថវិកាច្រើន ដូចនេះការសិក្សាស្រាវជ្រាវនេះ នឹងផ្តោតលើសាលាមធ្យមសិក្សាមួយចំនួនរួមមានវិទ្យាល័យចំនួន៦ និងអនុវិទ្យាល័យចំនួន៦ ក្នុងខណ្ឌចំនួន៦ នៃចំណោមខណ្ឌទាំង១៤។ ការសិក្សាស្រាវជ្រាវនេះគឺផ្តោតទៅលើនាយកសាលា លោកគ្រូ អ្នកគ្រូ(គ្រូបង្រៀន) សិស្សានុសិស្ស គណៈកម្មការ

គ្រប់គ្រងសាលារៀន/គណៈកម្មការទ្រទ្រង់សាលារៀន និងសហគមន៍។ ខ្លឹមសារប្រធានបទផ្ដោតទៅលើការគ្រប់គ្រងសាលារៀនប្រកបដោយប្រសិទ្ធភាពលើ ៤ ចំណុចៈ (១) ការដឹកនាំនិងគ្រប់គ្រងរបស់នាយកសាលា (ការគ្រប់គ្រងរដ្ឋបាល ការគ្រប់គ្រងហិរញ្ញវត្ថុ និងផែនការកែលម្អសាលារៀន) (២) ការបង្រៀន និងការរៀន (ការគ្រប់គ្រងការរៀននិងបង្រៀន និងការអនុវត្តកម្មវិធីសិក្សា) (៣) លទ្ធផលសិក្សារបស់សិស្ស (តេស្ដវាយតម្លៃការសិក្សារបស់សិស្ស) (៤) ការចូលរួមរបស់សហគមន៍ មាតាបិតាសិស្ស (ការចូលរួមនិងតួនាទីរបស់គណៈកម្មការគ្រប់គ្រងសាលារៀន) និងស្តង់ដាទាំង៩ស្ដីពីសាលារៀនប្រសិទ្ធភាពនៅមធ្យមសិក្សា ដែលត្រូវយកមកធ្វើការរៀបចំកម្រងសំណួរ និងសម្ភាសន៍។ ចំនួនដែលត្រូវជ្រើសរើសធ្វើជាសំណាករួមមានៈនាយកវិទ្យាល័យចំនួន៦នាក់ នាយកអនុវិទ្យាល័យចំនួន៦នាក់ គ្រូបង្រៀនចំនួន១១៩នាក់ សិស្សចំនួន១៧១នាក់ គណៈកម្មការគ្រប់គ្រងសាលារៀនចំនួន១៨នាក់ ដាច់ដោយឡែកពីគ្នា។ ចំនួននេះបើទោះបីអ្នកស្រាវជ្រាវគិតថាជាតំណាងឱ្យតួអង្គទាំងអស់ក្នុងរាជធានីភ្នំពេញក៏ដោយ ក៏ជាគុពិតជាក់ស្ដែង វាគ្រាន់តែជាការសន្មតតែប៉ុណ្ណោះ។ ដូច្នេះ អ្នកស្រាវជ្រាវក្រោយៗទៀតអាចធ្វើការស្រាវជ្រាវបន្តបានដោយកំណត់យកភាគសំណាកឱ្យធំជាងនេះ ឬអាចធ្វើទូទាំងរាជធានីភ្នំពេញ ឬទូទាំងប្រទេស។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះត្រូវបានបែងចែកជា៥ ជំពូករួមមានៈ **ជំពូកទី១ សេចក្ដីផ្ដើមៈ** ក្នុងជំពូកនេះអ្នកសិក្សាស្រាវជ្រាវលើកឡើងពីលំនាំបញ្ហា ចំណោទបញ្ហា គោលបំណងនៃការសិក្សាស្រាវជ្រាវ សំណួរស្រាវជ្រាវ ព្រមទាំងដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវលើប្រធានបទ " **ប្រសិទ្ធភាពនៃការគ្រប់គ្រងសាលារៀនដោយផ្អែកលើលទ្ធផលនៅមធ្យមសិក្សាក្នុងរាជធានីភ្នំពេញ**"។ **ជំពូកទី២ ការរំលឹកទ្រឹស្ដីៈ** រាល់ទ្រឹស្ដីរបស់អ្នកស្រាវជ្រាវមុនៗ កម្រងអត្ថបទស្រាវជ្រាវជាតិ និងអន្តជាតិ លិខិតបទដ្ឋានគតិយុត្តិ ប្រកាស សារាចរណ៍ណែនាំ និងឯកសារនានារបស់ក្រសួង និងស្ថាប័ននានា ដែលពាក់ព័ន្ធនឹងប្រធានបទនេះត្រូវបានលើកឡើង ដើម្បីធ្វើជាគំនិតឆ្លុះបញ្ចាំងទៅនឹងការរកឃើញថ្មីក្នុងស្នាដៃស្រាវជ្រាវនេះ។ **ជំពូកទី៣ វិធីសាស្ត្រស្រាវជ្រាវៈ** នៅក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវបានបង្ហាញនូវ

ឧបករណ៍ស្រាវជ្រាវ វិធីសាស្ត្រក្នុងការប្រមូលទិន្នន័យ វិធីសាស្ត្រជ្រើសរើសគំរូសំណាក និងប្រភេទសំណាក ព្រមទាំងវិធីសាស្ត្រវិភាគទិន្នន័យដែលប្រមូលមកតាមបណ្តុំគំនិត និងតាមតារាង ។ **ជំពូកទី៤ លទ្ធផលនៃការស្រាវជ្រាវ៖** លទ្ធផលនៃការស្រាវជ្រាវ និងត្រូវបានយកមកបកស្រាយ និងពិភាក្សា វិភាគយ៉ាងក្បោះក្បាយ ដើម្បីរកឱ្យឃើញនូវចំណុចល្អ និងចំណុចដែលត្រូវកែលម្អនៅក្នុងបរិបទជាក់ស្តែង នៃការគ្រប់គ្រងសាលារៀនប្រកបដោយប្រសិទ្ធភាពតាមសាលារៀនមធ្យមសិក្សានីមួយៗក្នុងរាជធានីភ្នំពេញ។

**ជំពូកទី៥ សេចក្តីសន្និដ្ឋាន និងសំណូមពរ៖** នេះជាផ្នែកដែលអ្នកស្រាវជ្រាវ ធ្វើការសន្និដ្ឋានទៅលើចំណុចទាំងអស់ដែលបានវិភាគ ព្រមទាំងផ្តល់និងលើកឡើងនូវសំណូមពរមួយចំនួនដល់ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ ការិយាល័យអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ ការិយាល័យអប់រំ យុវជន និងកីឡាខណ្ឌ និងតាមសាលារៀនមធ្យមសិក្សានីមួយៗ រួមមានគណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន និងអ្នកសិក្សាស្រាវជ្រាវក្រោយៗ ដើម្បីចូលរួមចំណែកអភិវឌ្ឍន៍ និងធ្វើឱ្យស្ថានភាពគ្រប់គ្រងសាលារៀនប្រកបដោយប្រសិទ្ធភាពជាងមុន។

# ជំពូកទី ២
# រំលឹកទ្រឹស្តី

# ជំពូកទី២

## រំលឹកទ្រឹស្តី

មុននឹងធ្វើការបកស្រាយជំពូកនេះ ឱ្យមានន័យស៊ីជម្រៅ និងក្បោះក្បាយ ត្រូវយល់នូវពាក្យគន្លឹះជាមុនសិន។ តើអ្វីជាការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល? អ្វីជាការគ្រប់គ្រងតាមសាលារៀន? តាមពិតឃ្លាថា កាគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល និងការគ្រប់គ្រងតាមសាលារៀន ឃ្លាទាំងពីរនេះមានន័យថាដូចគ្នា។ ដូចនេះ ការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល ឬការគ្រប់គ្រងតាមសាលារៀន មានអត្ថន័យដូចម្តេច? ការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល គឺសំដៅទៅការគ្រប់គ្រង និងចាត់ចែងសាលារៀនដោយខ្លួនឯង (Gamage & Zajda 2010)។ ចំណែកលោក David_Gamage, 2009 បានឱ្យនិយមន័យថា ការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល គឺជាការលះបង់សិទ្ធិអំណាចទៅឱ្យសាលារៀនដែលធ្វើឱ្យវាក្លាយជាសាលាគ្រប់គ្រងដោយខ្លួនឯង និងការផ្តល់អំណាចដល់សហគន៍សាលារៀនដើម្បីអនុវត្តមុខងារភាគច្រើន ហើយមានការទទួលខុសត្រូវលើសកម្មភាពនៃមុខងារពិសេសទាំងនោះ។ ការគ្រប់គ្រងតាមសាលារៀន(SBM)ជាយុទ្ធសាស្រ្ត ដើម្បីលើកកម្ពស់ការអប់រំ ដោយការផ្ទេរសិទ្ធអំណាចក្នុងការសម្រេចចិត្តសំខាន់ៗ ពីការិយាល័យរដ្ឋនិងស្រុកទៅសាលារៀននីមួយៗ។ SBM ផ្តល់ជូននាយកសាលា លោកគ្រូ អ្នកគ្រូ និងឪពុកម្តាយ ឲ្យគ្រប់គ្រងលើដំណើរការអប់រំ ដោយផ្តល់ការទទួលខុសត្រូវដល់ពួកគេ ក្នុងការសម្រេចចិត្តអំពីថវិកាបុគ្គលិក និងកម្មវិធីសិក្សា។ តាមរយៈការចូលរួមរបស់គ្រូ ឪពុកម្តាយ និងសមាជិក សហគមន៍ដទៃទៀត ក្នុងការសម្រេចចិត្តសំខាន់ៗទាំងនេះ នឹងអាចបង្កើតបរិយាកាសរៀនសូត្រប្រកបដោយប្រសិទ្ធភាពសម្រាប់សិស្សានុសិស្ស (Margery Martin, 1993)។ ការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល ឬការគ្រប់គ្រងតាមសាលារៀន ត្រូវការការចូលរួម មិនត្រឹមតែធនធាន អ្នកជំនាញ នៅតាមសាលារៀនប៉ុណ្ណោះទេ ថែមទាំងពីឪពុកម្តាយ អាណាព្យាបាលសិស្ស និងសហគមន៍ក្នុងការបង្កើតគោលនយោបាយសាលារៀន និងធ្វើការសម្រេចចិត្តសម្រាប់សាលារៀន (Duhou, 1999)។ ផ្អែកលើសៀវភៅណែនាំប្រតិបត្តិស្តីពីការគ្រប់គ្រងតាមសាលារៀនរបស់ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១៨ ការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល(SBM)មានន័យថាជាការប្រតិភូកម្មអំណាច ឬស្វ័យភាពក្នុងការសម្រេចចិត្ត

ទៅដល់ថ្នាក់មូលដ្ឋាន ដោយផ្អែកលើលទ្ធផលនៃអនុវត្តការងាររបស់សាលារៀន និងលទ្ធផលសិក្សារបស់សិស្សានុសិស្ស។ ក្នុងជំពូកនេះនឹងពិភាក្សាអំពីប្រសិទ្ធភាពនៃការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផលនៅសាលាមធ្យមសិក្សាក្រៅពីសាលាជំនាន់ថ្មី សាលាធនធាន និងវិទ្យាល័យទាំង៧ដែលបាននឹងកំពុងអនុវត្តគម្រោងSIEP ក្នុងរាជធានីភ្នំពេញ។

## ២.១ ទិដ្ឋភាពទូទៅនៃការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផលនៅកម្ពុជា

ក្រសួងអប់រំ យុវជន និងកីឡា បានកំពុងខិតខំប្រឹងប្រែង អនុវត្តនូវសកម្មភាពដើម្បីឱ្យការគ្រប់គ្រងតាមសាលារៀនមានគុណភាព។ សាលារៀនជាអង្គភាពមួយយ៉ាងសំខាន់ក្នុងការទទួលខុសត្រូវដោយផ្ទាល់ក្នុងការអភិវឌ្ឍធនធានមនុស្សនៅថ្នាក់មូលដ្ឋាន។ គោលនយោបាយអប់រំនៅកម្ពុជាបានលើកទឹកចិត្ត និងផ្តល់ស្វ័យភាពសម្រេចចិត្តស្ថិតនៅក្រោមលិខិតបទដ្ឋានគតិយុត្តិ សេចក្តីណែនាំនិងគោលការណ៍នានាដើម្បីឱ្យសាលារៀនអនុវត្តនូវសកម្មភាពរបស់ខ្លួននិងមានការចូលរួមរបស់សហគន៍ ដែលតំណាងដោយគណៈកម្មការទ្រទ្រង់ និងគាំទ្រដល់ការធ្វើផែនការអភិឌ្ឍន៍សាលារៀន ផែនការចំណាយ របាយការណ៍ទូទាត់ផ្សេងៗ ដែលជាមធ្យោបាយក្នុងការបញ្ចូលទំនួលខុសត្រូវរបស់សាលារៀននិងសហគមន៍ឱ្យសម្រេចបាននូវចំណុចដៅស្របនឹងផែនការយុទ្ធសាស្ត្រវិស័យអប់រំ។ នៅទសវត្សរ៍ចុងក្រោយនេះ ការគ្រប់គ្រងតាមសាលារៀនបានពេញនិយម ដោយការធ្វើវិមជ្ឈការនៃការអប់រំ ដើម្បីបង្កើនគុណភាពអប់រំ។ លើសពីនេះមានគោលការណ៍ណែនាំថ្នាក់ជាតិ ផ្តល់ការណែនាំអំពីការបង្កើតគណៈកម្មាធិការ និងអនុគណៈកម្មការដែលមានបំណងលើកកម្ពស់អភិបាលកិច្ចសាលារៀនដោយការលើកទឹកចិត្តគ្រូបង្រៀនឱ្យអនុវត្តភារកិច្ចរបស់ខ្លួនឱ្យបានល្អ និងផ្តល់នូវសម្ភារៈបរិក្ខារសិក្សាផ្សេងៗ ព្រមទាំងមានប្រាក់រង្វាន់លើកទឹកចិត្ត ចំពោះគ្រូបង្រៀនល្អ គ្រូឆ្នើម នាយកល្អ សាលាល្អជាដើម ឬប្រមូលកៀរគរសហគមន៍ចូលរួមកសាង ជួលជុល កែលម្អសាលារៀន ការចូលរួម និងផ្សព្វផ្សាយព័ត៌មានផែនការសាលារៀន។ តែទោះជាសហគមន៍មានការចូលរួមយ៉ាងក៏ដោយ ក៏ដំណើរការមិនទាន់បានល្អនៅឡើយដែរ។ ដើម្បីឱ្យមានប្រសិទ្ធភាព តម្រូវឱ្យមានការចូលរួម និងការបង្ហាញនូវគំនិតយោបល់របស់សហគមន៍ មាតាបិតា អាណាព្យាបាល អ្នកមាន អ្នកក្រជួបការលំបាកឱ្យចូលរួមពិភាក្សា រួមគ្នាគិត រួមគ្នាដោះស្រាយ និងរួមគ្នាធ្វើ។ តាមបាឋកថាស្តីពីការ

គ្រប់គ្រងនៅតាមសាលារៀនក្នុងបរិបទកំណែទម្រង់វិស័យអប់រំ ដើម្បីឆ្លើយតបនឹងការអនុវត្តកម្មវិធីសាលារៀនកុមារមេត្រី និងការគ្រប់គ្រងសាលារៀនប្រកបដោយប្រសិទ្ធភាព ឬការគ្រប់គ្រងតាមសាលារៀន គឺត្រូវផ្តោតទៅលើចំណុចសំខាន់ៗចំនួន៤ (ឯកឧត្តមបណ្ឌិតសភាចារ្យហង់ជួន ណារ៉ុន០៣ កុម្ភៈ ២០២០) ៖(១) ការដឹកនាំគ្រប់គ្រងរបស់នាយកសាលា (២) ការរៀននិងបង្រៀនរបស់គ្រូ (៣) លទ្ធផលសិក្សារបស់សិស្សានុសិស្ស (៤) ការចូលរួមរបស់សហគមន៍ មាតាបិតា និងអាជ្ញាធរដែនដី។

## ២.១.១ ការដឹកនាំ និងគ្រប់គ្រងរបស់នាយកសាលា

គុណភាពអប់រំត្រូវផ្តើមចេញពីគុណភាពគ្រូបង្រៀន និងគុណភាពនាយកសាលា។ នាយកសាលាត្រូវដឹងពីមុខងារ តួនាទី និងភារកិច្ចរបស់ខ្លួនជាអ្នកគ្រប់គ្រងប្រកបដោយអភិបាលកិច្ចល្អ។ ការគ្រប់គ្រងគ្មានរូបមន្តជាក់លាក់ងាយស្រួលណាមួយដែលក្រោយពីរៀនចេះទៅ អាចជួយអ្នកគ្រប់គ្រងឱ្យធ្វើអ្វីត្រូវជានិច្ច ឬសម្រេចតាមគោលបំណងរហូតនោះទេ។ អ្វីជាការដឹកនាំ? អ្វីជាការគ្រប់គ្រង? នាយកសាលាត្រូវធ្វើកិច្ចការអ្វីខ្លះ ដើម្បីឱ្យការដឹកនាំ និងគ្រប់គ្រងសាលារៀនមានប្រសិទ្ធភាព?

**ការដឹកនាំ** គឺសំដៅដល់ការឈានមុខមនុស្សទាំងឡាយ ធ្វើជាគម្រូដល់មនុស្សទាំងឡាយលើគ្រប់សកម្មភាព ដូចជាការដេក ដើរ ឈរ អង្គុយ និយាយ ស្តាប់ គិត ផ្ទត់គំនិតវិជ្ជមាន ភាពឆ្លាតវៃ រហ័សរហួន ។ល។ និងការនាំឱ្យមនុស្សធ្វើទង្វើល្អ ដើរផ្លូវល្អ ផ្លូវត្រឹមត្រូវ មិនបំផ្លាញផលប្រយោជន៍មនុស្សជាតិ ឬសង្គម មិនបំផ្លាញអ្នកដទៃ ឬដៃគូប្រកួតប្រជែង ហើយមានចក្ខុវិស័យត្រឹមត្រូវ។

**ការគ្រប់គ្រង** គឺសំដៅទៅដល់ការធ្វើផែនការ ការរៀបចំផែនការ ការរៀបចំចាត់ចែង ការដឹកនាំ និងការត្រួតពិនិត្យធនធានមនុស្ស និងធនធានដទៃទៀត និងកិច្ចសហការគ្នា ជាមួយបុគ្គលិក ដើម្បីឱ្យសម្រេចបាននូវគោលដៅរបស់អង្គភាព សាលារៀន ឬស្ថាប័នប្រកបដោយប្រសិទ្ធភាព។

នាយកសាលាត្រូវតែធ្វើការរៀបចំចាត់ចែងនានា ដើម្បីប្រើមនុស្សទាំងឡាយដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួន ឱ្យធ្វើការជូនអង្គភាពយ៉ាងមានប្រសិទ្ធភាព និងមានប្រសិទ្ធិផលខ្ពស់ រួមបញ្ចូលថែមនូវការឈានមុខមនុស្សទាំងឡាយ ធ្វើជាគម្រូដល់មនុស្សទាំងឡាយលើគ្រប់សកម្មភាព និងនាំឱ្យមនុស្សបុគ្គលិក ធ្វើទង្វើល្អ ដើរផ្លូវល្អ គិតប្រយោជន៍សាលារៀន សង្គម និងប្រទេសជាតិ។ ក្នុងន័យនេះ នាយក

សាលារៀនដែលល្អ ជានាយកដែលគ្រប់គ្រងសាលារៀនប្រកបដោយប្រសិទ្ធភាព ដែលធ្វើឱ្យសម្រេចបាននូវគោលបំណង និងគោលដៅអប់រំ ស្របទៅនឹងគោលនយោបាយអប់រំ របស់ក្រសួងអប់រំ យុវជន និងកីឡា តាមរយៈកិច្ចការសំខាន់ៗ ចំនួន៤ធំផងដែរ រួមមាន (១) ការគ្រប់គ្រងរដ្ឋបាល (២) ការគ្រប់គ្រងហិរញ្ញវត្ថុ (៣) ការធ្វើផែនការកែលម្អសាលារៀន (៤) ការគ្រប់គ្រងការបង្រៀន និងរៀន ។

**ក.ការគ្រប់គ្រងរដ្ឋបាលៈ** គឺជាសមាសភាពនៃការគ្រប់គ្រងតាមសាលារៀន ប្រកបដោយប្រសិទ្ធភាព។ នាយកសាលារៀនជាអ្នកអនុវត្តដោយផ្ទាល់ក្នុងការគ្រប់គ្រងរដ្ឋបាលសាលារៀន ត្រូវបានអនុវត្តសម្រាប់ជួយក្នុងការដឹកនាំនិងគ្រប់គ្រងរបស់នាយកសាលារៀន ដើម្បីធានាដល់ប្រសិទ្ធភាពការងារក្នុងការផ្តល់សេវាអប់រំ ដោយមានការចូលរួមពីសហគន៍មូលដ្ឋាន ឆ្លើយតបទៅនឹងតម្រូវការចំបាច់លើការអភិវឌ្ឍចំណេះដឹង។ នៅក្នុងស្ថាប័ន ឬអង្គភាពនីមួយៗទាមទារចាំបាច់ត្រូវរៀបចំផ្នែករដ្ឋបាលទូទៅមួយឱ្យបានល្អមានវិន័យ មានរបៀបរៀបរយតាមលំដាប់ឋានានុក្រមច្បាប់ និងលិខិតបទដ្ឋាន ជាមធ្យោបាយក្នុងវង្វង់សមត្ថកិច្ចនៃក្រសួងស្ថាប័ន ឬអង្គភាពរបស់ខ្លួន។ ការងាររដ្ឋបាលទូទៅមានការងាររៀបចំ ការងារពិធីការការងារតាក់តែងលិខិត ការងារសណ្តាប់ធ្នាប់សន្តិសុខ ការងារឯកសារ និងព័ត៌មានពាក់ព័ន្ធនិងសមត្ថកិច្ចរបស់ក្រសួងជាដើម។ ចំណែកឯ ការគ្រប់គ្រងរដ្ឋបាលតាមការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល (SBM) មានបីផ្នែកសំខាន់ ដែលមានតួនាទី ខុសៗគ្នាគឺៈ

- គណៈកម្មការគ្រប់គ្រងសាលារៀន/គណៈកម្មការទ្រទ្រង់អភិវឌ្ឍន៍សាលារៀន មានសមាសភាពគណៈនាយកសាលារៀន ប្រធានក្រុមសាលា ក្រុមប្រឹក្សាសង្កាត់ ចៅសង្កាត់/ចៅសង្កាត់រង អាជ្ញាធរ មេភូមិជាដើម ទទួលខុសត្រូវក្នុងការចូលរួមរាល់កិច្ចការទាំងឡាយ និងតាមដានការងារផ្សេងៗដូចជា (១) ការចូលរួមដោះស្រាយបញ្ហាអវិជ្ជមាននៅតាមសាលារៀននីមួយនៅពេលជួបប្រទេះគ្រោះមហន្តរាយធម្មជាតិ (២) ការចូលរួមឃោសនាក្នុងយុទ្ធនាការប្រមូលសិស្សចូលរៀន ការឃោសនាអប់រំ និងបណ្តុះបណ្តាលដល់សហគមន៍មាតាបិតាសិស្ស (៣) ការជួយសង្គ្រោះដល់កុមារងាយរងគ្រោះ កុមារពិការ កុមារក្នុងគ្រួសារក្រីក្រ ជួបការលំបាក ការប្រើអំពើហឹង្សាក្នុងគ្រួសារលើផ្លូវកាយ ផ្លូវចិត្ត និងការប្រព្រឹត្តលើកុមារ ក្នុងនោះមានសមាសភាពក្រុមប្រឹក្សាសង្កាត់ដែលទទួលបន្ទុកការងារស្ត្រី និងកុមារដែលត្រូវយកចិត្តទុកដាក់

ក្នុងកិច្ចការនេះ (៣) ចូលរួមពិនិត្យតាមដាន និងលើកទឹកចិត្តដល់លោកគ្រូអ្នកគ្រូក្នុងការអនុវត្តតួនាទីនិងភារកិច្ចបង្រៀនរបស់ខ្លួនឱ្យមានប្រសិទ្ធភាពខ្ពស់ក្នុងការផ្តល់សេវាអប់រំក្នុងមូលដ្ឋានរបស់ខ្លួន (៤) ការចូលរួមគ្រប់គ្រងទិន្នន័យស្ថិតិគ្រូ សិស្ស ការបោះបង់ការសិក្សា អត្រាត្រួតថ្នាក់ ឡើងថ្នាក់ និងការចូលរៀនឡើងវិញ (៥) រៀបចំការផ្តល់សេវាសុវត្ថិភាព និងបរិយាកាសសិក្សាក្នុងសាលារៀន ហេដ្ឋារចនាសម្ព័ន្ធប្រកបដោយមេត្រីភាព សម្រាប់ទាំងអស់គ្នា។

-គណៈកម្មការគ្រប់គ្រងថ្នាក់រៀន មានសមាសភាពគណៈនាយកទទួលបន្ទុក គ្រូទទួលបន្ទុកថ្នាក់ គ្រូជំនួយបន្ទុកថ្នាក់ គ្រូប្រចាំមុខវិជ្ជា ប្រធាន/អនុប្រធានថ្នាក់ ត្រូវរួមគ្នាតាមដាន និងស្វែងយល់ (១) ការសិក្សារបស់សិស្ស និងការបង្រៀនរបស់គ្រូ តាមរយៈការអង្កេតតាមថ្នាក់ សួរព័ត៌មានពីគ្រូ សិស្ស ការប្រជុំលើការមករៀនទៀងទាត់ បង្រៀនទៀងទាត់ ការផ្តល់ព័ត៌មានត្រឡប់ទៅគ្រូ សិស្ស និងអាណាព្យាបាលសិស្ស (២) ការប្រើប្រាស់ និងការផលិតសម្ភារឧបទ្ទេស បង្រៀន និងរៀន (៣) បរិស្ថាន អនាម័យសិក្សាក្នុងនិងក្រៅថ្នាក់ (៤) ការប្រឡង តេស្ត និងលទ្ធផលរបស់សិស្ស

-គណៈកម្មការក្រុមប្រឹក្សាកុមារនិងយុវជនសម្រាប់សាលារៀន គឺការជួយឱ្យកុមារ យុវជនមានសមត្ថភាពសិក្សាជួយខ្លួនឯង និងអ្នកដទៃ តាមរយៈការសិក្សានៅតាមក្រុម ក្លឹប និងក្នុងបណ្ណាល័យ និងជួយសម្របសម្រួលដោះស្រាយបញ្ហាអវិជ្ជមានក្នុងសាលារៀន ក្នុងថ្នាក់ និងក្រៅថ្នាក់ ការចូលរួមធ្វើផែនការ ដើម្បីប្រយោជន៍ដល់ការសិក្សារបស់កុមារ និងយុវជន ព្រមទាំងធ្វើរបាយការណ៍និងរាយការណ៍ជាផ្លូវការ និងមិនផ្លូវការដល់គណៈគ្រប់គ្រង និងគ្រូទទួលបន្ទុកការងារក្រុមប្រឹក្សាកុមារ និងយុវជន។

-គណៈកម្មការផ្សេងៗ រួមមានគណៈកម្មការប្រឡងប្រណាំង គណៈកម្មការទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀន និងក្មេងទំនើងក្នុងសាលារៀន គណៈកម្មការប្រយុទ្ធប្រឆាំង និងការជួញដូរ រត់ពន្ធធ្វើអាជីវកម្មពលកម្មលើកុមារ និងស្រីក្នុងសាលារៀន សមាសភាពទាំងអស់នោះត្រូវមានគណៈនាយក ចៅសង្កាត់ក្រុមប្រឹក្សាសង្កាត់ អាជ្ញាធរ មេភូមិ មាតាបិតាសិស្សចូលរួមតាមលទ្ធភាពរបស់ពួកគាត់ ដើម្បីឱ្យសាលារៀនក្នុងមូលដ្ឋានទទួលបាននូវសុវត្ថិភាពនិងភាពប្រសើរឡើងក្នុងការធ្វើឱ្យសេវាអប់រំក្នុងមូលដ្ឋានបានល្អឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងក្នុងជីវភាពរស់នៅ។

**ខ.ការគ្រប់គ្រងហិរញ្ញវត្ថុ** សាលារៀនមួយទោះធំ ឬតូច សុទ្ធតែទទួលបាននូវកញ្ចប់ថវិកាថេរ សម្រាប់ដំណើរសាលារៀន និងថវិកាអថេរដែលទទួលបានតាមចំនួនសិស្ស តាមតំបន់ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមការធ្វើផែនការថវិកាប្រចាំឆ្នាំតាមសាលារៀននីមួយៗ។ ដើម្បីឱ្យការគ្រប់គ្រងថវិកាដំណើរការសាលារៀនបានល្អ មានតម្លាភាព មានសុច្ចរិតភាព និងចំទិសដៅតាមផែនការរបស់សាលាដែលបានគ្រោងទុក ក្នុងការរួមចំណែកអភិវឌ្ឍន៍ កែលម្អសោភ័ណភាពសាលា ការបង្រៀន និងការរៀនឱ្យទទួលបានលទ្ធផលល្អប្រសើរនោះ ត្រូវមានការចូលរួមពីភាគីពាក់ព័ន្ធ ដូចជាលោកគ្រូអ្នកគ្រូ សហគមន៍ មាតាបិតា អាជ្ញាធរ ក្នុងការប្រើប្រាស់ថវិកា ឱ្យមានប្រសិទ្ធភាព ឆ្លើយតបទៅនឹងការធ្វើកំណែទម្រង់ស៊ីជម្រៅរបស់ក្រសួងអប់រំ យុវជន និងកីឡា។ ការគ្រប់គ្រងហិរញ្ញវត្ថុបានល្អ ជាកត្តាយ៉ាងសំខាន់ក្នុងការជួយគាំទ្រឱ្យសាលារៀនសម្រេចបាននូវផែនការ និងធានាឱ្យបាននូវការសិក្សាប្រកបដោយគុណភាព និងប្រសិទ្ធភាពនៃអ្នកដឹកនាំរបស់នាយកសាលា ឆ្លើយតបទៅនឹងតម្រូវការខាងសេដ្ឋកិច្ចសង្គម ជីវភាពរស់នៅ និងការរីកចម្រើននៃបច្ចេកវិទ្យាព័ត៌មាន។ ការគ្រប់គ្រងហិរញ្ញវត្ថុតាមសាលារៀនមួយបានល្អ មានប្រសិទ្ធភាព តម្លាភាព និងត្រឹមត្រូវ សាលារៀនទាំងអស់ត្រូវរៀបចំឱ្យមានគណៈកម្មការគ្រប់គ្រង និងប្រើប្រាស់ជាលាយលក្ខណ៍អក្សរ ក្នុងការអនុវត្តតាមតួនាទី និងភារកិច្ចរបស់សមាជិកនីមួយៗក្នុងគណៈកម្មការគ្រប់គ្រង និងប្រើប្រាស់ថវិកា និងអនុគណៈកម្មការតាមផ្នែកនីមួយៗ ដើម្បីចូលរួមអនុវត្តក្នុងការសម្រេចចិត្ត និងពិនិត្យតាមដាន និងធ្វើរបាយការណ៍ស្តីពីវឌ្ឍនភាព តាមរយៈការពង្រឹងការទទួលខុសត្រូវតាមតួនាទីរបស់ខ្លួនក្នុងគោលបំណងសម្រេចគោលដៅអប់រំ។

**គ.ការធ្វើផែនការកែលម្អសាលារៀន៖ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន៥ឆ្នាំ និងផែនការប្រតិបត្តិប្រចាំឆ្នាំ**

នៅក្នុងបរិបទនៃវិមជ្ឈការ ការផ្តល់ធនធាន និងយន្តការសមស្រប ដើម្បីតម្លាភាពការងារដល់ប្រព័ន្ធអប់រំ គឺជាកត្តាសំខាន់ក្នុងការលើកកម្ពស់លទ្ធផល និងបច្ច័យនៃសកម្មភាពអប់រំ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន និងផែនការប្រតិបត្តិប្រចាំឆ្នាំ បានរួមបញ្ចូលទាំងវិធានការកែលម្អការគ្រប់គ្រងថវិកាឱ្យមានប្រសិទ្ធភាព ប្រសើរជាងមុន ក្នុងការផ្សារភ្ជាប់ទំនាក់ទំនងរវាងលទ្ធផល និងធនធានហិរញ្ញវត្ថុ។ ការអនុវត្ត

ក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន ការអភិវឌ្ឍសមត្ថភាពរបស់បុគ្គលិកនៅគ្រប់កម្រិត ដើម្បីអនុវត្តការងារប្រកបដោយប្រសិទ្ធភាពធៀបនឹងស្តង់ដាច្បាស់លាស់ នឹងនាំមកនូវអភិបាលកិច្ចល្អ។ ដើម្បីគាំទ្រដល់ការងារនេះ សាលារៀននឹងបន្តអនុវត្តការពង្រឹងភាពជាដៃគូរវាងរាជរដ្ឋាភិបាល សហគមន៍ មាតាបិតាសិស្ស ដៃគូអភិវឌ្ឍន៍វិស័យឯកជន និងបណ្តាអង្គការមិនមែនរដ្ឋាភិបាលជាច្រើនទៀត។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន និងផែនការប្រតិបត្តិប្រចាំឆ្នាំ ត្រូវបានរៀបចំឡើង ដើម្បីឆ្លើយតបទៅនឹងតម្រូវការអប់រំ និងដើម្បីបញ្ជាក់ឱ្យបានច្បាស់លាស់នូវទំនាក់ទំនងរវាងគោលនយោបាយជាតិ និងគោលនយោបាយវិស័យអប់រំ។ ផែនការនេះបង្ហាញពីទំនាក់ទំនងពិតប្រាកដ រវាងក្របខណ្ឌយុទ្ធសាស្ត្រ កម្មវិធី សកម្មភាព ព្រមទាំងធនធានមនុស្ស និងហិរញ្ញវត្ថុ។ ផែនការទាំងនេះ ក៏ជាផែនទីបង្ហាញផ្លូវនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពសម្រាប់ការអប់រំនៅឆ្នាំ២០៣០។

នាយកសាលា/គណៈគ្រប់គ្រងសាលារៀន និងភាគីពាក់ព័ន្ធ ត្រូវរួមគ្នាកសាងផែនការទាំងនេះឡើង ដែលទម្រង់របស់វាជាផែនការអភិវឌ្ឍន៍សាលារៀនគ្រប់ដណ្តប់លើ១១ចំណុច រួមមាន (១) សេចក្តីផ្តើម (២) ប្រវត្តិសាលារៀន (៣) ចក្ខុវិស័យ (៤) បេសកម្ម (៥) ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈម (៦) គោលបំណង (៧) ចំណុចដៅ (៨) យុទ្ធសាស្ត្រ និងសកម្មភាព (៩) តម្រូវការហិរញ្ញប្បទាន (១០) យន្តការពិនិត្យតាមដាន និងវាយតម្លៃ និង (១១) តារាងឧបសម្ព័ន្ធ។ ការធ្វើផែនការអភិឌ្ឍន៍សាលារៀនទាំងអស់នេះ គឺពឹងផ្អែកទៅលើស្តង់ដាទាំង៩ ស្តីពីប្រសិទ្ធភាពការគ្រប់គ្រងតាមសាលារៀន ដូចដែលមានក្នុងតារាងផែនការប្រតិបត្តិប្រចាំឆ្នាំគំរូខាងក្រោម៖

ទម្រង់ផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀនមួយ

| លទ្ធផលរំពឹងទុក | សកម្មភាពដែលគ្រោង | ក្របខណ្ឌពេលវេលា | | | | អ្នកអនុវត្ត | តម្រូវការថវិកា | ប្រភពធនធានដែលមាន | | ថវិកាសរុប | កង្វះថវិកា |
|---|---|---|---|---|---|---|---|---|---|---|---|
| | | Q1 | Q2 | Q3 | Q4 | | | រដ្ឋ | ដៃគូ | | |
| | | | | | | | 1 | 2 | 3 | 4=2.3 | 5=1-4 |
| សរុប | | | | | | | | | | | |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| ស្តង់ដាទី១៖ វត្ថុបំណងគោលនយោបាយសាលារៀន | | | | | | | | | | | |
| -------------------- | ▪ សកម្មភាព<br>............. | | | | | | | | | | |
| ស្តង់ដាទី២៖ ការបង្រៀន និងរៀន | | | | | | | | | | | |
| -------------------- | ▪ សកម្មភាព<br>............. | | | | | | | | | | |
| ស្តង់ដាទី៣៖ មាតាបិតា និងសហគមន៍ជួយការសិក្សារបស់សិស្ស | | | | | | | | | | | |
| -------------------- | ▪ សកម្មភាព<br>............. | | | | | | | | | | |
| ស្តង់ដាទី៤៖ សិស្ស និងសេវាជួយសិស្ស | | | | | | | | | | | |
| -------------------- | ▪ សកម្មភាព<br>............. | | | | | | | | | | |
| ស្តង់ដាទី៥៖ ការដឹកនាំ និងគ្រប់គ្រង | | | | | | | | | | | |
| -------------------- | ▪ សកម្មភាព<br>............. | | | | | | | | | | |
| ស្តង់ដាទី៦៖ ធនធានមនុស្ស | | | | | | | | | | | |
| -------------------- | ▪ សកម្មភាព<br>............. | | | | | | | | | | |
| ស្តង់ដាទី៧៖ សម្ភារបង្រៀន និងរៀន | | | | | | | | | | | |
| -------------------- | ▪ សកម្មភាព<br>............. | | | | | | | | | | |
| ស្តង់ដាទី៨៖ កសាងហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានសាលារៀន | | | | | | | | | | | |
| -------------------- | ▪ សកម្មភាព<br>............. | | | | | | | | | | |
| ស្តង់ដាទី៩៖ កៀរគរហិរញ្ញប្បទាន និងគ្រប់គ្រងហិរញ្ញវត្ថុ | | | | | | | | | | | |
| -------------------- | ▪ សកម្មភាព<br>............. | | | | | | | | | | |

### ២.១.២ ការគ្រប់គ្រងការរៀន និងបង្រៀន

នៅក្នុងយុទ្ធសាស្ត្រកំណែទម្រង់ការគ្រប់គ្រងអប់រំ ដើម្បីលើកកម្ពស់ភាពជាពលរដ្ឋមានគុណភាព នៅកម្ពុជា មានការវាយតម្លៃការសិក្សារបស់សិស្សជាប្រចាំ កែលម្អវិធីសាស្ត្របង្រៀន ការដាក់បញ្ចូលភាពជាពលរដ្ឋមានគុណភាពក្នុងកម្មវិធីសិក្សា និងសៀវភៅសិក្សាគោល។

- **ការវាយតម្លៃការសិក្សារបស់សិស្សជាប្រចាំ៖** សាលារៀនត្រូវសម្របសម្រួលការវាយតម្លៃឱ្យឆ្លើយតបនឹងស្តង់ដា ប្រមូលចងក្រងទិន្នន័យ និងព័ត៌មាន សម្រាប់រៀបចំរបាយការណ៍សមិទ្ធផលនានានៃការវាយតម្លៃការសិក្សារបស់សិស្សជាត្រីមាស ឆមាស ប្រចាំឆ្នាំ និងលើកទឹកចិត្តឪពុកម្តាយ អាណាព្យាបាលឱ្យតាមដានលទ្ធផលសិក្សារបស់សិស្ស។ រីឯគណៈកម្មការគ្រប់គ្រងសាលារៀន ឯកភាពលើលទ្ធផលវាយតម្លៃការអនុវត្តរបស់សាលារៀន និងរបាយការណ៍សមិទ្ធកម្មនៃការសម្រេចបានសូចនាករ និងចំណុចដៅទាក់ទងនឹងលទ្ធផលសិក្សារបស់សិស្ស។ គ្រូបង្រៀនត្រូវរៀបចំតេស្តចំណេះដឹង និងបំណិនរបស់សិស្សឱ្យបានត្រឹមត្រូវ និងមានសង្គតិភាពជាមួយក្របខណ្ឌវង្វាយតម្លៃថ្នាក់ជាតិ។ គ្រូត្រូវប្រើប្រាស់វិធីសាស្ត្របង្រៀនថ្មីៗ ដើម្បីបង្កើនលទ្ធផលសិក្សារបស់សិស្ស ជួយសិស្សរៀនយឺតជាប្រចាំ និងលើកទឹកចិត្តសិស្សដែលឆ្នើម។

- **ការកែលម្អវិធីសាស្ត្របង្រៀន៖** សាលារៀនត្រូវផ្តល់សម្ភារៈសម្រាប់គ្រូ ដើម្បីផលិតសម្ភារឧបទ្ទេសផ្តល់បច្ចេកវិទ្យាដើម្បីឱ្យគ្រូបង្រៀនប្រើប្រាស់ក្នុងការអនុវត្តវិធីសាស្ត្របង្រៀនថ្មីៗ។ នាយកសាលាត្រូវធ្វើអធិការកិច្ចអចិន្ត្រៃយ៍ក្នុងដំណើរការងារអប់រំ ដើម្បីសម្រេចកំណែទម្រង់ការគ្រប់គ្រងការសិក្សានេះ។ ចំណែកលោកគ្រូអ្នកគ្រូត្រូវប្រើប្រាស់វិធីសាស្ត្របង្រៀនល្អៗ វិធីសាស្ត្របង្រៀនបែបប្រពៃណីនិយម(បែបឧទ្ទេស បែបចង្អុលបង្ហាញ) វិធីសាស្ត្របែបស្ថាបនានិយម (បែបរិះរក បែបដោះស្រាយបញ្ហា បែបផែនទីគំនិត បែបតុក្កតាគំនិត បែបពិភាក្សា បែបសហការ បែបអនុមានរួម អនុមានញែក (ប្រាក់ពៅ ឃិនវណ្ណីបានកក្កដា, ២០១៩) ។ គ្រូបង្រៀនត្រូវចេះគ្រប់គ្រងថ្នាក់រៀន ដើម្បីដឹងពីស្ថានភាពសិស្សច្បាស់លាស់ចេះប្រើបច្ចេកវិទ្យាព័ត៌មានក្នុងការបង្រៀន។ ដើម្បីទាក់ទាញសិស្ស គ្រូត្រូវចេះប្រើប្រាស់សំណួរចម្លើយតាមទ្រឹស្តីBloom ក្នុងការជួយសិស្សឱ្យឆ្លុះបញ្ចាំងពីបទពិសោធន៍ និងបរិបទថ្មី ក្នុងការដោះស្រាយបញ្ហា

ជីវិតជាក់ស្តែងប្រចាំថ្ងៃ លើកទឹកចិត្តសិស្សឱ្យចេះរៀបចំបទបង្ហាញ និងបង្ហាញតាមកម្មវិធីផ្សេងៗដោយប្រើប្រាស់បច្ចេកវិទ្យាជាកម្មវិធី PowerPointជាដើមនៅក្នុងថ្នាក់ និងតាមក្រុម។

- **ការដាក់បញ្ចូលភាពជាពលរដ្ឋមានគុណភាពក្នុងកម្មវិធីសិក្សា និងសៀវភៅសិក្សាគោល៖** រៀបចំបន្ទប់ឧបករណ៍បច្ចេកវិទ្យាដូចជាLCD កុំព្យូទ័រ និងសម្ភារបង្រៀនផ្សេងៗទៀត។ ត្រូវកែលម្អបណ្ណាល័យនៅសាលារៀនឱ្យស្របតាមស្តង់ដាបណ្ណាល័យសតវត្សទី២១ ដើម្បីផ្តល់ឱកាសដល់សិស្សានុសិស្សសិក្សារៀនសូត្រ ស្រាវជ្រាវ និងជួយដល់ការវិភាគឱ្យកាន់តែស៊ីជម្រៅ។ សាលារៀនត្រូវមានប្រព័ន្ធគ្រប់គ្រងសៀវភៅសិក្សាគោលឱ្យមានប្រសិទ្ធភាព ដើម្បីធានាថាគ្រប់សិស្សទាំងអស់មានសៀវភៅសិក្សាគោល សម្រាប់រៀនសូត្រតាមមុខវិជ្ជា និងតាមកម្រិតថ្នាក់នីមួយៗ។ គ្រូបង្រៀនជាអ្នកដើរតួ និងធានាថាសិស្សទទួលបានចំណេះដឹងលើបញ្ហាសកល និងចេះប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងឧបករណ៍ឌីជីថល ដើម្បីអនុវត្តកម្មវិធីសិក្សាភាពជាពលរដ្ឋមានគុណភាពនៅក្នុងថ្នាក់រៀន បង្រៀនសិស្សបែបសិក្សាគម្រោង និងធ្វើការបំផុសគំនិតក្នុងកម្មវិធីសិក្សាភាពជាពលរដ្ឋមានគុណភាព លើកទឹកចិត្តសិស្សឱ្យចេះរៀបចំសម្ភារសិក្សាតាមរយៈការធ្វើបទបង្ហាញតាមបែបបច្ចេកវិទ្យាព័ត៌មាន និងចុងក្រោយត្រូវរៀបចំការប្រឡងពាក់ព័ន្ធប្រធានបទភាពជាពលរដ្ឋប្រកបដោយគុណភាព និងចេះដោះស្រាយបញ្ហាប្រឈមនានា (យុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ,២០១៩-២០២៣)។

### ២.១.៣ លទ្ធផលសិក្សារបស់សិស្ស

សិស្សានុសិស្ស ត្រូវមានសមត្ថភាពចេះអាន សរសេរ និងនិយាយបានត្រឹមត្រូវ ចេះគិតលេខ និងបង្ហាញបានត្រឹមត្រូវលើមុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រ និងមានការគិតវិភាគបានស៊ីជម្រៅដោះស្រាយប្រកបដោយគំនិតច្នៃប្រឌិត ចេះទទួលខុសត្រូវ គោរពអ្នកដទៃ រក្សាសេចក្តីថ្លៃថ្នូរ មានសីលធម៌ខ្ពស់ មានអនាម័យ រក្សាបរិស្ថាន និងចូលរួមគ្រប់សកម្មភាពកីឡា សិល្បៈនិងតន្ត្រី និងរក្សាវប្បធម៌ជាតិ ។

### ២.១.៤ ការចូលរួមរបស់សហគមន៍ មាតាបិតាសិស្ស និងអាជ្ញាធរមូលដ្ឋាន

ក្រសួងបានប្រែក្លាយគណៈកម្មការទ្រទ្រង់សាលារៀន ទៅជាគណៈកម្មការគ្រប់គ្រងសាលារៀន ដើម្បីធានាឱ្យមានការចូលរួមកាន់តែច្រើនពីអ្នកពាក់ព័ន្ធក្នុងការគ្រប់គ្រងសាលារៀន ហើយសាលារៀនជាពិសេសនាយកសាលា ជាអ្នកផ្តួចផ្តើមបង្កើតគណៈកម្មការគ្រប់គ្រងសាលារៀន និងលើកទឹកចិត្តសហគមន៍ឱ្យចូលរួមបានច្រើនក្នុងការគ្រប់គ្រងសាលារៀន បង្កើនភាពជឿជាក់ និងទុកចិត្តព្រមទាំងសហការ ជួយរៀបចំផែនការអភិវឌ្ឍន៍សាលារៀន និងថ្នាក់រៀន និងប្រមូលផ្តុំនូវធនធានបន្ថែមរួមទាំងថវិកាចូលរួមអភិវឌ្ឍន៍សាលា។ លោកគ្រូអ្នកគ្រូ សិស្សានុសិស្សត្រូវរៀបចំកិច្ចប្រជុំជាទៀងទាត់រវាងសហគមន៍និងសាលារៀន ដើម្បីរួមគ្នាដោះស្រាយបញ្ហាប្រឈមនានាក្នុងដំណើរការអនុវត្តការងារកន្លងមក ឱ្យទទួលបានប្រសិទ្ធភាពក្នុងការចូលរួមអនុវត្តគោលនយោបាយអប់រំ។

ចំណុចដែលបានលើកឡើងទាំងអស់ខាងលើនេះគឺជាចំណុចអាទិភាព ដែលជះឥទ្ធិពលដល់ប្រសិទ្ធភាពនៃការគ្រប់គ្រងសាលារៀន។ ដើម្បីជំរុញឱ្យការដឹកនាំ និងគ្រប់គ្រងសាលារៀនមានប្រសិទ្ធភាព ទាល់តែសាលារៀនមានគណៈគ្រប់គ្រងមានស្តង់ដា។ ស្តង់ដានេះគឺសំដៅទៅលើស្តង់ដានាយកសាលា។ ក្រសួងបានបង្កើតនូវស្តង់ដានាយកសាលាមធ្យមសិក្សា ដែលបានបញ្ជាក់នូវកម្រិតអប្បរមា និងសមត្ថភាព ក្នុងការបំពេញតួនាទី និងមុខងារជានាយកសាលា។

## ២.២ ស្តង់ដានាយកសាលាមធ្យមសិក្សា

ក្រសួង បានដាក់ចេញ នូវគោលនយោបាយអប់រំចំនួនពីរ គឺគោលនយោបាយទី១៖ ធានាការអប់រំមានគុណភាព សមធម៌ បរិយាបន្ន និងលើកកម្ពស់ការសិក្សាពេញមួយជីវិត សម្រាប់ទាំងអស់គ្នា និងគោលនយោបាយទី២ គឺការធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់។ នាយកសាលាគឺជាមន្ត្រីគ្រប់គ្រងអប់រំ ហេតុនេះហើយ ទើបក្រសួងបានរៀបចំស្តង់ដានាយកសាលា ក្នុងន័យពង្រឹងភាពជាអ្នកដឹកនាំសាលារៀនឱ្យមានគុណវឌ្ឍិគ្រប់គ្រាន់ មានសមត្ថភាព និងភាពថ្លៃប្រឌិតខ្ពស់ មានការដឹកនាំ និងគ្រប់គ្រងសាលារៀនល្អ សម្រាប់ការផ្តល់សេវាអប់រំប្រកបដោយគុណភាពទាំងក្នុងប្រទេស តំបន់ និងពិភពលោក ឆ្លើយតបទៅនឹងការអភិវឌ្ឍខ្លួនពេញមួយជីវិត និងដើម្បីឆ្លើយតបទៅនឹងចក្ខុវិស័យឆ្នាំ២០៣០។ ស្តង់ដានាយកសាលាមធ្យមសិក្សាមានចំនួន៦ រួមមាន៖

**ស្តង់ដាទី១៖ កម្រិតវប្បធម៌ និងបទពិសោធការងារ**

នាយកសាលារៀន ត្រូវមាន៖

១. កម្រិតវប្បធម៌យ៉ាងទាបបំផុតបរិញ្ញាបត្រ ឬ សញ្ញាបត្រសមមូល ឬប្រសិទ្ធិផលគ្រប់គ្រាន់ (នាយកសាលាល្អប្រចាំឆ្នាំណាមួយ)

២. វិញ្ញាបនបត្រវិជ្ជាជីវៈនាយកសាលារៀន

៣. ចំណេះដឹងជំនាញភាសាបរទេសអាចប្រើប្រាស់បានក្នុងការប្រាស័យទាក់ទង

៤. បទពិសោធន៍បំពេញការងារជាគ្រូបង្រៀនយ៉ាងតិច៥ឆ្នាំ

**ស្តង់ដាទី២៖ សមត្ថភាព និងគុណសម្បត្តិរបស់នាយកសាលារៀន**

នាយកសាលារៀន ត្រូវមានសមត្ថភាព និងគុណសម្បត្តិដែលបង្ហាញពីភាពខ្លាំង និងប្រសិទ្ធភាពរបស់ខ្លួនក្នុងការគ្រប់គ្រង និងបំពេញការងារឱ្យអស់ពីសមត្ថភាព និងលទ្ធភាព ដោយយកចិត្តទុកដាក់លើការអភិវឌ្ឍជំនាញវិជ្ជាជីវៈរបស់ខ្លួនជាប្រចាំ។ នាយកសាលា ត្រូវធ្វើជាគម្រូ ក្នុងការដឹកនាំ និងគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព ដូចជាការបង្ហាញសកម្មភាពល្អៗប្រចាំថ្ងៃ ហ៊ានបង្ហាញពីតម្លាភាព និងគណនេយ្យភាព ផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងមានមោទនភាពលើវិជ្ជាជីវៈរបស់ខ្លួនជាប្រចាំ ចេះជ្រើសរើសចំណុចអទិភាពមកធ្វើមុនគេ មានក្រមសីលធម៌វិជ្ជាជីវៈ ភាពជាអ្នកដឹកនាំ និងការប្តេជ្ញាចិត្តខ្ពស់ ហ៊ាននិយាយ ហ៊ានធ្វើ ហ៊ានទទួលខុសត្រូវ មានការអត់ធ្មត់ និងចេះសម្របខ្លួនក្នុងស្ថានភាពលំបាក ស្រឡាញ់ការពារនិងថែរក្សាបរិស្ថានស្អាត។

**ស្តង់ដាទី៣៖ បំណិនត្រិះរិះពិចារណា និងនវានុវត្តន៍**

នាយកសាលា ចាំបាច់ត្រូវស្វែងយល់ពីក្របខ័ណ្ឌគតិយុត្តិ តាមរយៈការអភិវឌ្ឍសមត្ថភាព ការពង្រឹងយន្តការ គោលការណ៍ជំរុញប្រសិទ្ធភាពការងារ ដោយមានការគិត វិភាគ ប្រមូលភស្តុតាង ទិន្នន័យ និងសេណារីយ៉ូក្នុងការដោះស្រាយបញ្ហា ព្រមទាំងគិតទៅលើគំនិតថ្មីៗ ដែលអាចធ្វើឱ្យប្រសើរឡើងនូវការបំពេញការងារ ដោយមានការចូលរួមពីភាគីពាក់ព័ន្ធ ក្នុងការធ្វើសេចក្តីសម្រេចចិត្តបានត្រឹមត្រូវ។ នាយកសាលារៀនត្រូវមានចក្ខុវិស័យ បេសកម្ម គោលនយោបាយ និងផែនការយុទ្ធសាស្ត្រ ផែនការសកម្ម

ភាពច្បាស់លាស់ ព្រមទាំងចេះ បែងចែក និងប្រើប្រាស់ធនធាន (ថវិកា មនុស្ស សម្ភារៈ និងព័ត៌មាន)ត្រឹមត្រូវ និងមានប្រសិទ្ធភាព ចេះធ្វើការត្រួតពិនិត្យ និងវាយតម្លៃការងារ ដើម្បីធ្វើការកែលម្អនូវចំណុចខ្វះខាតនានានិងដោះស្រាយទាន់ពេលវេលា រាល់សំណូមពរ ក្នុងគោលដៅកែលម្អប្រសិទ្ធភាពការងារ។ ចូលរួមផ្តល់ទិន្នន័យ និងព័ត៌មានដល់ថ្នាក់ដឹកនាំតាមឋានានុក្រម និងតាមតម្រូវការចំបាច់។

**ស្តង់ដាទី៤៖ ភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរដ្ឋបាលសាលារៀន**

នាយកសាលារៀន ត្រូវធ្វើការគ្រប់គ្រងរដ្ឋបាលសាលារៀនមានការអភិវឌ្ឍឱ្យកាន់តែប្រសើរឡើងគ្រប់ផ្នែកប្រកបដោយគុណភាព និងប្រសិទ្ធភាពមានដូចជាការងារបរិស្ថាន ការគ្រប់គ្រងបុគ្គលិក ការគ្រប់គ្រងហិរញ្ញវត្ថុ និយ័តភាពការងារ ការត្រួតពិនិត្យវាយតម្លៃការផ្តល់សេវា ការគ្រប់គ្រងទិន្នន័យបុគ្គលិក ថ្នាក់សិស្ស និងការរៀបចំផែនការសកម្មភាព ថវិកា ពិសេសត្រូវបង្ហាញនូវអ្វីដែលសម្រេចជាក់លាក់ថ្មី ដែលនាយកសាលាបានអនុវត្ត។ ភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរដ្ឋបាលសាលារៀនមានសូចនាករ៣សំខាន់ រួមមាន៖ (១) ការគ្រប់គ្រងរដ្ឋបាល (២) ការគ្រប់គ្រងបុគ្គលិក និង (៣) ការគ្រប់គ្រងហិរញ្ញវត្ថុ។

**១. ការគ្រប់គ្រងរដ្ឋបាល៖** មានការរៀបចំ និងបង្កើតគណៈកម្មការ អនុគណៈកម្មការ និងក្រុមប្រឹក្សានានា ការបង្កើតរចនាសម្ព័ន្ធបែងចែកតួនាទី និងភារកិច្ចដល់គណៈនាយក បុគ្គលិកទីចាត់ការនិងបុគ្គលិកបង្រៀន តាមជំនាញប្រកបដោយប្រសិទ្ធភាព ការរៀបចំទុកដាក់លិខិតស្នាមនានា និងឯកសារគណនេយ្យស្របតាមការណែនាំ ការធ្វើប្រតិភូកម្មឱ្យមានប្រសិទ្ធភាព ការបង្កើតវប្បធម៌ទំនាក់ទំនងរវាងបុគ្គលិកនិងបុគ្គលិក បុគ្គលិកនិងគណៈនាយក គណៈនាយក និងថ្នាក់ដឹកនាំ ការរៀបចំបង្កើតប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិសាលារៀន ដឹកនាំអង្គប្រជុំប្រកបដោយប្រសិទ្ធភាព បង្កើនការគ្រប់គ្រង និងប្រើប្រាស់បច្ចេកវិទ្យាសម្រាប់ការគ្រប់គ្រងសាលារៀន មានប្រព័ន្ធទំនាក់ទំនងសង្គម និងសមត្ថភាពក្នុងការគិតនិងដោះស្រាយប្រកបដោយភាពឆ្នៃប្រឌិត ព្រមទាំងធ្វើការចែករំលែកនូវបទពិសោធន៍ល្អៗ ដល់សាលាដទៃទៀត។

**២. កាគ្រប់គ្រងបុគ្គលិក៖** មានការវាយតម្លៃការបំពេញការងាររបស់គ្រូបង្រៀនប្រកបដោយតម្លាភាព និងមានការចូលរួម។ បង្កលក្ខណៈងាយស្រួលដល់បុគ្គលិកនៅក្នុងសាលាឱ្យទទួលបានការ

សិក្សាបន្ថែម និងការស្រាវជ្រាវបន្ថែម ក្នុងការពង្រីកចំណេះដឹងលើមុខវិជ្ជាវិធីសាស្ត្របង្រៀនថ្មីល្អៗ លើកទឹកចិត្តដល់គ្រូដែលមានស្នាដៃតាមរយៈការស្នើដំឡើងឋានន្តរស័ក្តិ ថ្នាក់ ប័ណ្ណសរសើរ ស្មារតី និងសម្ភារៈ ស្គាល់សុខទុក្ខរបស់គ្រូ និងបុគ្គលិកក្នុងសាលារៀន អំពីស្ថានភាពរស់នៅ ចំណង់ចំណូលចិត្ត ជាពិសេសត្រូវលើកស្ទួយតម្លៃយេនឌ័រក្នុងការចូលរួមគ្រប់សកម្មភាពរបស់សាលារៀន។ ធ្វើការអប់រំ ណែនាំ និងចាត់វិធានការរដ្ឋបាលចំពោះបុគ្គលិកអសកម្មការងារផ្សេងៗ និងត្រូវពង្រឹងសាមគ្គីភាពផ្ទៃក្នុងល្អជានិច្ច។

**៣. ការគ្រប់គ្រងហិរញ្ញវត្ថុ៖** នាយកសាលាត្រូវតែមានចំណេះដឹងផ្នែកហិរញ្ញវត្ថុ ក្នុងការអនុវត្តការងារគ្រប់គ្រងឱ្យមានប្រសិទ្ធភាព តម្លាភាព និងប្រសិទ្ធិផលខ្ពស់ តាមរយៈការធ្វើផែនការ និងការធ្វើគម្រោងថវិកា ការពិនិត្យតាមដាន និងវាយតម្លៃលើលទ្ធផលនៃការអនុវត្តផែនការអភិវឌ្ឍន៍សាលា ដោយប្រើប្រាស់ប្រភពថវិកា ធនធាននានា និងមានការចូលរួមពីបុគ្គលិក គ្រូបង្រៀន សហគមន៍ និងគណៈកម្មការគ្រប់គ្រងថវិកាប្រចាំសាលារៀន។

**ស្តង់ដាទី៥៖ ភាពជាអ្នកដឹកនាំលើកម្មវិធីសិក្សា ការបង្រៀន និងរៀន**

នាយកសាលា ចាំបាច់ត្រូវដឹកនាំការអនុត្ត និងការកែលម្អកម្មវិធីសិក្សា បង្កើតបរិស្ថាន និងបរិយាកាសសិក្សាល្អ ក្នុងការធ្វើអធិការកិច្ច និងវាយតម្លៃការបំពេញការងាររបស់គ្រូបង្រៀន និងការផ្តល់លទ្ធផលសិក្សារបស់សិស្ស ដោយមានសូចនាករសំខាន់ៗរួមមាន៖ ការគ្រប់គ្រងការរៀននិងបង្រៀន ត្រូវធានាឱ្យមានសម្ភារៈគ្រប់គ្រាន់ក្នុងដំណើរការបង្រៀននិងរៀន ជំរុញឱ្យគ្រូធ្វើផែនការ និងគម្រោងបង្រៀនតាមត្រីមាស ឆមាស និងប្រចាំឆ្នាំ ជំរុញឱ្យគ្រូអនុវត្តតាមក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន ផ្តល់ព័ត៌មានត្រឡប់ទៅគ្រូវិញ ដើម្បីស្តាបនានិងកែលម្អ។ ជំរុញឱ្យគ្រូស្រាវជ្រាវមេរៀន និងប្រជុំក្រុមបច្ចេកទេសឱ្យបានទៀងទាត់ រិះរកវិធីសាស្ត្របង្រៀន និងរៀនឱ្យមានប្រសិទ្ធភាព និងបន្តសហការទំនាក់ទំនងបុគ្គលិក សហគមន៍ និងភាគីពាក់ព័ន្ធ តាមឋានានុក្រម។ ត្រូវមានការអភិវឌ្ឍសមត្ថភាព និងការធ្វើអធិការកិច្ចផ្ទៃក្នុង ដើម្បីវាយតម្លៃចំណុចខ្លាំង និងចំណុចខ្វះខាត លើលទ្ធផលសិក្សា ការបង្រៀន និងវឌ្ឍនៈភាពការងារ ដើម្បីកែលម្អឱ្យមានប្រសិទ្ធភាព។

**ស្តង់ដាទី៦៖ ការផ្សារភ្ជាប់សាលារៀន ទៅនឹងសហគមន៍**

ដើម្បីឱ្យសាលារៀនមួយមានការរីកចម្រើន និងអភិវឌ្ឍន៍បានឆាប់រហ័ស ទាល់តែមានការចូលរួមពីសហគមន៍ អាជ្ញាធរ មាតាបិតា និងភាគីពាក់ព័ន្ធ។ វាជាកម្លាំងចលករមួយ ដែលរុញច្រាន និងធ្វើឱ្យសាលារៀនល្អ និងរីកចម្រើនលូតលាស់ខ្លាំងលើគ្រប់វិស័យ រួមមានបរិស្ថាន ហេដ្ឋារចនាសម្ព័ន្ធសម្ភារបរិក្ខារ គុណភាពបង្រៀននិងរៀន និងលទ្ធផលសិក្សារបស់សិស្ស។ កម្លាំងចលករទាំងអស់នេះបានបង្កើនទំនាក់ទំនងជិតស្និទ្ធក្នុងការដឹកនាំ សម្របសម្រួល និងកៀរគរធនធានពីប្រភពផ្សេងៗ មកអភិវឌ្ឍន៍សាលារៀន។ នាយកសាលាត្រូវកសាងទំនុកចិត្ត បង្កើនសមិទ្ធផល លទ្ធផលសិក្សាល្អ លះបង់ខ្ពស់ដោយមិនគិតការនឿយហត់។ ស្តាប់ និងទទួលយកនូវគំនិតយោបល់រិះគន់ ស្ថាបនាពីសហគមន៍ និងធ្វើឱ្យសាលារៀន និងសហគមន៍នៅជិតគ្នាជានិច្ច។

## ២.៣ ប្រសិទ្ធភាពនៃស្តង់ដាសាលាមធ្យមសិក្សា

សាលារៀនជាអង្គភាពទទួលខុសត្រូវក្នុងការអភិវឌ្ឍធនធានមនុស្ស ប្រកបដោយវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា និងកាយសម្បទា នៅថ្នាក់មូលដ្ឋាន។ ការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផលបានក្លាយជាវិធីសាស្ត្រពេញនិយមមួយនៅទសវត្សរ៍ចុងក្រោយនេះ តាមរយៈការធ្វើវិមជ្ឈការទៅឱ្យសាលារៀនក្នុងការស្វ័យសម្រេចចិត្ត ផ្អែកលើក្របខណ្ឌច្បាប់ គោលនយោបាយ ការណែនាំ និងគោលការណ៍ផ្សេងៗ ដែលបានចែងនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យអប់រំ។

យោងតាមសៀវភៅណែនាំប្រតិបត្តិស្តីពីការគ្រប់គ្រងសាលារៀនមធ្យមសិក្សា ឯកសារប្រតិបត្តិការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល គោលនយោបាយនិងនិតិវិធីគ្រប់គ្រងសាលារៀនឆ្នាំ២០១៧ និងស្តង់ដាសាលាមធ្យមចំណេះទូទៅ ស្តង់ដាសាលាមធ្យមសិក្សាមានចំនួន៩៖ ស្តង់ដាទី១ វត្ថុបំណងគោលនយោបាយសាលារៀន ស្តង់ដាទី២ ការបង្រៀននិងបំណែងចែកកម្មវិធីសិក្សា ស្តង់ដាទី៣ មាតាបិតា និងសហគមន៍ជួយដល់ការរៀនសូត្រ ស្តង់ដាទី៤ សិស្សនិងសេវាសិស្សជួយសិស្ស ស្តង់ដាទី៥ ការដឹកនាំនិងគ្រប់គ្រង ស្តង់ដាទី៦ ធនធានមនុស្ស ស្តង់ដាទី៧ សម្ភារៈបង្រៀននិងរៀន ស្តង់ដាទី៨ ហេដ្ឋារចនាសម្ព័ន្ធនិងបរិស្ថាន និងស្តង់ដាទី៩ ហិរញ្ញប្បទាននិងការគ្រប់គ្រងហិរញ្ញវត្ថុ។

### ២.៣.១ វត្ថុបំណងគោលនយោបាយសាលារៀន

នាយកសាលា ឬគណៈកម្មការគ្រប់គ្រងសាលារៀន មានតួនាទីរៀបចំផែនការចាត់ចែង ដឹកនាំ និងតាមដានការវាយតម្លៃដំណើរការអនុវត្តការគ្រប់គ្រងសាលារៀនឱ្យសម្រេចបាននូវចក្ខុវិស័យ បេសកម្ម និងគោលបំណង ក្នុងការឆ្លើយតបទៅនឹងគោលនយោបាយអប់រំ និងកំណែទម្រង់វិស័យអប់រំ ស្របទៅតាមផែនការយុទ្ធសាស្ត្រថ្នាក់ក្រសួង មន្ទីរ ការិយាល័យអប់រំក្រុងស្រុកខណ្ឌ និងត្រូវធានាថាលទ្ធផលសិក្សារបស់សិស្សមានការប្រែប្រួលជាវិជ្ជមាន ពិសេសលើការប្រមូលសិស្សចូលរៀនឱ្យបានគ្រប់ៗគ្នា កាត់បន្ថយអត្រាបោះបង់ និងត្រួតថ្នាក់ឱ្យនៅទាបបំផុត និងបង្កើនអត្រាឡើងថ្នាក់ប្រកបដោយគុណភាព ដោយមានការចូលរួមសហការជាមួយមាតាបិតាអាណាព្យាបាល និងសហគមន៍ផងដែរ (ការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល ឯកសារប្រតិបត្តិគោលនយោបាយ និងនិតិវិធីគ្រប់គ្រងសាលារៀន ២០១៧) (ក្រសួងអប់រំយុវជននិងកីឡា, ២០១៧)

### ២.៣.២ ការបង្រៀន និងបំណែងចែកកម្មវិធីសិក្សា

ការបង្រៀន គឺជាមាគ៌ាក្នុងការផ្តល់ចំណេះដឹងដល់សិស្ស តាមរយៈការប្រើប្រាស់វិធីសាស្ត្រ និងល្បិចផ្សេងៗ ដើម្បីឱ្យសិស្សមានការអភិវឌ្ឍផ្នែកបញ្ញា ស្មារតី និងរាងកាយ។ គ្រូបង្រៀនដែលមានប្រសិទ្ធភាព មិនមែនធ្វើអ្វីដោយគ្មានគោលបំណង និងផែនការច្បាស់លាស់នោះទេ ពោលគឺធ្វើអ្វីមួយ បង្រៀនអ្វីមួយ ត្រូវតែរៀបចំផែនការមេរៀនដែលត្រូវបង្រៀនប្រចាំឆ្នាំ ឆមាស ត្រីមាស និងសប្តាហ៍ ឱ្យបានច្បាស់លាស់។ ត្រូវត្រៀមសម្ភារៈឧបទេសគាំទ្រដល់ការបង្រៀន ត្រៀមសំណួរ និងត្រៀមឆ្លើយនូវរាល់ចម្ងល់របស់សិស្ស (ប្រាក់ពៅ ឃិនវណ្ណី បានកក្កដា, ២០១៩)។ ដើម្បីរៀបចំគម្រោងលំនាំនៃការបង្រៀន និងបំណែងចែកកម្មវិធីបង្រៀន ប្រកបដោយគុណភាព លុះត្រាតែគ្រូបង្រៀនស្វែងយល់ពីមុខងារ និងសារៈសំខាន់របស់សៀវភៅសិក្សា ស្តង់ដាកម្មវិធីសិក្សា ឯកសារកម្មវិធីសិក្សាលម្អិតដើម្បីប្រើប្រាស់ក្នុងការកំណត់ខ្លឹមសារមេរៀនសម្រាប់សិស្ស និងកំណត់លទ្ធផលរំពឹងទុកក្រោយពីបញ្ចប់មេរៀននេះចប់ ថាតើសិស្សនឹងទទួលបានអ្វី ចេះអ្វី និងយល់ដឹងអ្វី។ ចំណែកឯកម្មវិធីសិក្សាក្នុងប្រព័ន្ធមជ្ឈការ ត្រូវបានធ្វើនិងជ្រើសរើស

ដោយថ្នាក់ការិយាល័យកណ្តាល។ ក្នុងប្រព័ន្ធវិមជ្ឈការការគ្រប់គ្រងតាមសាលារៀន សាលារៀនត្រូវផ្តល់នូវវិធីសាស្ត្របង្រៀនថ្មីៗឱ្យគ្រូវទៅនឹងបរិបទក្នុងការអនុវត្តឱ្យមានប្រសិទ្ធភាព ។

### ២.៣.៣ មាតាបិតា និងសហគមន៍ជួយដល់ការរៀនសូត្រ

នៅតាមសាលារៀនមានការបង្កើតគណៈកម្មការផ្សេងៗ ក្នុងការទទួលអនុវត្តការងារឱ្យមានភាពច្បាស់លាស់ និងប្រកបដោយការទទួលខុសត្រូវ។ គណៈកម្មការមួយ ក្នុងចំណោមគណៈកម្មការទាំងនោះគឺគណៈកម្មការគ្រប់គ្រងថ្នាក់រៀន ឬគណៈកម្មការអភិវឌ្ឍន៍ថ្នាក់រៀន។ គណៈកម្មការនេះ ត្រូវបានបង្កើតឡើងក្នុងគោលបំណងពង្រឹងប្រសិទ្ធភាព នៃការសិក្សារបស់សិស្ស ដោយផ្សារភ្ជាប់ជាមួយនឹងឪពុកម្តាយ និងអ្នកអាណាព្យាបាលនៅតាមកម្រិតថ្នាក់នីមួយៗ។ គណៈកម្មការនេះ មានតួនាទី និងភារកិច្ចធ្វើសកម្មភាពទំនាក់ទំនងរវាងគ្រូបង្រៀន ជាមួយឪពុកម្តាយ និងអ្នកអាណាព្យាបាលសិស្ស ដើម្បីឱ្យគាត់ដឹងពីសុខទុក្ខនិងការសិក្សារបស់កូនៗ និងការបង្រៀនរបស់គ្រូ ហើយចូលរួមតាមដានជំរុញលើកទឹកចិត្តកូនៗឱ្យខិតខំប្រឹងប្រែងរៀនសូត្រទៀងទាត់ពេលវេលា ជួយក្រើនរំលឹកកូនៗឱ្យធ្វើកិច្ចការផ្ទះជាប្រចាំ ព្រមទាំងជួយអភិវឌ្ឍន៍ថ្នាក់រៀន ដោយការផ្តល់នូវសម្ភារៈ បច្ចេកទេស ធនធាន ព្រមទាំងថវិកា ធ្វើឱ្យបរិយាកាសសិក្សាក្នុងថ្នាក់រៀន មានផាសុខភាព និងអនាម័យ។ ការទំនាក់ទំនងរបស់គ្រូ និងមាតាបិតា អ្នកអាណាព្យាបាលសិស្សពិតជាមានសារៈសំខាន់ណាស់ ក្នុងការជួយដល់ការសិក្សារបស់សិស្សឱ្យទទួលបានលទ្ធផលល្អ លើគុណភាព ចំណេះដឹង ចំណេះធ្វើ សីលធម៌ និងចេះជួយគ្នាក្នុងថ្នាក់និងក្រៅថ្នាក់រៀន ហើយការទំនាក់ទំនងនេះនឹងធ្វើឱ្យមានភាពស្និទស្នាល រវាងគ្រូ និងមាតាបិតា ឬអាណាព្យាបាយសិស្ស និងអាចជួយទុក្ខធុរៈដល់គ្រូ និងសិស្សដែលជួបការលំបាកផ្សេងៗបានផងដែរ។ ប្រសិនបើមានកម្មវិធីអញ្ជើញឪពុកម្តាយ ឬអ្នកអាណាព្យាបាលសិស្សមកចូលរួមធ្វើថ្នាក់និទស្សន៍ ឬការអង្កេតថ្នាក់រៀនក្នុងម៉ោងបង្រៀនរបស់គ្រូ តាមកាលវិភាគ នឹងធ្វើឱ្យគ្រូបង្រៀនខិតខំពង្រឹងសមត្ថភាព និងវិធីសាស្ត្របង្រៀនឱ្យកាន់តែល្អ និងមានការប្រុងប្រយ័ត្ន។ កិច្ចការនេះគឺជាការចូលរួមចំណែកក្នុងការលើកស្ទួយការបង្រៀនរបស់គ្រូផងដែរ។ ចំណែកគណៈនាយកក៏ត្រូវខិតខំប្រឹងប្រែង បង្កើតស្នាដៃដើម្បីទទួលទំនុកចិត្តពីមាតាបិតា ជាពិសេសគឺទទួលបានមតិឬព័ត៌មានត្រឡប់នៅចំណុចខ្វះខាត សម្រាប់កែលម្អនៅពេលក្រោយ (ក្រសួងអប់រំយុវជន

និងកីឡា, ការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល ឯកសារប្រតិបត្តិ គណៈកម្មការអភិវឌ្ឍថ្នាក់រៀន, ២០១៧)។

### ២.៣.៤ សិស្ស និងសេវាជួយសិស្ស

ស្តង់ដាមួយនេះ តម្រូវឱ្យសាលារៀនរៀបចំក្រុមប្រឹក្សាកុមារ និងយុវជន ដើម្បីជួយធ្វើកិច្ចការផ្សេងៗពាក់ព័ន្ធកុមារ និងយុវជន នៅតាមសាលានីមួយៗ។ ក្រុមប្រឹក្សាកុមារ និងយុវជនដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយសិស្ស និងមិត្តជួយមិត្ត ចូលរួមសកម្មភាពនានានៅសាលា ដូចជាការងារក្លឹបសិក្សា វិន័យ បរិស្ថាន សុខភាព បញ្ហាគ្រឿងញៀន ចរាចរណ៍ បំណិនជីវិត សុជីវធម៌ សីលធម៌ ការទំនាក់ទំនងល្អក្នុងសាលារៀន និងសង្គម ស្វ័យសិក្សាក្នុងម៉ោងបណ្ណាល័យ នៅផ្ទះ ឬនៅទីកន្លែងផ្សេងៗ។ ក្រុមប្រឹក្សាកុមារ ឬយុវជនបានចូលរួមជំរុញចលនាប្រឡងប្រណាំងពីស្នាដៃមួយទៅស្នាដៃមួយទៀត ក្នុងការអភិវឌ្ឍចំណេះដឹង ឱ្យក្លាយខ្លួនជាកូនល្អ មិត្តល្អ សិស្សល្អ និងពលរដ្ឋល្អសម្រាប់សង្គមគ្រួសារ និងប្រទេសជាតិ។ ទំពាំងស្នងឫស្សី កូនប្រុសស្រីស្នងប្រទេសជាតិ។ ម្យ៉ាងវិញទៀត ក្រុមប្រឹក្សាកុមារ ឬយុវជន បានជួយគាំទ្រ និងលើកស្ទួយដល់សិទ្ធិសំខាន់ៗ របស់កុមារផងដែរ ដូចមានចែងក្នុងគោលការណ៍ និងខ្លឹមសារសំខាន់ៗ ដែលមានស្រាប់ក្នុងគោលនយោបាយ និងសេចក្តីណែនាំនានារបស់ក្រសួង។

សកម្មភាពសំខាន់ៗរបស់ក្រុមប្រឹក្សាកុមារ ឬយុវជន គឺផ្តើមចេញពីការជួយកុមារឱ្យមានសមត្ថភាពជួយខ្លួនឯង និងមិត្តភក្តិ សម្របសម្រួលជួយកុមារ ក្នុងការរៀនសូត្រ ទាំងនៅក្នុង និងក្រៅថ្នាក់។ មានសមត្ថភាពរាយការណ៍ទៅដល់សាលារៀន គ្រួសារ និងសហគមន៍ ចំពោះបញ្ហាដែលកើតមានឡើងទៅលើកុមារ និងអាចដោះស្រាយបញ្ហាដែលកើតឡើង ក្នុងន័យការពារសិទ្ធិ និងផលប្រយោជន៍ដែលពាក់ព័ន្ធនឹងកុមារ និងការរស់នៅប្រចាំថ្ងៃ (ក្រសួងអប់រំយុវជននិងកីឡា, ការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល ឯកសារប្រតិបត្តិ ក្រុមប្រឹក្សាយុវជននិងកីឡា, ២០១៧)។

### ២.៣.៥ ការដឹកនាំ និងគ្រប់គ្រង

ការងារគ្រប់គ្រង គឺជាកិច្ចដំណើរការសម្រេចការងារ តាមរយៈអ្នកក្រោមបង្គាប់។ ដូច្នេះអ្នកគ្រប់គ្រងគឺជាអ្នកទទួលខុសត្រូវ លើសកម្មភាពការងារ ហើយលទ្ធផលដែលទទួលបាន គឺបានតាមរយៈការខិតខំប្រឹងប្រែងរបស់មនុស្សក្រោមបង្គាប់ ឬមនុស្សគ្រប់ប្រភេទ មិនថាបុគ្គលម្នាក់ ឬក្រុមណាមួយឡើយ។ ការងារគ្រប់គ្រងសំដៅទៅលើសកម្មភាពខុសៗគ្នាជាច្រើន ដូចជាការងារគ្រប់គ្រងរបស់រាជរដ្ឋាភិបាលដឹកនាំប្រទេស ការគ្រប់គ្រងនិងដឹកនាំគ្រួសារ មេផ្ទះ ការគ្រប់គ្រងក្រុមហ៊ុន ឬស្ថាប័ននានា។ ការងារគ្រប់គ្រងទាំងនោះ មានភាពខុសគ្នា និងមានជំនាញផ្សេងពីគ្នាដែរ។ ការងារគ្រប់គ្រងគ្មានរូបមន្តងាយស្រួលណាមួយ ដែលក្រោយពីរៀនចេះទៅអាចជួយឱ្យអ្នកគ្រប់គ្រង អនុវត្តបានជោគជ័យគ្រប់ពេលវេលាហូតនោះទេ។ ការងារគ្រប់គ្រងគឺទាមទារឱ្យអ្នកគ្រប់គ្រងមានជំនាញច្រើន ហើយជំនាញណាដែលគួរត្រូវប្រើតាមកាលទេសៈសមស្របណាមួយ។ អ្នកគ្រប់គ្រងត្រូវស្វែងយល់ពីស្ថានភាពក្នុងនិងក្រៅអង្គភាព ព្រមទាំងវិធី និងបច្ចេកទេស ដើម្បីឆ្លើយតបទៅនឹងស្ថានភាពទាំងនេះ ក្នុងកាលទេសៈសមស្រប ( Spillance,J.P.,Halverson,R.,&Diamond,J.B, 2004 )។

ការដឹកនាំ និងគ្រប់គ្រងសាលារៀនប្រកបដោយប្រសិទ្ធភាព ទាមទារឱ្យនាយកសាលាប៉ិនប្រសព្វនិងមានជំនាញច្រើនក្នុងការយកមនុស្សមកប្រើតាមស្ថានភាពជាក់ស្តែងរបស់ខ្លួន ដើម្បីសម្រេចបាននូវចក្ខុវិស័យ បេសកម្ម និងគោលបំណងរបស់សាលារៀន។ កិច្ចការដែលត្រូវបំពេញមានការងារគ្រប់គ្រងរដ្ឋបាលសាលារៀន ការបង្កើតគណៈកម្មការផ្សេងៗ រដ្ឋបាលទីចាត់ការ អ្នកគ្រប់គ្រងស្ថិតិបុគ្គលិក គ្រូសិស្សថ្នាក់រៀន អគារសិក្សា សម្ភារៈ គ្រប់គ្រងការងារបុគ្គលិក ការធ្វើផែនការអភិវឌ្ឍន៍សាលារៀន ការគ្រប់គ្រងកិច្ចបញ្ជីការគណនេយ្យ និងហិរញ្ញវត្ថុ ការគ្រប់គ្រងការបង្រៀន និងរៀន ការគ្រប់គ្រងរបាយការណ៍ លិខិតស្នាមផ្សេងៗ និងការទំនាក់ទំនងជាមួយសហគមន៍ មាតាបិតា និងអាជ្ញាធរ ។ល។

សរុបមកការងារគ្រប់គ្រងអង្គភាព ឬស្ថាប័នមួយ ជាដំណើរការប្រើប្រាស់ធនធានមនុស្សសម្ភារៈថវិកា និងធនធានដ៏ទៃទៀតរបស់ខ្លួន ប្រើប្រាស់តាមរបៀបត្រឹមត្រូវមានប្រសិទ្ធភាព ប្រកបដោយភាពឆ្លាតវៃឆ្ពោះទៅសម្រេចបាននូវគោលដៅរបស់ខ្លួន ។

### ២.៣.៦ ធនធានមនុស្ស

ធនធានមនុស្សនៅតាមសាលារៀន គឺសំដៅទៅលើបុគ្គលិកអប់រំ ដែលមានគុណវុឌ្ឍិ។ គុណវុឌ្ឍិគ្រូ សំដៅទៅលើសញ្ញាបត្រជំនាញដែលទទួលបានការបណ្តុះបណ្តាលផ្លូវការពីក្រសួងអប់រំ យុវជន និងកីឡា ឬតាមស្ថាប័នបណ្តុះបណ្តាលដទៃទៀត អំពីវិធីសាស្ត្របង្រៀន គរុកោសល្យ ការគ្រប់គ្រងថ្នាក់រៀន ភាសាបរទេស បច្ចេកវិទ្យាព័ត៌មាន ទំនាក់ទំនង និងICT ដើម្បីអភិវឌ្ឍន៍សមត្ថភាពគ្រូបង្រៀន ឱ្យបានជោគជ័យ។ លោកគ្រូ អ្នកគ្រូ បានចូលរួមអភិឌ្ឍន៍សាលារៀន ក្រោយពីបានចូលរួមក្នុងកម្មវិធីនេះ ជាមួយនឹងនាយកសាលា ប្រកបដោយការទទួលខុសត្រូវ និងភាពជាម្ចាស់របស់គ្រូបង្រៀន ប្រធានក្រុមបច្ចេកទេស នាយកសាលា បានសិក្សានិងចែករំលែកចំណេះដឹងគ្នាទៅវិញទៅមក។

ក្រោមការដឹកនាំរបស់នាយកសាលា និងប្រធានក្រុមបច្ចេកទេស ត្រូវតែដឹងពីស្ថានភាពរបស់បុគ្គលិកអប់រំ កម្រិតសញ្ញាបត្រ មុខវិជ្ជាឯកទេស តាមកម្រិត តាមម៉ោងប្រចាំថ្ងៃ ប្រចាំសប្តាហ៍ និយាមនៃការប្រើប្រាស់បុគ្គលិក និងជាពិសេសសាមគ្គីភាពផ្ទៃក្នុងឱ្យបានល្អនឹងគ្នា ខិតខំធ្វើឱ្យសាលារៀនជាសាលាគម្រូសម្រាប់សិស្ស និងសហគមន៍ លើការផ្តល់សេវាអប់រំប្រកបដោយគុណភាព ជាការទាក់ទាញដល់សហគមន៍ មាតាបិតាសិស្ស ក្នុងមូលដ្ឋានជួយផ្តល់នូវធនធានបច្ចេកទេស សម្ភារៈ និងថវិកាដល់សាលារៀនឱ្យកាន់តែរីកចម្រើន។

ជារួម ធនធានមនុស្សជាធនធានយ៉ាងសំខាន់ ក្នុងចំណោមធនធានដទៃទៀត ក្នុងសាលារៀន។ សាលារៀនត្រូវការអភិឌ្ឍន៍ជំនាញវិជ្ជាជីវៈដល់បុគ្គលិករបស់ខ្លួនបើចង់ឱ្យពួកគេអនុវត្តការងារប្រកបដោយប្រសិទ្ធភាព (Cheng, 1996)។

### ២.៣.៧ សៀវភៅសិក្សាគោល និងសម្ភារបង្រៀន និងរៀន

តាមលទ្ធផលនៃការបូកសរុបរបាយការណ៍អធិការកិច្ច តាមប្រធានបទ ការគ្រប់គ្រង និងប្រើប្រាស់សៀវភៅសិក្សាគោល នៅសាលាបឋមសិក្សា និងរបាយការណ៍បូកសរុបថ្នាក់ជាតិ អធិការកិច្ចតាមកាលកំណត់ផ្នែកបឋមសិក្សានិងមធ្យមសិក្សាឃើញថា ការគ្រប់គ្រងនិងប្រើប្រាស់សៀវភៅសិក្សាគោលនៅមានភាពខ្វះខាត មិនទាន់បានផ្តល់ជូនគ្រប់គ្រាន់និងទាន់ពេលវេលានោះទេ ដោយសារខ្វះការគ្រប់គ្រង និង

ថែទាំ ផែនការតម្រូវការសៀវភៅច្បាស់លាស់ និងបែងចែកទាន់ពេលវេលា (នាយកដ្ឋានធានាគុណភាពអប់រំ, ២០១៩)។

បច្ចុប្បន្ន សៀវភៅសិក្សាគោលសម្រាប់សិស្ស និងគ្រូ ជាមធ្យោបាយមួយយ៉ាងសំខាន់ ក្នុងការគាំទ្រដល់ការបង្រៀន និងរៀននៅតាមសាលារៀន។ នៅប្រទេសកម្ពុជា មានការខ្វះខាតគ្រូបង្រៀនដែលបានទទួលការបណ្តុះបណ្តាលគ្រប់គ្រាន់លើវិធីសាស្ត្របង្រៀនថ្មីៗហើយសង្កត់ធ្ងន់ លើការរៀនបែបសកម្មច្រើន។ គ្រូបង្រៀនផ្តោតសំខាន់ទៅលើការទន្ទេញចាំមាត់។ លទ្ធផលសិក្សារបស់សិស្សមិនទាន់មានសមត្ថភាពផ្សារភ្ជាប់ទៅនឹងជីវភាពប្រចាំថ្ងៃ។ ការផ្លាស់ប្តូរនេះ ត្រូវការពេលវេលាវែង និងទាមទារឱ្យមានការកែលម្អកម្មវិធីសិក្សា និងការបណ្តុះបណ្តាលគ្រូលើវិធីសាស្ត្របង្រៀនថ្មីៗ។ ដើម្បីលើកកម្ពស់គុណភាពអប់រំនៅកម្រិតមូលដ្ឋាន និងមធ្យមសិក្សា ទាមទារឱ្យមានគុណភាពកម្មវិធីសិក្សា ដែលអាចផ្សារភ្ជាប់ទៅនឹងជីវភាពជាក់ស្តែង មានសៀវភៅសិក្សាគោលគ្រប់គ្រាន់សម្រាប់សិស្ស និងគ្រូបង្រៀន។ គ្រូបង្រៀនបានទទួលការបណ្តុះបណ្តាលវិធីសាស្ត្របង្រៀនថ្មីៗ មានគុណភាព មានសម្ភារឧបទេសគ្រប់គ្រាន់ មានបរិក្ខារបច្ចេកវិទ្យាICT មានលទ្ធភាពហិរញ្ញវត្ថុគាំទ្រដល់ដំណើរការរៀននិងបង្រៀន។ គ្រូបង្រៀនមានភាពជាពលរដ្ឋដែលមានគុណភាពក្នុងសតវត្សរ៍ទី២១។ គ្រូបង្រៀនត្រូវផ្លាស់ប្តូរវិធីសាស្ត្របង្រៀនតាមបែបទន្ទេញចាំមាត់(គ្រូមជ្ឈមណ្ឌល) មកជាការបង្រៀននិងរៀនបែបសកម្ម (សិស្សមជ្ឈមណ្ឌល)។ គ្រូបង្រៀនត្រូវរៀបចំរដ្ឋបាលរបស់ខ្លួនឱ្យបានគ្រប់គ្រាន់ ដូចជាកំណត់ត្រាប្រចាំថ្ងៃសម្រាប់ការបង្រៀននិងរៀនរបស់សិស្ស ត្រូវកិច្ចតែងការបង្រៀនថ្មីៗ មិនដដែលៗ និងមានការព្យាយាមកសាងនិងប្រើប្រាស់សម្ភារៈឧបទេសល្អៗ ដែលទាក់ទងនឹងខ្លឹមសារមេរៀន។ គ្រូបង្រៀនត្រូវធ្វើជាទីប្រឹក្សាសិស្សជំរុញការអានសៀវភៅ និងបង្កើតទម្លាប់នៃការអានជាគម្រូឱ្យសិស្ស និងគ្រូដទៃទៀត។ ជាមួយគ្នានេះដែរ សាលារៀនត្រូវប្តេជ្ញាចិត្តក្នុងការបង្កើត និងរៀបចំឱ្យមានបន្ទប់បណ្ណាល័យជាច់ដោយឡែកមួយប្រកបដោយស្តង់ដា ដែលមានបណ្ណារក្សទទួលការបណ្តុះបណ្តាលត្រឹមត្រូវ មានការគ្រប់គ្រង ថែរក្សា និងទប់ស្កាត់ការបាត់បង់សៀវភៅ។ បណ្ណាល័យត្រូវតែមានបរិយាកាសស្អាត មានអនាម័យ មានឯកសារស្រាវជ្រាវនានា និងថ្មីៗ

ច្រើន ដើម្បីទាក់ទាញឱ្យសិស្សចង់ចូល ចង់អានសៀវភៅ និងចង់ស្រាវជ្រាវបន្ថែម ក្នុងបណ្ណាល័យ តាមរយៈការបង្កើតទម្លាប់រៀនដោយខ្លួនឯង។

### ២.៣.៨ ហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានសាលារៀន

ហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានសាលារៀន គឺសំដៅទៅលើអគារសិក្សា បន្ទប់រៀន អគារទីចាត់ការ អគារបណ្ណាល័យ បន្ទប់ធនធានឬរោងជាង គ្រឿងសង្ហារឹម តុ ទូ កៅអីគ្រូ សិស្ស បរិក្ខារអប់រំមានកុំព្យូទ័រ ម៉ាស៊ីនថតចម្លង ម៉ាស៊ីនព្រីនធីរ ម៉ាញ៉េ ទូរស័ព្ទ និងទូរទស្សន៍។ល។ ហេដ្ឋារចនាសម្ព័ន្ធអនាម័យសាលារៀនមានបង្គន់ បន្ទប់ទឹក កន្លែងលាងដៃ ប្រព័ន្ធទឹកស្អាត ប្រភពទឹក ធុងចម្រោះទឹក ស្រះ ស្រពាំង អណ្តូង និងឡដុតសំរាម។ ហេដ្ឋារចនាសម្ព័ន្ធសុវត្ថិភាពសាលារៀន មានរបងសាលារៀន កន្លែងចតកង់ម៉ូតូឡាន ស្លាកសញ្ញាផ្សេងៗ ប្រព័ន្ធការពារអគ្គីភ័យ។ បរិស្ថានផ្នែកធម្មជាតិ សួនច្បារ ដើមឈើ សួនបំណិនជីវិត សួនជីវចម្រុះ ដាំណាំ បន្លែ ឈើហូបផ្លែ។ល។ បច្ចុប្បន្ននេះ យើងសង្កេតឃើញថា ក្រសួងអប់រំ យុវជន និងកីឡា ដៃគូអភិវឌ្ឍន៍ សប្បុរសជន ក្នុង និងក្រៅប្រទេស បានយកចិត្តទុកដាក់យ៉ាងខ្លាំងក្លា ក្នុងការខិតខំប្រឹងប្រែង បង្កើនវិស័យអប់រំ ផ្នែកហេដ្ឋារចនាសម្ព័ន្ធនិងបរិស្ថានសាលារៀន ដើម្បីឆ្លើយតបទៅនឹងផែនការយុទ្ធសាស្ត្រវិស័យអប់រំ។

### ២.៣.៩ ហិរញ្ញប្បទាន និងការគ្រប់គ្រងហិរញ្ញវត្ថុ

ដើម្បីធានាឱ្យការគ្រប់គ្រងហិរញ្ញវត្ថុ និងការគ្រប់គ្រងថវិកាសាលារៀនប្រកបដោយប្រសិទ្ធភាព និងតម្លាភាព ក្រសួងអប់រំ យុវជន និងកីឡាបានចេញកម្មវិធីកំណែទម្រង់លើការគ្រប់គ្រងហិរញ្ញវត្ថុ និងបានជួយគាំទ្រដល់សាលារៀនក្នុងការគ្រប់គ្រងថវិកា។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏បានចេញនូវគោលការណ៍ចំណាយមួយចំនួនសម្រាប់អនុវត្តមូលនិធិដំណើរការសាលារៀនសាធារណៈ សាលាគរុកោសល្យ និងវិក្រឹតការខេត្ត និងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តចាប់ពីឆ្នាំ២០១៩តទៅ។ សាលារៀនត្រូវរៀបចំឱ្យមានគណៈកម្មការគ្រប់គ្រងថវិកាដំណើរសាលារៀន ដោយបែងចែកតួនាទី និងភារកិច្ចទទួលខុសត្រូវ ក្នុងការប្រើប្រាស់ និងចំណាយតាមគោលការណ៍ ប្រកបដោយប្រសិទ្ធភាព។ ការគ្រប់គ្រងថវិកា

នៅតាមសាលា ចាំបាច់ទាមទារ ឱ្យមានការចូលរួមចំណែកពីភាគីពាក់ព័ន្ធសំខាន់ៗ ទាក់ទងលើមុខចំណាយនានា ដើម្បីឱ្យសាលារៀនអាចដោះស្រាយនូវរាល់បញ្ហានានា សំដៅជានាឱ្យការអប់រំមានប្រសិទ្ធភាព និងគុណភាព ។ សាលារៀនត្រូវតែបង្ហាញពីតម្លាភាព គណនេយ្យភាព និងការចូលរួម ដើម្បីបង្កើនភាពជឿទុកចិត្ត ពីភាគីពាក់ព័ន្ធទាំងអស់ ដូចជាសហគមន៍ មាតាបិតា អ្នកអាណាព្យាបាល អាជ្ញាធរ និងរួមគ្នាអភិវឌ្ឍន៍សាលារៀនក្នុងមូលដ្ឋាន ឱ្យកាន់តែរីកចម្រើនឆាប់រហ័ស ឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាជនក្នុងមូលដ្ឋានផងដែរ។

## ២.៤. បទពិសោធនៃការគ្រប់គ្រងផ្អែកលើលទ្ធផល និងការចូលរួម នៅប្រទេសនានា

តាមរយៈការសិក្សាស្រាវជ្រាវមួយចំនួននៅសហរដ្ឋអាមេរិក ក្នុងឆ្នាំ១៩៨៥ ការគ្រប់គ្រងផ្អែកលើលទ្ធផល ឬការគ្រប់គ្រងតាមសាលារៀន គឺសំដៅទៅលើមូលដ្ឋានគ្រឹះនៃការធ្វើប្រតិភូកម្មរចនាសម្ព័ន្ធចាត់តាំងគ្រប់គ្រងវិមជ្ឈការអំណាចនិងការសម្រេចចិត្តដែលធ្វើឡើងពីថ្នាក់ជាតិ ក្រុមប្រឹក្សាសាលាស្រុក ផ្ទេរទៅឱ្យគ្រូ នាយកសាលា ឪពុកម្តាយ និងសហគមន៍មូលដ្ឋាន (Lindquist and Maurie, 1989)។ យោងតាមការស្រាវជ្រាវនេះ ការគ្រប់គ្រងតាមសាលារៀន គឺសង្កត់ធ្ងន់លើសារៈសំខាន់នៃក្រុមដែលដើរតួនាទីក្នុងការអនុវត្តការគ្រប់គ្រងតាមសាលារៀន។ ក្រុមទាំងនោះមាន នាយកសាលា គ្រូបង្រៀនសិស្សានុសិស្ស ឪពុកម្តាយ និងសហគមន៍មូលដ្ឋាន ក្នុងការចូលរួមសកម្មភាពល្អក្នុងការសម្រេចចិត្តលើការគ្រប់គ្រងសាលារៀនឱ្យដំណើរការល្អ និងជោគជ័យ។ លោក (Daniel J. Brown, 1990) បានបញ្ជាក់ថា នាយកសាលា គ្រូ និងឪពុកម្តាយ សិស្ស ដើរតួជាយន្តការជាក់ស្តែងក្នុងដំណើរការគ្រប់គ្រងតាមសាលារៀន។ ពួកគេចូលរួមគ្រប់សកម្មភាពរបស់សាលារៀន ដើម្បីធ្វើការសម្រេចចិត្តតាមរយៈការធ្វើប្រតិភូកម្មអំណាចដល់ថ្នាក់មូលដ្ឋាន និងដល់ក្រុមដែលពាក់ព័ន្ធ។ ការគ្រប់គ្រងតាមសាលារៀន ជាប្រភពនៃការតស៊ូមតិ សម្រាប់វិមជ្ឈការ។ ការលើកឡើងគឺថា ដំណើរការនេះ ត្រូវការការយល់ព្រមយ៉ាងច្រើនពីប្រព័ន្ធគ្រប់គ្រងដោយអភិបាលស្រុកខេត្ត។ ចំណែកឯលោក Marburger មិនយល់ស្របទៅនឹងការលើកឡើងនេះទេ គាត់បានអះអាងថា ការគ្រប់គ្រងតាមសាលារៀន គឺជាការធ្វើការសម្រេចចិត្តរួមគ្នា ដែលគ្រូបង្រៀនឪពុកម្តាយនិង

សិស្សអាចមានសម្លេងពិតនៅក្នុងការគ្រប់គ្រងសាលារៀន។ ប៉ុន្តែការសម្រេចចិត្តរបស់ពួកគេតែងតែមានការយល់ព្រមពីគណៈនាយក ។

ចំពោះកណីរសិក្សា ការអនុវត្តការគ្រប់គ្រងតាមសាលារៀនរបស់ប្រទេសឥណ្ឌូនេស៊ី ក្នុងរបាយការណ៍ស្តីពីការកំណត់នូវកត្តាដែលទាក់ទងនឹងការអនុវត្តជោគជ័យ និងផលប៉ះពាល់នៃការអនុវត្តការគ្រប់គ្រងតាមសាលារៀនក្នុងរយៈពេល៨ឆ្នាំបន្ទាប់ពីការចាប់ផ្តើម ហើយតាមរយៈការស្ទាបស្ទង់មតិរបស់នាយកសាលា គ្រូបង្រៀន សមាជិកគណៈកម្មការសាលារៀន ឪពុកម្តាយ បុគ្គលិកអប់រំ យុវជន និងកីឡាស្រុក តម្រូវឱ្យមានការផ្លាស់ប្តូរដ៏ធំមួយ នៅក្នុងរបៀបដែលមនុស្សគិតអំពីការសិក្សានិងការធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពនាយក គ្រូបង្រៀន និងសហគមន៍ ដើម្បីផ្តល់ភាពជាអ្នកដឹកនាំអភិឌ្ឍន៍ជម្រើសកម្មវិធីសិក្សា ដើម្បីឆ្លើយតបទៅនឹងតម្រូវការអប់រំក្នុងតំបន់ និងចូលរួមជាមួយឪពុកម្តាយ និងសហគមន៍ក្នុងអភិបាលកិច្ចសាលារៀន។ រហូតមកដល់ពេលនេះ ការអនុវត្តការគ្រប់គ្រងតាមសាលារៀន បានទទួលជោគជ័យនៅមានកម្រិត។ ទោះបីជានាយកសាលាភាគច្រើនបានរាយការណ៍ថា ពួកគេមានស្វ័យភាព ក្នុងការសម្រេចចិត្ត ប៉ុន្តែសាលារៀនពួកគេមិនបានទាញយកផលប្រយោជន៍ពីនេះ ដោយធ្វើការផ្លាស់ប្តូរកម្មវិធីនិងការណែនាំសំខាន់ៗនោះទេ។ ការចូលរួមរបស់ពួកគេនៅតិចតួចនៅឡើយ ដោយសារពួកគេបានបង្ហាញអាកប្បកិរិយាមិនជ្រៀតជ្រែកជាមួយកិច្ចការសាលា និងមិនគោរពដល់បុគ្គលិកសាលា។ អ្នកពាក់ព័ន្ធនៅថ្នាក់សាលារៀនទាំងអស់ មិនបានត្រៀមលក្ខណៈគ្រប់គ្រាន់ ដើម្បីផ្តល់ភាពជាអ្នកដឹកនាំប្រកបដោយប្រសិទ្ធភាព។ ការកែលម្អការអនុវត្ត និងលទ្ធផលការគ្រប់គ្រងតាមសាលារៀននៅក្នុងប្រទេសនេះ នឹងតម្រូវឱ្យមានសមត្ថភាព ទាំងសមាជិក នាយកសាលា គ្រូ គណៈកម្មការ និងបង្កើនសមត្ថភាពដើម្បីធ្វើការផ្លាស់ប្តូរ ក្នុងការគាំទ្រការប្រតិបត្តិការគ្រប់គ្រងតាមសាលារៀន។ នៅប្រទេសអូស្ត្រាលី បានអនុវត្តប្រព័ន្ធគ្រប់គ្រងតាមសាលារៀន តាំងពីឆ្នាំ១៩៧៤, ប្រទេសអេស្បាញ ១៩៨៥ ,ចក្រភពអង់គ្លេស ១៩៨៨, ប្រទេសញ៉ូហ្សេឡែន ១៩៨៩, អាព្រិចខាងត្បូង ១៩៩៦, ប្រទេសថៃ ១៩៩៩, ហុងកុង ២០០១, ឥណ្ឌូនេស៊ី២០០៣។

## ២.៥ កត្តាចាំបាច់សម្រាប់អនុវត្តការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផលនៅកម្ពុជា

ក្រសួងអប់រំ យុវជន និងកីឡា បានបង្ហាញនូវការប្តេជ្ញាចិត្តក្នុងការកែលម្អវិស័យអប់រំតាមរយៈកំណែទម្រង់ស៊ីជម្រៅក្នុងវិស័យអប់រំ ។ ក្នុងផែនការយុទ្ធសាស្រ្តវិស័យអប់រំ ESP ២០០៦-២០០៩ និង ២០១០-២០១៣ ផ្តោតទៅលើគោលនយោបាយសំខាន់បីគឺ (១) ការទទួលបានសេវាអប់រំប្រកបដោយសមធម៌ (២) គុណភាពនិងប្រសិទ្ធភាពនៃសេវាអប់រំ (៣) ការអភិវឌ្ឍស្ថាប័ន និងកសាងសមត្ថភាពសម្រាប់វិមជ្ឈការ។ កំណែទម្រង់ការអប់រំត្រូវបានចាប់ផ្តើមដោយជំនួយពីដៃគូអភិវឌ្ឍន៍ និងទីភ្នាក់ងារអន្តរជាតិនានា។ ធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ីបានដើរតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រដំណើរការនៃការបង្កើតគោលនយោបាយ។

ការអនុវត្តការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល ឬការគ្រប់គ្រងតាមសាលារៀនមានគោលបំណងសំដៅទៅ (១) កែលម្អការអប់រំប្រកបដោយគុណភាព (២) ពង្រីកលទ្ធភាពទទួលបានការអប់រំតាមរយៈការលុបបំបាត់ចោលគោលនយោបាយឆ្នាំសិក្សាបង់ថ្លៃ (៣) លើកកម្ពស់វិធីសាស្រ្តក្នុងការធ្វើសេចក្តីសម្រេចចិត្ត ដោយផ្តល់សិទ្ធិដល់អាជ្ញាធរ និងអ្នកពាក់ព័ន្ធនានាក្នុងមូលដ្ឋាន ដើម្បីធ្វើសេចក្តីសម្រេចចិត្ត និង (៤) បង្កើនប្រសិទ្ធភាព នៃការគ្រប់គ្រងថវិកានៅសាលារៀន។ នៅក្នុងការអនុវត្តការគ្រប់គ្រងតាមសាលារៀន ការសម្រេចចិត្តនានា ត្រូវមានការចូលរួមពីគណៈកម្មាធិការគាំទ្រសាលារៀនដែល មានសមាសភាព ដូចជា (១) គណៈកម្មការទ្រទ្រង់សាលា តំណាងសហគមន៍ អាជ្ញាធរមូលដ្ឋាន មេភូមិ និងចៅសង្កាត់ (២) នាយកសាលា (៣) គណនេយ្យករ (៤) ហិរញ្ញិក និង (៥) ប្រធានក្រុមបច្ចេកទេស។ មុខងារ និងតួនាទី របស់គណៈកម្មាធិការរួមមាន៖ការបង្កើតការចុះឈ្មោះចូលរៀនរបស់សិស្ស យុទ្ធនាការអប់រំ ប្រមូលសិស្សចូលរៀន លើកទឹកចិត្តឪពុកម្តាយចូលរួម កៀរគរប្រាក់ចំណូល មូលនិធិ សម្រាប់កសាងហេរដ្ឋារចនាសម្ព័ន្ធ ការសាងសង់ផ្សេងៗ និងការតាមដានការសិក្សារបស់សិស្សជាដើម។

កត្តាបួនយ៉ាងដែលបានចូលរួមចំណែកដល់ការអនុវត្តការគ្រប់គ្រងសាលាផ្អែកលើលទ្ធផល ឬការគ្រប់គ្រងតាមសាលារៀននៅក្នុងប្រទេសកម្ពុជា រួមមានសមាសភាពគណៈកម្មាធិការ ដែលមានសិទ្ធិធ្វើសេចក្តីសម្រេចចិត្តកាន់តែធំ ចំពោះសាលារៀន ក្នុងស្រុក និងសហគមន៍របស់ពួកគេ ព្រោះពួកគេដោះ

ស្រាយដោយផ្ទាល់ ដើម្បីធ្វើឱ្យប្រសើរឡើងក្នុងការផ្តល់សេវាអប់រំប្រសើរដោយផ្តោតទៅលើតម្រូវការរបស់សិស្ស និងធ្វើឱ្យសាលារៀនប្រើប្រាស់ធនធាននានាមានប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព (២) ការបែងចែកធនធាន និងមូលនិធិសាលារៀន សាធារណៈដោយរដ្ឋាភិបាល ផ្អែកលើយន្តការផ្តល់ធនធានស្មើគ្នានិងស្មើភាព និងការផ្តល់នូវសិទ្ធអំណាចដល់សាលារៀនកាន់តែធំក្នុងការគ្រប់គ្រង និងមានភាពបត់បែនចំពោះការប្រើប្រាស់ថវិកា និងធនធាន។ នាយកដ្ឋានកណ្តាលចាំបាច់ត្រូវធ្វើការផ្លាស់ប្តូរតួនាទីរបស់ខ្លួនពីអ្នកដឹកនាំ ទៅជាអ្នកសម្របសម្រួល គាំទ្រ និងជាទីប្រឹក្សា ដើម្បីធានាថាច្បាប់និងគោលនយោបាយអប់រំ ចាំបាច់ប្រើក្នុងប្រព័ន្ធអប់រំថ្មីត្រូវបានអនុម័ត (៣) ពាក់ព័ន្ធនឹងការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស ការបណ្តុះបណ្តាលអភិវឌ្ឍវិជ្ជាជីវៈ ឱ្យមានសមត្ថភាពក្នុងការអនុវត្ត សម្រេចបានតាមផែនការ។ (៤) ការចូលរួមប្រាស្រ័យទាក់ទង ដើម្បីឱ្យសាលារៀន សហគមន៍នៅជិតគ្នា សម្រាប់ចូលរួមចំណែកក្នុងការផ្តល់ធនធាន សម្ភារៈ ថវិកា និងបច្ចេកទេស ក្នុងការធ្វើអភិបាលកិច្ចសាលារៀនឱ្យមានប្រសិទ្ធភាព (MONO, 2029)។

# ជំពូកទី ៣
# វិធីសាស្ត្រស្រាវជ្រាវ

# ជំពូកទី៣
# វិធីសាស្រ្តស្រាវជ្រាវ

## ៣.១ ព័ត៌មានទូទៅនៃគម្រោងស្រាវជ្រាវ

ការស្រាវជ្រាវនេះត្រូវបានសិក្សាតាមវិធីសាស្ត្របែបបរិមាណវិស័យ និងគុណវិស័យ ដែលបានយកមកវិភាគ ដើម្បីស្វែងយល់ពីប្រសិទ្ធភាពនៃការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល នៅមធ្យមសិក្សានៅតាមគ្រឹះស្ថានសិក្សាដែលជាគោលដៅនៃការស្រាវជ្រាវលើប្រធានបទនេះ។ កម្រងសំណួរចំនួនបួនប្រភេទ ត្រូវបានបង្កើតឡើងផ្សេងៗគ្នា សម្រាប់នាយកសាលា សហគមន៍និងគណៈកម្មការទ្រទ្រង់/គ្រប់គ្រងសាលារៀន គ្រូ សិស្ស។

## ៣. ២ ទីកន្លែងសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះជ្រើសរើសយករាជធានីភ្នំពេញជាទីតាំងសម្រាប់ធ្វើការស្រាវជ្រាវដើម្បីប្រមូលទិន្នន័យ។ សាលាគោលដៅមានចំនួន១២សាលា (វិទ្យាល័យ៦ អនុវិទ្យាល័យ៦)ក្នុងខណ្ឌចំនួន៦ក្នុងចំណោមខណ្ឌទាំង១៤ ក្នុងការគ្រប់គ្រងសាលារៀនប្រកបដោយប្រសិទ្ធភាពផ្អែកលើលទ្ធផលត្រូវបានលើកយកមកសិក្សា។ ដូចបានរៀបរាប់ក្នុងជំពូកទី១ខាងលើ ការស្រាវជ្រាវនេះ មានគោលបំណងសំខាន់ចំនួន២គឺ៖ (១) ស្ថានភាពបច្ចុប្បន្ននៃដំណើរការគ្រប់គ្រងសាលារៀនមធ្យមសិក្សា ក្រៅពីសាលាជំនាន់ថ្មី សាលាធនធាន និងសាលាគម្រោងSIEPពិសេសលើការអនុវត្តស្តង់ដាសាលាមធ្យមសិក្សាចំណោះទូទៅទាំង៩ (២) រកឱ្យឃើញនូវបញ្ហាប្រឈមនានា ក្នុងដំណើរការគ្រប់គ្រងសាលារៀនប្រកបដោយគុណភាពផ្អែកលើលទ្ធផល នៃការដឹកនាំនិងគ្រប់គ្រងរបស់នាយកសាលា ការរៀននិងបង្រៀនរបស់គ្រូ លទ្ធផលសិក្សារបស់សិស្ស និងការចូលរួមរបស់សហគមន៍មាតាបិតាអាណាព្យាបាល និងអាជ្ញាធរ។

ដើម្បីសម្រេចនូវគោលបំណងខាងលើនេះ អ្នកស្រាវជ្រាវបានប្រើវិធីសាស្ត្រស្រាវជ្រាវបែបបរិមាណវិស័យ និងគុណវិស័យ ដោយផ្អែកទៅលើព័ត៌មានផ្ទាល់ខ្លួន ភេទ អាយុ កម្រិតនៃការអប់រំ កម្រិតវិជ្ជាជីវៈ បទពិសោធ រួមផ្សំជាមួយនឹងព័ត៌មានពីការអង្កេតផ្ទាល់របស់អ្នកសិក្សាស្រាវជ្រាវទៅលើស្ថានភាពជាក់

ស្តែងរបស់សាលាគោលដៅទាំងនោះ។ ម្យ៉ាងវិញទៀត ទីកន្លែងដែលធ្វើការស្រាវជ្រាវនេះ ក៏ជាទីតាំងដែលអ្នកស្រាវជ្រាវកំពុងរស់នៅផងដែរ។

## ៣.៣ ការជ្រើសរើសសំណាក

ក្នុងការសិក្សាស្រាវជ្រាវប្រធានបទខាងលើនេះ អ្នកសិក្សាស្រាវជ្រាវបានជ្រើសរើស នាយកសាលា/នាយិកា ១២នាក់ លោកគ្រូអ្នកគ្រូ១១៩នាក់ សិស្សានុសិស្ស១៧១នាក់ គណៈកម្មការទ្រទ្រង់សាលា/គណៈកម្មការគ្រប់គ្រងសាលា/សហគមន៍១៨នាក់ ចេញពីសាលារៀនមធ្យមសិក្សាចំនួន១២ (វិទ្យាល័យ៦ អនុវិទ្យាល័យ៦)ក្នុងខណ្ឌចំនួន៦ប៉ុណ្ណោះ។ ក្នុងរាជធានីភ្នំពេញ មានខណ្ឌចំនួន១៤ មានវិទ្យាល័យចំនួន៤១សាលា ក្នុងនោះ (សាលាជំនាន់ថ្មី២ សាលាបច្ចេកទេស១ វិទ្យាល័យអប់រំពិសេស២ សាលាធនធាន២ វិទ្យាល័យ៧ អនុវត្តគម្រោងកែលម្អសាលារៀនSIEP) និងអនុវិទ្យាល័យចំនួន២៧ សរុបសាលាមធ្យមសិក្សាចំនួន៦៨សាលា។ ក្នុងនោះដែរអ្នកសិក្សាស្រាវជ្រាវបានជ្រើសរើស១២សាលាក្នុងចំណោមសាលា៥៤។ មូលហេតុអ្នកសិក្សាស្រាវជ្រាវជ្រើសរើសសាលា១២នេះគឺដើម្បីធ្វើការប្រៀបធៀប លើផ្នែកមួយចំនួននៃប្រសិទ្ធភាពគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល ធៀបនឹងស្តង់ដាសាលារៀនមានប្រសិទ្ធភាព ដោយផ្តោតទៅលើ ៤ ចំណុចៈ ១.ការដឹកនាំនិងគ្រប់គ្រងរបស់នាយកសាលា (ការគ្រប់គ្រងរដ្ឋបាល ការគ្រប់គ្រងហិរញ្ញវត្ថុ និងផែនការកែលម្អសាលារៀន) ២.ការបង្រៀននិងការរៀន (ការគ្រប់គ្រងការរៀននិងបង្រៀន និងការអនុវត្តកម្មវិធីសិក្សា) ៣.លទ្ធផលសិក្សារបស់សិស្ស (តេស្តវាយតម្លៃការសិក្សារបស់សិស្ស) ៤.ការចូលរួមរបស់សហគមន៍ មាតាបិតាសិស្ស (ការចូលរួមនិងតួនាទីរបស់គណៈកម្មការគ្រប់គ្រងសាលារៀន) និងស្តង់ដាទាំង៩ស្តីពីសាលារៀនប្រសិទ្ធភាពនៅមធ្យមសិក្សា ដែលត្រូវយកមកធ្វើការរៀបចំកម្រងសំណួរនិងសម្ភាសន៍ និងផ្ទៀងផ្ទាត់គ្នា ថាតើភាគសំណាកទាំងអស់ខាងលើមានលក្ខណៈត្រឹមត្រូវសុក្រិតកម្រិតណា។

តារាងទី១៖សំណាកសម្រាប់ស្រាវជ្រាវ

| សំណាកសម្រាប់ការស្រាវជ្រាវ |
| --- |

| ល.រ | ក្រុមគោលដៅ | ចំនួនអ្នកចូលរួម | ផ្សេងៗ |
|---|---|---|---|
| ០១ | នាយកសាលា | ១២ | |
| ០២ | គ្រូបង្រៀន | ១១៩ | |
| ០៣ | សិស្សានុសិស្ស | ១៧១ | |
| ០៤ | សហគមន៍ និងគណៈកម្មការទ្រទ្រង់/គ្រប់គ្រងសាលារៀន | ១៨ | |

## ៣.៤ ឧបករណ៍នៃការស្រាវជ្រាវ

ការប្រមូលទិន្នន័យរបស់អ្នកសិក្សាស្រាវជ្រាវ បានផ្តល់អត្ថប្រយោជន៍ដល់ការស្រាវជ្រាវ របស់ខ្លួន។ ដើម្បីប្រមូលទិន្នន័យឱ្យបានជាក់លាក់ អ្នកសិក្សាស្រាវជ្រាវត្រូវបង្កើតឧបករណ៍សម្រាប់ប្រមូលទិន្នន័យ ដោយការរៀបចំបង្កើតនូវកម្រងសំណួរដែលមានលក្ខណៈកម្រិតចម្លើយ និងសំណួរទម្រង់បើកសម្រាប់នាយកសាលា លោកគ្រូអ្នកគ្រូ សិស្សានុសិស្ស សហគមន៍និងគណៈកម្មការទ្រទ្រង់/គ្រប់គ្រងសាលារៀន។ កម្រងសំណួរក៏ត្រូវធ្វើបួនប្រភេទ ដើម្បីប្រមូលទិន្នន័យរួមមាន កម្រងសំណួរសម្រាប់នាយកសាលាមាន១២ច្បាប់ កម្រងសំណួរសម្រាប់គ្រូបង្រៀនមាន១០៨ច្បាប់ កម្រងសំណួរសម្រាប់សិស្សមាន ១៨០ច្បាប់ កម្រងសំណួរសម្រាប់សហគមន៍និងគណៈកម្មការទ្រង់ទ្រង/គ្រប់គ្រងសាលាមាន១៨ច្បាប់ សរុបទាំងអស់៣៣៩ច្បាប់។ ខ្លឹមសារនៃកម្រងសំណួរផ្តោតលើការគ្រប់គ្រងសាលារៀនប្រកបដោយប្រសិទ្ធភាពលើ ៤ចំណុច និងតាមស្តង់ដាសាលារៀនមានប្រសិទ្ធភាពទាំង៩។

## ៣.៥ កម្រងសំណួរ និងគោលបំណងនៃកម្រងសំណួរ

កម្រងសំណួរសម្រាប់ប្រមូលទិន្នន័យ អ្នកសិក្សាស្រាវជ្រាវបានដៅក្រុមគោលដៅចំនួន៤ក្រុម ៖នាយកសាលា លោកគ្រូអ្នកគ្រូ សិស្សានុសិស្ស និងសហគមន៍និងគណៈកម្មការទ្រទ្រង់/គ្រប់គ្រងសាលារៀន ។

### ៣.៥.១ កម្រងសំណួរសម្រាប់នាយកសាលា

កម្រងសំណួរនេះ មាន២គឺកម្រងសំណួរបិទ និងកម្រងសំណួរសម្រាប់សម្ភាសន៍។

៣.៥.១.១-កម្រងសំណួរបិទមានមាន២ផ្នែក៖ ផ្នែកទី១៖ព័ត៌មានប្រជាសាស្ត្រ ឈ្មោះសាលា ព័ត៌មានផ្ទាល់ខ្លួន កម្រិតវប្បធម៌ អាយុ ភេទ បទពិសោធការងារអ្នកបំពេញ។កម្រងសំណួរនេះមិនត្រូវបានយកមកវិភាគទេ ដោយអ្នកសិក្សាគ្រាន់តែចង់ដឹងព័ត៌មានប៉ុណ្ណោះ។ ផ្នែកទី២៖ ប្រសិទ្ធភាពនៃការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផលទាក់ទងនឹងការគ្រប់គ្រងរបស់នាយកសាលា ថាតើមានប្រសិទ្ធភាពកម្រិតណាទាក់ទងនឹង (១) វត្ថុបំណងគោនយោបាយសាលារៀន (២) ការដឹកនាំនិងគ្រប់គ្រងសាលារៀន (៣) ធនធានមនុស្ស (៤) សៀវភៅសិក្សាគោល និងសម្ភារបង្រៀននិងរៀន (៥) ហេដ្ឋារចនាសម្ព័ន្ធនិងបរិស្ថានសាលារៀន (៦) ហិរញ្ញប្បទាន និងការគ្រប់គ្រងហិរញ្ញវត្ថុ។

៣.៥.១.២-កម្រងសំណួរសម្រាប់សម្ភាសន៍គឺវាស់ស្ទង់ពីមតិផ្ទាល់របស់នាយកសាលា លើការគ្រប់គ្រងសាលា ធៀបនឹងស្តង់ដាសាលាមានប្រសិទ្ធភាព។

### ៣.៥.២ កម្រងសំណួរសម្រាប់គ្រូ

កម្រងសំណួរសម្រាប់គ្រូមាន២ ជាកម្រងសំណួរបិទ និងកម្រងសំណួរសម្រាប់សម្ភាសន៍។

៣.៥.២.១-កម្រងសំណួរបិទមានមាន២ផ្នែក៖ ផ្នែកទី១៖ព័ត៌មានប្រជាសាស្ត្រ ឈ្មោះសាលា ព័ត៌មានផ្ទាល់ខ្លួន កម្រិតវប្បធម៌ អាយុ ភេទ បទពិសោធការងារអ្នកបំពេញ។ ផ្នែកទី២៖ ប្រសិទ្ធភាពនៃការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផលទាក់ទងនឹងការបង្រៀននិងរៀន តើមានប្រសិទ្ធភាពកម្រិតណា។

៣.៥.២.២-កម្រងសំណួរសម្រាប់សម្ភាសន៍គឺវាស់ស្ទង់ពីមតិផ្ទាល់របស់គ្រូ លើការបង្រៀននិងរៀន ធៀបនឹងស្តង់ដាសាលាមានប្រសិទ្ធភាព។

### ៣.៥.៣ កម្រងសំណួរសម្រាប់សិស្សានុសិស្ស

កម្រងសំណួរសម្រាប់សិស្សមាន២ ជាកម្រងសំណួរបិទនិងកម្រងសំណួរសម្រាប់សម្ភាសន៍។

៣.៥.៣.១-កម្រងសំណួរបិទមាន២ផ្នែក៖ ផ្នែកទី១៖ ឈ្មោះសាលា ព័ត៌មានផ្ទាល់ខ្លួន ភេទ បទពិសោធការងារអ្នកបំពេញ។ ផ្នែកទី២៖ ប្រសិទ្ធភាពនៃការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផលទាក់ទងនឹងសិស្សនិងសេវាជួយសិស្ស។

៣.៥.២.២-កម្រងសំណួរសម្រាប់សម្ភាសន៍គឺវាស់ស្ទង់ពីមតិផ្ទាល់របស់សិស្ស លើការគ្រប់គ្រងសាលា ធៀបនឹងស្តង់ដាសាលាមានប្រសិទ្ធភាព។

### ៣.៥.៣ កម្រងសំណួរសម្រាប់គណៈកម្មការគ្រប់គ្រង/ទ្រទ្រង់សាលា

កម្រងសំណួរនេះមាន២ ជាកម្រងសំណួរបិទនិងកម្រងសំណួរសម្រាប់សម្ភាសន៍។

៣.៥.២.១-កម្រងសំណួរបិទមានមាន២ផ្នែក៖ ផ្នែកទី១៖ព័ត៌មានប្រជាសាស្ត្រ ឈ្មោះសាលា ព័ត៌មានផ្ទាល់ខ្លួន កម្រិតវប្បធម៌ អាយុ ភេទ និងកម្រិតវិជ្ជាជីវៈ។ ផ្នែកទី២៖ ប្រសិទ្ធភាពនៃការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល កម្រិតណាលើការទំនាក់ទំនង និងការចូលរួមរបស់ពួកគាត់ក្នុងសាលារៀន។

៣.៥.២.២-កម្រងសំណួរសម្រាប់សម្ភាសន៍គឺវាស់ស្ទង់ពីមតិផ្ទាល់ របស់គណៈកម្មការទ្រទ្រង់/គ្រប់គ្រងសាលារៀន ក្នុងការចូលរួមជាមួយសាលា ធៀបនឹងស្តង់ដាសាលាមានប្រសិទ្ធភាព។

## ៣.៦ ដំណាក់កាលនៃការប្រមូលទិន្នន័យ

មុនពេលចុះទៅប្រមូលទិន្នន័យតាមក្រុមគោលដៅ អ្នកស្រាវជ្រាវត្រូវទទួលការណែនាំ និងឯកភាពពីសាស្ត្រាចារ្យដឹកនាំ និងលិខិតឧទ្ទេសនាមលេខ១០២ វជអ.ផក ចុះថ្ងៃ ចន្ទ ៨រោច ខែ ផល្គុន ឆ្នាំ កុរ ឯកស័ក ព.ស. ២៥៦៣ ត្រូវនឹងថ្ងៃទី ១៦ ខែ មីនា ឆ្នាំ២០២០ និងលិខិតស្នើសុំលេខ ១១៩ វជអផក ចុះថ្ងៃ ព្រហស្បតិ៍ ១១រោច ខែ អាសាឍ ឆ្នាំ ជូត ទោស័ក ព.ស. ២៥៦៤ ត្រូវនឹងថ្ងៃទី១៦ ខែកក្កដា ឆ្នាំ ២០២០ របស់វិទ្យាស្ថានជាតិអប់រំ ទៅមន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ ដើម្បីសហការនិងសម្របសម្រួលក្នុងការចុះប្រមូលទិន្នន័យស្រាវជ្រាវ នៅតាមសាលារៀនមធ្យមសិក្សា។ ក្រោយពីបានលិខិត ១៣៧ អយក.ភព ចុះថ្ងៃ ចន្ទ១៥រោច ខែ អាសាឍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០ ស្តីពីការអនុញ្ញាតពីលោកប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ រួចមកអ្នកស្រាវជ្រាវបានយកលិខិតស្នើសុំទៅប្រគល់ជូនលោកនាយកសាលាគោលដៅ ដើម្បីសុំការអនុញ្ញាតក្នុងការចុះប្រមូលទិន្នន័យព្រមទាំងសម្ភាសន៍លើសំណាកដែលមាននាយកសាលា គ្រូ សិស្សានុសិស្ស គណៈកម្មការទ្រទ្រង់/គ្រប់គ្រងសាលារៀនជាដើម។ ក្រោយពីបានកំណត់កាលបរិច្ឆេទ ក្នុងការណាត់ជួប និងប្រាប់ពីគោលបំណង សារៈសំខាន់ក្នុងស្រាវជ្រាវនេះរួចមក អ្នកសិក្សាស្រាវជ្រាវ ផ្តល់នូវកម្រងសំណួរ ដល់

ពួកគាត់ដើម្បីបំពេញនិងធ្វើការសម្ភាស។ ប៉ុន្តែមុននិងធ្វើការចុះស្រាវជ្រាវផ្ទាល់ដល់សាលាគោលដៅ អ្នកស្រាវជ្រាវបានធ្វើការសាកល្បងលើកម្រងសំណួរទាំងអស់នោះទៅសាលារៀនដែលនៅជិតជាងគេក្នុងរាជជានីភ្នំពេញ ក្នុងគោលបំណងធានាអំពីប្រសិទ្ធភាពនិងភាពជឿជាក់នៃកម្រងសំណួរ ថាតើសំណួរណាខ្លះគួរកែលម្អ? តើអាចទទួលយកបានទេ? ចំណេញពេលវេលាប៉ុន្មានក្នុងមួយកម្រងសំណួរ? តើជួបប្រទះការលំបាកអ្វីខ្លះនៅពេលសម្ភាសន៍? ។ល។ ក្រោយពីបានសាកល្បង និងរកបញ្ហាឃើញហើយ ត្រូវសុំយោបល់បន្ថែមពីសាស្ត្រាចារ្យដឹកនាំ ទើបអ្នកសិក្សាស្រាវជ្រាវចាប់ផ្តើមចុះប្រមូលទិន្នន័យ។

## ៣.៧ ការវិភាគទិន្នន័យ

ចំពោះកិច្ចការស្រាវជ្រាវនេះ អ្នកសិក្សាស្រាវជ្រាវ បានប្រើប្រាស់វិធីសាស្ត្រ តាមបែបបរិមាណវិស័យ។ សំណួរបិទប្រើប្រាស់កម្មវិធីMs. Excel សម្រាប់សង់ក្រាប តារាង ឬក្រាហ្វិក និងបកប្រែជាតុសំណាកនីមួយៗជាភាសាខ្មែរ ។ ចំណែកសំណួរបើកវិញ ជាសំណួរបែបគុណវិស័យ ប្រើប្រាស់កម្មវិធី SPSS និង Ms. Word វិភាគទិន្នន័យចេញជាភាគរយ។ រាល់ការវិភាគចម្លើយ នៃសំណួរទាំងអស់ អាស្រ័យទៅលើប្រភេទនៃសំណួរ។ សំណួរបើក គឺអ្នកស្រាវជ្រាវបានប្រមូលផ្តុំចម្លើយរបស់ភាគីពាក់ព័ន្ធដែលទទួលពីការសម្ភាស ដើម្បីធ្វើការផ្ទៀងផ្ទាត់ជាមួយទិន្នន័យ និងស្វែងយល់ឱ្យកាន់តែច្បាស់លាស់ អំពីកម្រិតនៃការគ្រប់គ្រងសាលារៀនប្រកបដោយគុណភាពផ្អែកលើលទ្ធផល ដើម្បីឆ្លើយតបទៅនឹងវត្ថុបំណងនៃការស្រាវជ្រាវ។ ក្រោយពីបានវិភាគទិន្នន័យរួចមក អ្នកសិក្សាស្រាវជ្រាវនឹងលើកជាមតិយោបល់ សំណូមពរទៅថ្នាក់ដឹកនាំតាមឋានុក្រម និងលោកគ្រូអ្នកគ្រូ ដើម្បីជ្រាបជាព័ត៌មាន និងស្វែងរកដំណោះស្រាយចំពោះបញ្ហាប្រឈមនានាដែលកើតមាន ដើម្បីជំរុញឱ្យការគ្រប់គ្រងសាលារៀនមានប្រសិទ្ធភាពថែមទៀត។

## ៣.៨ ក្រមសីលធម៌នៃការស្រាវជ្រាវ

ចំពោះការសិក្សាស្រាវជ្រាវនេះ ក្នុងនាមជាអ្នកស្រាវជ្រាវត្រូវតែយកចិត្តទុកដាក់ពីក្រមសីលធម៌នៃការស្រាវជ្រាវ ត្រូវរក្សាការសម្ងាត់នូវរាល់ចម្លើយ របស់អ្នកចូលរួម មាននាយកសាលា គ្រូ សិស្ស គណៈកម្មការទ្រទ្រង់/គ្រប់គ្រងសាលារៀន ដោយមិនប្រាប់ព័ត៌មានអ្នកចូលរួមឡើយ។ ក្រោយពីពេលស្រាវជ្រាវរួច

អ្នកសិក្សាស្រាវជ្រាវត្រូវមានភាពស្មោះត្រង់ចំពោះការបញ្ចូលទិន្នន័យនូវចម្លើយអ្នកចូលរួម ដោយមិនបំផ្លើស និងបំពេញបន្ថែម លើចំណុចណាមួយឡើយ។ ការធ្វើបែបនេះ ក្នុងនាមអ្នកស្រាវជ្រាវនឹងទទួលបាននូវភាពជឿទុកចិត្ត ហើយជាភស្តុតាងមួយ បញ្ជាក់ពីការចុះទៅប្រមូលទិន្នន័យប្រកបដោយភាពត្រឹមត្រូវ សុចរិតភាព និងក្រមសីលធម៌ខ្ពស់។

# ជំពូកទី ៤
# លទ្ធផលនៃការស្រាវជ្រាវ
# និងការពិភាក្សា

# ជំពូកទី៤

# លទ្ធផលនៃការស្រាវជ្រាវ និងការពិភាក្សា

នៅក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវ និងបង្ហាញនូវលទ្ធផលនៃការវិភាគទិន្នន័យ និងការពិភាក្សានូវអ្វីដែលបានរកឃើញតាមរយៈការសម្ភាសនាយកសាលា ការបំពេញកម្រងសំណួររបស់គ្រូបង្រៀនបង្រៀនថ្នាក់ទី៧ ៨ ៩ តាមភាគរយ និងតាមតារាង ហើយនឹងធ្វើការប្រៀបធៀបខ្លឹមសារនៃពិន្ទុស្តង់ដាទាំង៩របស់សាលាមានប្រសិទ្ធភាព។

## ៤.១ លទ្ធផលនៃការស្រាវជ្រាវ

### ៤.១.១ អ្នកចូលរួមក្នុងការផ្តល់ព័ត៌មានក្នុងការស្រាវជ្រាវ

ក្រោយពេលបូកសរុបទិន្នន័យសាលារៀនសាធារណៈ ដែលប្រមូលបានពីការបំពេញកម្រងសំណួរ និងការឆ្លើយសំណួរសម្ភាសរួចមក អ្នកសិក្សាស្រាវជ្រាវរកឃើញថា អ្នកចូលរួមឆ្លើយក្នុងកម្រងសំណួរផ្តល់ព័ត៌មាន សរុបមានចំនួន៣២០នាក់ ស្រី១៨៣នាក់ ក្នុងនោះនាយកសាលា១២នាក់ ស្រី០០នាក់ គ្រូបង្រៀន១១៩នាក់ ស្រី៦០នាក់ សិស្ស១៧១នាក់ ស្រី១១៩នាក់ សហគមន៍ និងគណៈកម្មការគ្រប់គ្រងសាលារៀនចំនួន១៨នាក់ ស្រី០៤នាក់ ដូចមានក្នុងតារាងទី១។

**តារាងទី១ ចំនួនអ្នកចូលរួមផ្តល់ព័ត៌មានសម្រាប់ការស្រាវជ្រាវ**

| អ្នកចូលរួមឆ្លើយ | ប្រុស | ស្រី | សរុប |
|---|---|---|---|
| នាយកសាលា | ១២ | ០ | ១២ |
| គ្រូបង្រៀន | ៥៩ | ៦០ | ១១៩ |
| សិស្ស | ៥២ | ១១៩ | ១៧១ |
| សហគមន៍និងគណៈកម្មការគ្រប់គ្រងសាលា | ១៤ | ៤ | ១៨ |
| សរុប | ១៣៧ | ១៨៣ | ៣២០ |

ម៉្យាងវិញទៀត កម្រិតវប្បធម៌របស់នាយកសាលាទាំង១២នាក់ ដែលចូលរួមឆ្លើយតប ក្នុងការស្រាវជ្រាវមានតែនាយក១នាក់ទេ ដែលមានកម្រិតទុតិយភូមិ ៧នាក់មានកម្រិតបរិញ្ញាបត្រ ៤នាក់មានកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ និងមិនមានកម្រិតបណ្ឌិតទេ។ ចំណែកឯគ្រូបង្រៀនវិញ សរុបចំនួន១១៩នាក់ ក្នុងនោះ កម្រិតវប្បធម៌ទុតិយភូមិចំនួន៤៩នាក់ ស្រី២៨នាក់ បរិញ្ញាបត្រចំនួន៦៥នាក់ស្រី៣០នាក់ បរិញ្ញាបត្រជាន់ខ្ពស់៥នាក់ ស្រី២នាក់ ដូចមានបង្ហាញក្នុងតារាងទី២។

**តារាងទី២ កម្រិតវប្បធម៌អ្នកចូលរួមឆ្លើយកម្រងសំណួរ**

| កម្រិតវប្បធម៌(១) | នាយកសាលា | | គ្រូបង្រៀន | | សរុប |
|---|---|---|---|---|---|
| | ប្រុស | ស្រី | ប្រុស | ស្រី | |
| បឋមភូមិ | ០ | ០ | ០ | ០ | |
| ទុតិយភូមិ | ១ | ០ | ២១ | ២៨ | ៥០ |
| បរិញ្ញាបត្រ | ៧ | ០ | ៣៥ | ៣០ | ៧២ |
| បរិញ្ញាបត្រជាន់ខ្ពស់ | ៤ | ០ | ៣ | ២ | ៩ |
| បណ្ឌិត | ០ | ០ | ០ | ០ | ០ |
| សរុប | ១២ | ០ | ៥៩ | ៦០ | ១៣១ |

កម្រិតវិជ្ជាជីវៈនាយកសាលាក្នុងចំណោម១២នាក់ នាយកសាលា៥នាក់ស្មើនឹង៤១.៦៦%មានក្របខណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន និង៧នាក់មានក្របខណ្ឌគ្រូបង្រៀនកម្រិតឧត្តម។ ចំណែកឯគ្រូបង្រៀនវិញ ៤នាក់ ស្រី២នាក់ មានក្របខណ្ឌគ្រូបង្រៀនបឋមសិក្សា ៩៣នាក់ ស្រី៤៧នាក់ មានក្របខណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន និង២២នាក់មានក្របខណ្ឌគ្រូបង្រៀនកម្រិតឧត្តមដូចមានបង្ហាញក្នុងតារាងទី៣។ នេះបញ្ជាក់បានថា គ្រូបង្រៀននៅកម្រិតមធ្យមសិក្សាបឋមភូមិនៅមិនទាន់មានគុណវុឌ្ឍិគ្រប់គ្រាន់ដើម្បីឆ្លើយតបទៅនឹងគោលនយោបាយស្តីពីធនធានមនុស្សក្នុងវិស័យអប់រំនៅឡើយ។

**តារាងទី៣ កម្រិតវិជ្ជាជីវៈ នាយក គ្រូបង្រៀន**

| កម្រិតវិជ្ជាជីវៈ | នាយកសាលា | | គ្រូបង្រៀន | | សរុប |
|---|---|---|---|---|---|
| | ប្រុស | ស្រី | ប្រុស | ស្រី | |
| បឋមសិក្សា | ០ | ០ | ២ | ២ | ៤ |
| កម្រិតមូលដ្ឋាន | ៥ | ០ | ៤៦ | ៤៧ | ៩៨ |
| កម្រិតឧត្តម | ៧ | ០ | ១១ | ១១ | ២៩ |
| សរុប | ១២ | ០ | ៥៩ | ៦០ | ១៣១ |

តារាងទី៤ បង្ហាញពីអតីតភាពការងារក្នុងមុខតំណែងរបស់នាយកសាលានិងគ្រូបង្រៀន ក្នុងនោះនាយកសាលារៀនដែលមានអតីតភាពការងារចាប់ពី១៥ឆ្នាំឡើងទៅមានចំនួន១១នាក់ស្រី០នាក់និងមានបទពិសោធចន្លោះពី១០ ទៅ១៥ឆ្នាំ មានចំនួន០១នាក់ ស្រី០នាក់។ ចំណែកឯគ្រូបង្រៀនដែលមានអតីតភាពការងារចាប់ពី១៥ឆ្នាំឡើងទៅមានចំនួន៦៨នាក់ស្រី៣២នាក់ ចន្លោះពី១០ទៅ១៥ឆ្នាំមានចំនួន១៩នាក់ស្រី០៩នាក់ ចន្លោះពី៥ទៅ១០ឆ្នាំមានចំនួន២៥នាក់ស្រី១៤នាក់និងតិចជាង៥ឆ្នាំមានចំនួន០៧នាក់ស្រី០៥នាក់។ សរុបជារួម ទាំងនាយក និងគ្រូបង្រៀន ភាគច្រើនមានបទពិសោធន៍កាងារចាប់១៥ឆ្នាំឡើងទៅ។

**តារាងទី៤ អតីតភាពការងារមុខតំណែងរបស់នាយកសាលា និងគ្រូបង្រៀន**

| បទពិសោធការងារ | នាយកសាលា | | គ្រូបង្រៀន | | សរុប |
|---|---|---|---|---|---|
| | ប្រុស | ស្រី | ប្រុស | ស្រី | |
| តិចជាង៥ឆ្នាំ | ០ | ០ | ២ | ៥ | ៧ |
| ពី៥ទៅ១០ឆ្នាំ | ០ | ០ | ១១ | ១៤ | ២៥ |
| ពី១០ទៅ១៥ឆ្នាំ | ១ | ០ | ១០ | ៩ | ២០ |
| ពី១៥ឆ្នាំឡើងទៅ | ១១ | ០ | ៣៦ | ៣២ | ៧៩ |

| | | | | | |
|---|---|---|---|---|---|
| សរុប | ១២ | ០ | ៥៩ | ៦០ | ១៣១ |

តារាងទី៥ បង្ហាញពីចំនួនសិស្សតាមកម្រិតថ្នាក់នីមួយៗដែលបានចូលរួមឆ្លើយនូវកម្រងសំណួរ ក្នុងនោះសិស្សថ្នាក់ទី៧មានចំនួន៤៤នាក់ ស្រី៣៣នាក់ ថ្នាក់ទី៨ មានចំនួន៦៩នាក់ ស្រី៥១នាក់ និង សិស្សថ្នាក់ទី៩ មាន៥៨នាក់ស្រី៣៥នាក់ សរុបទាំងអស់១៧១នាក់ស្រី១១៩នាក់។

**តារាងទី៥ ចំនួនសិស្សតាមកម្រិតថ្នាក់**

| កម្រិតថ្នាក់ | សិស្ស | | សរុប |
|---|---|---|---|
| | ប្រុស | ស្រី | |
| ថ្នាក់ទី៧ | ១១ | ៣៣ | ៤៤ |
| ថ្នាក់ទី៨ | ១៨ | ៥១ | ៦៩ |
| ថ្នាក់ទី៩ | ២៣ | ៣៥ | ៥៨ |
| សរុប | ៥២ | ១១៩ | ១៧១ |

## ៤.១.២ ប្រសិទ្ធភាពនៃការអនុវត្តការគ្រប់គ្រងតាមសាលា ផ្អែកតាមស្តង់ដាទាំង៩

### *៤.១.២.១ វត្ថុបំណងគោលនយោបាយសាលារៀន*

**តារាងទី៦៖ វត្ថុបំណងគោលនយោបាយសាលារៀន**

| ល.រ | សូចនាករ | | កម្រិត | | |
|---|---|---|---|---|---|
| | | | ១=ទាប | ២=មធ្យម | ៣=ខ្ពស់ |
| | **ស្តង់ដា១៖ វត្ថុបំណងសាលារៀន** | | | | |
| ១.១ | ចូលរៀន ត្រួតថ្នាក់ បោះបង់ និងឡើងថ្នាក់ (ចំនួនសិស្ស) | ចូលរៀន | | | ៣ |
| | | ត្រួតថ្នាក់ | ១ | | |
| | | បោះបង់ | ១ | | |

| | | | | | |
|---|---|---|---|---|---|
| | | ឡើងថ្នាក់ | | | ៣ |
| ១.២ | ភាគរយសិស្សសម្រេចផលសិក្សាចុងឆ្នាំសិក្សាជាពិន្ទុ ច្រើនជាង៦០%នៃពិន្ទុសរុបលើមុខវិជ្ជាគោលនីមួយៗ | ភាសាខ្មែរ | | ២ | |
| | | គណិតវិទ្យា | | ២ | |
| | | ភាសាបរទេស | | | ៣ |
| ១.៣ | ភាគរយសិស្សសម្រេចផលសិក្សាចុងឆ្នាំសិក្សាជាពិន្ទុ ច្រើនជាង៦០%នៃពិន្ទុសរុបលើមុខវិជ្ជាគោលនីមួយៗ (មុខវិជ្ជាវិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម ប្រវត្តិវិទ្យា) | រូបវិទ្យា | | | ៣ |
| | | គីមីវិទ្យា | | ២ | |
| | | ជីវវិទ្យា | | ២ | |
| | | ផែនដីវិទ្យា | | | ៣ |
| | | ប្រវត្តិវិទ្យា | | ២ | |
| | | ICT | ១ | | |
| ១.៤ | ភាគរយសិស្សថ្នាក់ទី៩ សម្រេចបានល្បឿនអានភាសាខ្មែរ ក្នុង១នាទីយល់ភាសា | | | ២ | |
| ១.៥ | ភាគរយសិស្សថ្នាក់ទី៩ ប្រឡងជាប់សញ្ញាបត្របឋមភូមិ | | | | ៣ |
| សរុបស្តង់ដាទី១ | | | ៣៣ | | |
| ពិន្ទុស្តង់ដាអប្បរមាគឺ ៦៥% មានន័យថាស្តង់ដានេះត្រូវមានពិន្ទុយ៉ាងតិច២៧ ដើម្បីបំពេញបាននូវស្តង់ដាអប្បរមា | | | | | |

តារាងទី៦ បានបង្ហាញឱ្យឃើញថា ប្រសិទ្ធភាពនៃការគ្រប់គ្រងសាលារៀន ទៅលើស្តង់ដាទី១ ចំពោះសាលារៀនទាំង១២ ក្នុងរាជធានីភ្នំពេញ គឺបានបំពេញនូវស្តង់ដាអប្បរមាកម្រិតមធ្យម ដោយសារការអនុវត្តក្នុងស្តង់ដាទី១បានពិន្ទុសរុប៣៣ ធៀបនឹងស្តង់ដាពិន្ទុអប្បរមាសាលាមានប្រសិទ្ធភាព ដែលត្រូវមានពិន្ទុយ៉ាងតិច២៧។ អត្រាចូលរៀន និងអត្រាឡើងថ្នាក់ គិតជាមធ្យមទទួលបានពិន្ទុ៣ (ល្អ)។ តែសាលាទាំងនោះក៏នៅមានបញ្ហាប្រឈមកើតឡើងដែរ ពិសេសគឺនៅមានសិស្សបោះបង់ និងត្រួតថ្នាក់នៅឡើយ បើទោះបីជាមានតិចតួចក៏ដោយ។ កត្តានេះ អាចបណ្តាលមកពីសិស្សមិនយកចិត្តទុកដាក់ ក្នុងការសិក្សា មិនមានមូលដ្ឋានគ្រឹះលើមុខវិជ្ជាមួយចំនួន ពិសេសមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យា ឬអាច

បណ្តាលមកពីបញ្ហាជីវភាពគ្រួសារ ការផ្លាស់ប្តូរទៅតាមទីកន្លែងធ្វើការរបស់ឪពុកម្តាយ ឬក៏ឈប់រៀនទៅធ្វើការងារជាកម្មកររោងចក្រ ឬការងារផ្សេងៗទៀត ដូចជាការងារផ្ទះ និងការងារលក់ដូរនៅផ្ទះជាដើម។ ម្យ៉ាងវិញទៀត ការធ្វើតេស្តសិស្សនៅសាលាមធ្យមសិក្សាលើមុខវិជ្ជាគោលភាសាខ្មែរ និងគណិតវិទ្យានៅមានកម្រិតមធ្យម។ សម្រាប់តេស្តអំណានសិស្សថ្នាក់ទី៩ លើមុខវិជ្ជាភាសាខ្មែរ ក្នុងរយៈពេល១នាទីអានភាសាខ្មែរបាន៩០ពាក្យ ទទួលបានពិន្ទុ២ មានន័យថា អំណានមានកម្រិតមធ្យម តែការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិទទួលបានពិន្ទុល្អ(ពិន្ទុ៣)។ សម្រាប់មុខវិជ្ជាវិទ្យាសាស្ត្រពិត ក៏នៅមានកម្រិតមធ្យមផងដែរ។ ដោយឡែក សម្រាប់មុខវិជ្ជាកុំព្យូទ័រ (ICT) វិញ មិនមានដំណើរការ ឬក៏អាចដំណើរការដែរតែដំណើរការតិចតួច ដោយសារខ្វះគ្រូមុខវិជ្ជាកុំព្យូទ័រ ខ្វះកុំព្យូទ័រ ឬសាលាខ្លះមានកុំព្យូទ័រដែរ តែភាគច្រើនជាកុំព្យូទ័រចាស់ៗ ស៊ីថាមពលអគ្គីសនីច្រើន ធ្វើឱ្យសាលារៀនត្រូវចំណាយលើការប្រើប្រាស់ថាមពលអគ្គីសនីច្រើន។

### ៤.១.២.២ ការបង្រៀន និងរៀន

**តារាងទី៧ ការបង្រៀន និងរៀន**

| ល.រ | សូចនាករ | កម្រិត | | |
|---|---|---|---|---|
| | | ១ | ២ | ៣ |
| **ស្តង់ដា២៖ ការបង្រៀន និងរៀន** | | | | |
| ២.១ | បំណែងចែកកម្មវិធីសិក្សាតាមមុខវិជ្ជានិងតាមកម្រិតថ្នាក់(ឆ្នាំ)? | | | ៣ |
| ២.២.១ | ចំនួនកិច្ចតែងការបង្រៀនបានរៀបចំតាមមុខវិជ្ជាគោល (ភាសាខ្មែរ គណិតវិទ្យា វិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម/ប្រវត្តិ) ថ្នាក់ទី៧ ទៅតាមក្រុមគោលដៅ(ឆ្នាំ) | | | ៣ |
| ២.២.២ | ចំនួនកិច្ចតែងការបង្រៀនបានរៀបចំតាមមុខវិជ្ជាគោល (ភាសាខ្មែរ គណិតវិទ្យា វិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម/ប្រវត្តិ) | | | ៣ |

| | | | | |
|---|---|---|---|---|
| | ថ្នាក់ទី៨ ទៅតាមក្រុមគោលដៅ(ឆ្នាំ) | | | |
| ២.២.៣ | ចំនួនកិច្ចតែងការបង្រៀនបានរៀបចំតាមមុខវិជ្ជាគោល (ភាសាខ្មែរ គណិតវិទ្យា វិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម/ប្រវត្តិ) ថ្នាក់ទី៩ ទៅតាមក្រុមគោលដៅ(ឆ្នាំ) | | | ៣ |
| ២.៣ | ចំនួនសិស្សថ្នាក់ទី៩ មានពិន្ទុតេស្តជាប់ស្តង់ដាល្បឿនអំណាននិងយល់ខ្លឹមសារ(២០០ពាក្យក្នុងមួយនាទី) (ត្រួតពិនិត្យតាមដាន និងចុងឆមាសទី១ និងចុងឆមាសទី២) | | ២ | |
| ២.៤.១ | ចំនួនសិស្សថ្នាក់ទី៧ មានពិន្ទុតេស្តជាប់លើមុខវិជ្ជាគោលធៀបជាមួយក្រុមគោលដៅគ្រោងទុក(ត្រូវពិនិត្យតាមដាននៅចុងឆមាសទី១ និងទី២) | | ២ | |
| ២.៤.២ | ចំនួនសិស្សថ្នាក់ទី៨ មានពិន្ទុតេស្តជាប់លើមុខវិជ្ជាគោលធៀបជាមួយក្រុមគោលដៅគ្រោងទុក(ត្រូវពិនិត្យតាមដាននៅចុងឆមាសទី១ និងទី២) | | ២ | |
| ២.៤.៣ | ចំនួនសិស្សថ្នាក់ទី៩ មានពិន្ទុតេស្តជាប់លើមុខវិជ្ជាគោលធៀបជាមួយក្រុមគោលដៅគ្រោងទុក(ត្រូវពិនិត្យតាមដាននៅចុងឆមាសទី១ និងទី២) | | ២ | |
| ២.៥ | ភាគរយសិស្សថ្នាក់ទី៩ ប្រឡងជាប់ឆមាស(ត្រូវពិនិត្យតាមដាននៅចុងឆមាសទី១ និងទី២) | | | ៣ |
| ២.៦ | ភាគរយសិស្សប្រឡងឡើងថ្នាក់សម្រាប់សិស្សធ្លាក់មធ្យមភាគ (ប្រចាំឆ្នាំឬក្រៅថ្នាក់) | ១ | | |
| ២.៧ | ចំនួនថ្នាក់មានការប្រជុំរវាងគ្រូបង្រៀន មាតាបិតានិងសិស្សរៀនយឺត((សិស្សត្រួតថ្នាក់ឆ្នាំមុន សិស្សដែលមានពិន្ទុទាបជា៦០%ពី | | ២ | |

| | | | | |
|---|---|---|---|---|
| | ចុងឆ្នាំសិក្សាមុន និងនៅបំណាច់ខែទី១)ជៀបជាមួយក្រុមគោលដៅ | | | |
| ២.៨.១ | កង្វះចំនួនម៉ោងបង្រៀនជាមធ្យមនៃថ្នាក់ទី៧ (ត្រូវពិនិត្យតាមដាននៅចុងឆមាសទី១ និងទី២) | ១ | | |
| ២.៨.២ | កង្វះចំនួនម៉ោងបង្រៀនជាមធ្យមនៃថ្នាក់ទី៨ (ត្រូវពិនិត្យតាមដាននៅចុងឆមាសទី១ និងទី២) | ១ | | |
| ២.៨.៣ | កង្វះចំនួនម៉ោងបង្រៀនជាមធ្យមនៃថ្នាក់ទី៩ (ត្រូវពិនិត្យតាមដាននៅចុងឆមាសទី១ និងទី២) | ១ | | |
| ២.៩.១ | ភាគរយសិស្សអវត្តមានតិចជាង៥ដង | ១ | | |
| ២.៩.២ | ភាគរយសិស្សអវត្តមានចាប់ពី៥ទៅ១០ដង | ១ | | |
| ២.៩.៣ | ភាគរយសិស្សអវត្តមានច្រើនជាង១០ដង | ១ | | |
| ២.១០.១ | ភាគរយសិស្សថ្នាក់ទី៧ បានទទួលលំហាត់ឬកិច្ចការផ្ទះដាក់ឱ្យតាមមុខវិជ្ជាគោល (ភាសាខ្មែរ គណិត វិទ្យាសាស្ត្រ)ធៀបនឹងក្រុមគោលដៅគ្រោងទុក | | | ៣ |
| ២.១០.២ | ភាគរយសិស្សថ្នាក់ទី៨ បានទទួលលំហាត់ឬកិច្ចការផ្ទះដាក់ឱ្យតាមមុខវិជ្ជាគោល (ភាសាខ្មែរ គណិត វិទ្យាសាស្ត្រ)ធៀបនឹងក្រុមគោលដៅគ្រោងទុក | | | ៣ |
| ២.១០.៣ | ភាគរយសិស្សថ្នាក់ទី៩ បានទទួលលំហាត់ឬកិច្ចការផ្ទះដាក់ឱ្យតាមមុខវិជ្ជាគោល (ភាសាខ្មែរ គណិត វិទ្យាសាស្ត្រ)ធៀបនឹងក្រុមគោលដៅគ្រោងទុក | | | ៣ |
| ២.១១.១ | ភាគរយសិស្សថ្នាក់ទី៧ បានទទួលកិច្ចការជាគម្រោងដាក់ឱ្យតាម | | ២ | |

| | | | | |
|---|---|---|---|---|
| | មុខវិជ្ជាគោល (ភាសាខ្មែរ គណិតវិទ្យា និងវិទ្យាសាស្ត្រ) ធៀបជាមួយក្រុមគោលដៅគ្រោងទុក | | | |
| ២.១១.២ | ភាគរយសិស្សថ្នាក់ទី៨ បានទទួលកិច្ចការជាគម្រោងដាក់ឱ្យតាមមុខវិជ្ជាគោល (ភាសាខ្មែរ គណិតវិទ្យា និងវិទ្យាសាស្ត្រ) ធៀបជាមួយក្រុមគោលដៅគ្រោងទុក | | ២ | |
| ២.១១.៣ | ភាគរយសិស្សថ្នាក់ទី៩ បានទទួលកិច្ចការជាគម្រោងដាក់ឱ្យតាមមុខវិជ្ជាគោល (ភាសាខ្មែរ គណិតវិទ្យា និងវិទ្យាសាស្ត្រ) ធៀបជាមួយក្រុមគោលដៅគ្រោងទុក | | | ៣ |
| ២.១២ | ចំនួនគ្រូបង្រៀនក្រោមគោលដៅបានទទួលការបំប៉ននិងជួយការបង្រៀននៅនឹងកន្លែង | ១ | | |
| ២.១៣ | ចំនួនថ្នាក់រៀនបានបំពេញរដ្ឋបាលថ្នាក់រៀនតាមការណែនាំរបស់ក្រសួងធៀបជាមួយក្រុមគោលដៅ | | | ៣ |
| ២.១៤ | ភាគរយគ្រូបង្រៀនបើកថ្នាក់យឺត និងបិទថ្នាក់មុនបានថយចុះធៀបជាមួយក្រុមគោលដៅ | ១ | | |
| ២.១៥ | ចំនួនមុខវិជ្ជាអប់រំកាយកីឡា និងសិល្បៈបានបង្រៀនតាមក្រុមគោលដៅគ្រោង (សរុប១៤មុខវិជ្ជា) | | | ៣ |
| **សរុបស្តង់ដាទី២** | | ៥៦ | | |
| ពិន្ទុស្តង់ដាអប្បរមាគឺ ៦៥% មានន័យថាស្តង់ដានេះត្រូវមានពិន្ទុយ៉ាងតិច៥១ ដើម្បីបំពេញបាននូវ ស្តង់ដាអប្បរមា | | | | |

តារាងទី៧ បង្ហាញថា ការរៀន និងបង្រៀន នៅសាលាមធ្យមសិក្សាទាំង១២ក្នុងរាជធានីភ្នំពេញ មានកម្រិតមធ្យម ដោយពិន្ទុទទួលបាន៥៦ បើប្រៀបធៀបទៅនឹងស្តង់ដាសាលាមានប្រសិទ្ធភាព ពិន្ទុស្តង់

ជាអប្បរមាគឺ ៦៥% មានន័យថាស្តង់ដានេះត្រូវមានពិន្ទុយ៉ាងតិច៥១ ។ តាមការឆ្លើយរបស់ នាយក និងគ្រូបង្រៀន សុទ្ធតែបានបញ្ជាក់ថាមានបំណែងចែកកម្មវិធីសិក្សា កិច្ចតែងការបង្រៀនតាមកម្រិតថ្នាក់ និងតាមមុខវិជ្ជា តែក្នុងពេលបង្រៀន មិនសុទ្ធតែប្រើប្រាស់កិច្ចតែងការបង្រៀន និងសម្ភារឧបទេស ទាំងអស់នោះទេ។ ចំពោះការសិក្សារបស់សិស្សថ្នាក់ទី៩ ដែលបានធ្វើតេស្តល្បឿនអំណាន(២០០ពាក្យក្នុង១នាទី) ក៏មានកម្រិតមធ្យមផងដែរ ដោយសារនៅមានសិស្សមួយចំនួនមិនបានតេស្តជាប់ល្បឿនអំណាន ព្រោះរៀនយឺតពីកម្រិតបឋម និងមិនមានមូលដ្ឋានគ្រឹះលើអំណានដំបូង។ ចំណែកសិស្សថ្នាក់ទី៧ ទី៨ វិញមានពិន្ទុតេស្តជាប់លើមុខវិជ្ជាគោលមានកម្រិតមធ្យមនៅឡើយ។ មានតែសាលា១ ក្នុងចំណោមសាលារៀនទាំង ១២ ប៉ុណ្ណោះដែលមិនទាន់សម្រេចបាននូវស្តង់ដាអប្បរមាលើការរៀន និងបង្រៀន។

### *៤.១.២.៣ មាតាបិតា និងសហគមន៍ជួយការសិក្សាសិស្ស*

**តារាងទី៨ មាតាបិតា និងសហគមន៍ជួយដល់ការរៀនសូត្រសិស្ស**

| ល.រ | សូចនាករ | កម្រិត | | |
|---|---|---|---|---|
| | | ទាប | មធ្យម | ខ្ពស់ |
| **ស្តង់ដាទី៣ មាតាបិតានិងសហគមន៍ជួយដល់ការរៀនសូត្រសិស្ស** | | | | |
| ៣.១ | ភាគរយថ្នាក់រៀនបានប្រជុំប្រឹក្សាយោបល់រវាងគ្រូបង្រៀន មាតាបិតាសិក្សានិងសិស្ស(នៅដើមឆ្នាំសិក្សានិងតាមត្រីមាស) | | ២ | |
| ៣.២ | ចំនួនប្រជុំគណៈកម្មការគ្រប់គ្រងសាលារៀនតាមការណែនាំ (ពេលបើកបវេសនកាល ចុងឆមាសទី២ និងទី២) | | ២ | |
| ៣.៣ | ភាគរយសិស្សមករៀនយឺត | ១ | | |
| ៣.៤ | ភាគរយសិស្សបានធ្វើកិច្ចការផ្ទះ ឬកិច្ចការគម្រោង | | | ៣ |
| **សរុបស្តង់ដាទី៣** | | ៨ | | |
| ពិន្ទុស្តង់ដាអប្បរមាគឺ ៦៥% មានន័យថាស្តង់ដានេះត្រូវមានពិន្ទុយ៉ាងតិច ៨ ដើម្បីបំពេញនូវស្តង់ដាអប្បរមា | | | | |

ស្តង់ដាទី៣នៃសាលារៀនមានប្រសិទ្ធភាពគឺមាតាបិតានិងសហគមន៍ជួយសិស្សក្នុងការសិក្សា។ តាមរយៈការផ្តល់យោបល់ពីគណៈកម្មការគ្រប់គ្រងសាលារៀន និងមាតាបិតាសិស្ស នៃសាលាទាំង១២ បានបង្ហាញថាការចូលរួមរបស់មាតាបិតានិងសហគមន៍ចូលរួមជួយសិស្សបានកម្រិតមធ្យម ដោយសារពិន្ទុដែលទទួលបានសរុបមាន៨ ដូចមានបង្ហាញក្នុងតារាងទី៨។ នេះអាចបញ្ជាក់ជាទូទៅបានថា សាលាអាចបំពេញនូវស្តង់អប្បរមា តែក៏មានសាលាមួយចំនួនពិសេសអនុវិទ្យាល័យចំនួន៤ ក្នុងការសិក្សានេះមិនទាន់បានបំពេញនូវស្តង់ដាអប្បរមានៅឡើយ ដោយសារមានបញ្ហាប្រឈមដូចជាការប្រជុំគណៈកម្មការគ្រប់គ្រងសាលារៀនបានតិចតួច ត្រឹមតែ១ដងប៉ុណ្ណោះ។

### ៤.១.២.៤ សិស្ស និងសេវាជួយសិស្ស

**តារាងទី៩ សិស្សនិងសេវាជួយសិស្ស**

| ល.រ | សូចនាករ | កម្រិត | | |
|---|---|---|---|---|
| | | ១ | ២ | ៣ |
| **ស្តង់ដាទី៤ សិស្ស និងសេវាសិស្សជួយសិស្ស** | | | | |
| ៤.១ | ភាគរយសិស្សប្រើបណ្ណាល័យ (ពិនិត្យតាមដានរាល់ត្រីមាស) | | ២ | |
| ៤.២ | ភាគរយសិស្សប្រើបន្ទប់ពិសោធន៍ | ១ | | |
| ៤.៣ | ភាគរយសិស្សប្រើកុំព្យូទ័រ | ១ | | |
| ៤.៤ | ភាគរយថ្នាក់មានដំណើរការ (តាមការណែនាំរបស់ក្រសួង) ក្លឹបសិស្សានុសិស្ស | | ២ | |
| ៤.៥ | ភាគរយសិស្សខ្សោយ គំហើញនិងខ្សោយស្តាប់ បានទទួលការគាំទ្រដើម្បីរៀនបានប្រសើរ | | ២ | |
| ៤.៦ | ភាគរយសិស្សអាហារូបករណ៍បោះបង់ការសិក្សា | ១ | | |
| ៤.៧ | ចំនួនទស្សនកិច្ចសិក្សារបស់គ្រូបង្រៀន | ១ | | |
| សរុបស្តង់ដាទី៤ | | ១០ | | |

| |
|---|
| ពិន្ទុស្តង់ដាអប្បរមាគឺ ៦៥% មានន័យថាស្តង់ដានេះ ត្រូវមានពិន្ទុយ៉ាងតិច១៤ ដើម្បីបំពេញបាននូវស្តង់ដាអប្បរមា |

តារាងទី៩ បង្ហាញថាសេវាសិស្សជួយសិស្ស ដែលជាស្តង់ដាទី៤នៃសាលាមានប្រសិទ្ធភាពគឺអនុវត្តបានកម្រិតទាប ធៀបទៅនឹងស្តង់ដា ដោយបានពិន្ទុវាយតម្លៃជារួមសម្រាប់ស្តង់ដានេះគឺត្រឹមតែ១០ពិន្ទុប៉ុណ្ណោះ មានន័យថាមិនបានអនុវត្តពិន្ទុអប្បរមាដែលស្មើនឹង៦៥%ឬ១៤ពិន្ទុ នៅក្នុងស្តង់ដាទី៤នៃសាលារៀនមានប្រសិទ្ធភាពនោះទ។ នេះអាចបញ្ជាក់បានថា ពុំទាន់បានបំពេញស្តង់ដានេះ។ បញ្ហាប្រឈមដែលបានរកឃើញ ពីអ្នកចូលរួមបំពេញកម្រងសំណួរ និងសម្ភាសន៍គឺថា បណ្ណាល័យគ្មានកម្រិតស្តង់ដា បណ្ណាល័យមិនដំណើរការ សាលាខ្លះទៀតមានបណ្ណាល័យដំណើរការដែរ តែមិនមានឯកសារ និងសៀវភៅគ្រប់គ្រាន់សម្រាប់សិស្សចូលអាននិងស្រាវជ្រាវ និងពុំមានបណ្ណារក្សគ្រប់គ្រងត្រឹមត្រូវ។ ចំណែកឯបន្ទប់ពិសោធន៍វិញ សាលារៀនក៏នៅមានកម្រិតទាប។ សម្រាប់សាលាធំមួយចំនួនវិញមានបន្ទប់ពិសោធន៍ដែរ តែពុំសូវមានដំណើរការ។ មួយវិញទៀត សាលាក៏ខ្វះសម្ភារពិសោធន៍លើផ្នែកវិទ្យាសាស្ត្រមួយចំនួនធំ។ ចំណែកឯគ្រូមិនទាន់មានចំណេះដឹងក្នុងការប្រើប្រាស់សម្ភារពិសោធន៍។ ការប្រើប្រាស់កុំព្យូទ័ររបស់សិស្សក៏មានកម្រិតទាបដែរ ដោយសារសាលាខ្លះ ពុំទាន់មានបំពាក់សម្ភារកុំព្យូទ័រ សម្រាប់បង្រៀនសិស្សនៅឡើយ ។ សាលាខ្លះមានកុំព្យូទ័រដែរ តែកុំព្យូទ័រចាស់ខូច និងមានគ្រូ ICT ដែលធ្វើសេវាមួយនេះនៅមានកម្រិត។ ជារួម ស្តង់ដាទី៤នេះ មានសាលា៩ក្នុងចំណោមសាលាទាំង១២ ដែលមិនបានបំពេញនូវស្តង់អប្បរមា ហើយមានតែសាលា៣ទេ ដែលសម្រេចបាននូវស្តង់ដាទី៤នេះ។

### ៤.១.២.៥ ការដឹកនាំ និងការគ្រប់គ្រង

**តារាងទី១០ ការដឹកនាំ និងការគ្រប់គ្រងសាលារៀន**

| ល.រ | សូចនាករ | កម្រិត | | |
|---|---|---|---|---|
| | | ១ | ២ | ៣ |
| **ស្តង់ដាទី៥៖ការដឹកនាំនិងគ្រប់គ្រងសាលារៀន** | | | | |
| ៥.១ | ចំនួនសូចនាករ រដ្ឋបាលសាលារៀនបានបំពេញតាមការណែនាំរបស់ | | | ៣ |

| | | | | |
|---|---|---|---|---|
| | ក្រសួង (សរុបសូចនាករ១០) | | | |
| ៥.២ | ការអនុវត្តផែនការអធិការកិច្ចរបស់នាយកឬនាយករង | | | ៣ |
| ៥.៣ | ចំនួនការប្រជុំបច្ចេកទេសប្រចាំខែតាមការណែនាំរបស់ក្រសួង (សរុប៧ដងក្នុង១ឆ្នាំ) | | | ៣ |
| ៥.៤ | ចំនួនដងបំប៉ន និងដឹកដៃធ្វើការងារនៅនឹងកន្លែងដល់នាយក និងគណៈកម្មការគ្រប់គ្រងសាលារៀនដោយមន្ត្រីក្រសួងដើម្បីកែលម្អសូចនាការគ្រប់គ្រងសាលារៀន | ១ | | |
| ៥.៥ | ចំនួនគ្រូបង្រៀន បានបំពេញការងារប្រសើរជាងមុន តាមរយៈការវាយតម្លៃការអនុវត្តការងារប្រចាំឆ្នាំ | | | ៣ |
| ៥.៦ | ការបន្ថយភាពមិនប្រក្រតីនៅសាលារៀន (សរុប៩ភាពមិនប្រក្រតី) | | | ៣ |
| ៥.៧ | ចំនួនដងពិនិត្យតាមដាននិងគាំទ្រពីថ្នាក់ស្រុកមន្ទីរនិងក្រសួង | | ២ | |
| សរុបស្តង់ដាទី៥ | | ១៨ | | |
| ពិន្ទុស្តង់ដាអប្បរមាគឺ ៦៥% មានន័យថាស្តង់ដានេះត្រូវមានពិន្ទុយ៉ាងតិច១៤ ដើម្បីបំពេញបាននូវស្តង់ដាអប្បរមា | | | | |

តារាងទី១០ បង្ហាញថាការដឹកនាំ និងគ្រប់គ្រង របស់នាយកនៅសាលាមធ្យមសិក្សា គឺមានកម្រិតមធ្យម បើប្រៀបធៀបទៅនឹងស្តង់ដាអប្បរមា៦៥%ដែលត្រូវមានពិន្ទុយ៉ាងតិច១៤ ដើម្បីបំពេញបានស្តង់ដាអប្បរមា។ ឆ្លងតាមរយៈការផ្តល់បទសម្ភាសន៍ ការចូលរួមគួសលើកិច្ចការស្រាវជ្រាវ និងការសង្កេតលើរបាយការណ៍មួយចំនួនមក អ្នកស្រាវជ្រាវបានរកឃើញថា នៅមានបញ្ហាប្រឈមដែលសាលាខ្លះមិនទាន់មានផែនការ និងការធ្វើអធិការកិច្ចរបស់នាយកបានល្អនៅឡើយ។ សាលាខ្លះបានធ្វើតែ២ដង និងខ្លះបានធ្វើតែម្តងទេ។ មិនទាន់មានការបំប៉ន និងការដឹកដៃធ្វើការងារនៅនឹងកន្លែងដល់នាយក គណៈកម្មការគ្រប់គ្រងសាលារៀន ពីមន្ត្រីក្រសួង ដើម្បីកែលម្អសូចនាករនៃការគ្រប់គ្រងសាលារៀននៅឡើយ។ បើពិនិត្យតាមចំនួនសាលាវិញ មានតែសាលាមួយប៉ុណ្ណោះ មិនទាន់សម្រេចបានស្តង់ដាអប្បរមានេះ។

### ៤.១.២.៦ ធនធានមនុស្ស

តារាងទី១១៖ ធនធានមនុស្ស

| ល.រ | សូចនាករ | កម្រិត | | |
|---|---|---|---|---|
| | | ១ | ២ | ៣ |
| **ស្តង់ដាទី៦.ធនធានមនុស្ស** | | | | |
| ៦.១ | គុណវុឌ្ឍិគ្រូបង្រៀនធៀបជាមួយផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន | | | ៣ |
| ៦.២ | ចំនួនគ្រូខ្វះ មុខវិជ្ជាភាសាខ្មែរ គណិតវិទ្យា វិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម (ប្រវត្តិវិទ្យា) ចុះថយធៀបជាមួយបទដ្ឋាន | | ២ | |
| ៦.៣ | គុណវុឌ្ឍិនាយក ឬនាយិកាសាលាធៀបជាមួយផែនការក្រសួង | | ២ | |
| **សរុបស្តង់ដាទី៦** | | ៧ | | |
| ពិន្ទុស្តង់ដាអប្បរមាគឺ ៦៥% មានន័យថាស្តង់ដានេះត្រូវមានពិន្ទុយ៉ាងតិច៦ ដើម្បីបំពេញបាននូវស្តង់ដាអប្បរមា | | | | |

តារាងទី១១ បង្ហាញថាសាលាដែលបានចូលរួមធ្វើការស្រាវជ្រាវបានបំពេញស្តង់ដាអប្បរមា គឺបានពិន្ទុ៧មានន័យថាស្តង់ដាទី៦នេះ ត្រូវមានពិន្ទុយ៉ាងតិច៦ ដើម្បីបំពេញបានលក្ខខណ្ឌស្តង់ដាអប្បរមា។ តែបើនិយាយដោយឡែក ឃើញថា សាលាតូចៗនៅតែខ្វះមុខវិជ្ជាវិទ្យាសាស្ត្រ និងមុខវិជ្ជាវិទ្យាសាស្ត្រសង្គម ដោយសារអត្រាវិចរិល ដូចជាការចូលនិវត្តន៍ ការផ្លាស់ប្តូរទីកន្លែងធ្វើការ ការផ្លាស់ប្តូរតាមសហព័ន្ធ និងផ្ទះនៅឆ្ងាយពីកន្លែងធ្វើការជាដើម។ ចំពោះគុណវុឌ្ឍិនាយកវិញ មានតែនាយក១នាក់មានកម្រិតវប្បធម៌ត្រឹមសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ និងនាយកចំនួន១១នាក់មានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រដល់បរិញ្ញាបត្រជាន់ខ្ពស់។ រីឯគ្រូបង្រៀនមានកម្រិតវប្បធម៌ត្រឹមសញ្ញាបត្រទុតិយភូមិមានចំនួន៤៩នាក់ ស្មើនឹង៤០% ធៀបនឹងគ្រូសរុប១១៩នាក់ និងគ្រូបង្រៀន៦០%ឡើងទៅមានសញ្ញាបត្រចាប់ពីកម្រិតបរិញ្ញាបត្រ។

### ៤.១.២.៧ សៀវភៅសិក្សាគោល និងសម្ភារៈរៀន និងបង្រៀន

**តារាងទី១២៖ សៀវភៅសិក្សាគោល និងសម្ភារៀន និងបង្រៀន**

| ល.រ | សូចនាករ | កម្រិត | | |
|---|---|---|---|---|
| | | ១=ទាប | ២=មធ្យម | ៣=ខ្ពស់ |
| **ស្តង់ដាទី៧.សៀវភៅសិក្សាគោល និងសម្ភារៈរៀន និងបង្រៀន** | | | | |
| ៧.១ | ភាគរយសិស្សមានសៀវភៅគោលតាមមុខវិជ្ជានិងតាមកម្រិតថ្នាក់តាមបទដ្ឋាន | | | ៣ |
| ៧.២ | ចំនួនគ្រូបង្រៀនមុខវិជ្ជាគោលបានបំប៉នពីការប្រើប្រាស់សៀវភៅលំហាត់ | ១ | | |
| ៧.៣ | បណ្ណាល័យបានបង្កើតនិងមានស្តង់ដា | ១ | | |
| **សរុបស្តង់ដាទី៧** | | ៥ | | |
| ពិន្ទុស្តង់ដាអប្បរមាគឺ ៦៥% មានន័យថាស្តង់ដានេះត្រូវមានពិន្ទុយ៉ាងតិច៦ ដើម្បីបំពេញបាននូវស្តង់ដាអប្បរមា | | | | |

តារាងទី១២ បានបង្ហាញថា ការអនុវត្តស្តង់ដាទី៧ ស្តីពីសៀវភៅសិក្សាគោល និងសម្ភាររៀន និងបង្រៀន គឺមិនទាន់បានបំពេញស្តង់ដាអប្បរមានៅឡើយទេ ដោយពិន្ទុសរុបបានតែ៥ប៉ុណ្ណោះ បើធៀបទៅនឹងស្តង់ដាសាលារៀនមានប្រសិទ្ធភាព ត្រូវមានពិន្ទុយ៉ាងតិច៦ ស្មើនឹង៦៥%។ យោងតាមទិន្នន័យក្នុងតារាងបង្ហាញថា សៀវភៅសិក្សាគោលតាមមុខវិជ្ជា និងតាមកម្រិតថ្នាក់នៅតាមសាលានីមួយៗ គឺសិស្សមានប្រើប្រាស់សៀវភៅគ្រប់ៗគ្នា ដោយសិស្សម្នាក់មានសៀវភៅ១ក្បាលគ្រប់មុខវិជ្ជា។ ចំណែកគ្រូបង្រៀនតាមមុខវិជ្ជាគោលវិញ មិនបានបំប៉នពីការប្រើប្រាស់សៀវភៅលំហាត់ ឬការបណ្ដុះបណ្ដាល ឬការចូលរួមសិក្សាពីការប្រើប្រាស់ និងការអនុវត្តកម្មវិធីសិក្សាថ្មីៗ ជាមួយថ្នាក់មន្ទីរ ឬក្រសួង ដើម្បីឱ្យលោកគ្រូអ្នកគ្រូកាន់តែយល់ច្បាស់ពីខ្លឹមសារ និងអត្ថន័យរបស់សៀវភៅ ងាយស្រួលក្នុងការពន្យល់សិស្សឱ្យឆាប់យល់។ រីឯការបង្កើតបណ្ណាល័យសាលារៀននៅតាមសាលាទាំង១២វិញ ឃើញថាសាលាមួយចំនួនមិនទាន់មានបណ្ណាល័យដែលសមស្របតាមស្តង់ដាបណ្ណាល័យមធ្យមសិក្សាផងដែរ ដោយសារមិនទាន់មានសម្ភារៈនិង

សៀវភៅគ្រប់គ្រាន់ ការកត់ត្រាកូដសៀវភៅបណ្ណារក្សមិនទាន់មានជំនាញច្បាស់លាស់ មិនទាន់បានឆ្លងកាត់ការបណ្តុះបណ្តាលវគ្គបណ្ណារក្ស បន្ទប់សម្រាប់ធ្វើជាបណ្ណាល័យមិនទាន់សមស្របតាមស្តង់ដានៅឡើយ។ ម្យ៉ាងវិញទៀត បណ្ណារក្សខ្លះដែលទទួលការបណ្តុះបណ្តាលហើយ ត្រូវផ្លាស់ប្តូរទៅកន្លែងធ្វើការងារតាមប្តី ប្រពន្ធ ឬផ្ទះនៅឆ្ងាយ ដែលធ្វើឱ្យមានការខ្វះបណ្ណារក្ស។

### *៤.១.២.៨ ហេដ្ឋារចនាសម្ព័ន និងបរិស្ថានសាលារៀន*

**តារាងទី១៣៖ ហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានសាលារៀន**

| **ស្តង់ដាទី៨.ហេដ្ឋរចនាសម្ព័ន្ធនិងបរិស្ថានសាលារៀន** | | | | |
|---|---|---|---|---|
| ៨.១ | កង្វះបន្ទប់រៀនថយចុះរហូតមានចំនួនសិស្សក្នុងបន្ទប់រៀនតាមបទដ្ឋាន | ១ | | |
| ៨.២ | បន្ទប់ស្នាក់នៅរបស់គ្រូបង្រៀនបានសាសង់តាមតម្រូវការ | ១ | | |
| ៨.៣ | បន្ទប់រដ្ឋបាលសាលារៀននិងសង្ហារឹមបានផ្តល់តាមតម្រូវការ | ១ | | |
| ៨.៤ | បន្ទប់ទឹកបានសាសង់តាមស្តង់ដា និងគ្រប់គ្រាន់តាមបទដ្ឋានសម្រាប់សិស្ស ទាំងប្រុស ទាំងស្រី | | | ៣ |
| **សរុបស្តង់ដាទី៨** | | ៦ | | |
| ពិន្ទុស្តង់ដាអប្បរមាគឺ ៦៥% មានន័យថាស្តង់ដានេះត្រូវមានពិន្ទុយ៉ាងតិច១០ ដើម្បីបំពេញបាននូវស្តង់ដាអប្បរមា | | | | |

លទ្ធផលតារាងទី១៣ បានបង្ហាញថា សាលារៀនទាំង១២ មិនទាន់បានបំពេញនូវស្តង់ដាសាលារៀនមធ្យមសិក្សានៅឡើយ ដោយសារទទួលបានពិន្ទុតែ៦ប៉ុណ្ណោះ បើធៀបនឹងស្តង់ដាសាលារៀនមធ្យមសិក្សាត្រូវមានពិន្ទុអប្បរមាយ៉ាងតិច១០ស្មើនឹង៦៥%នៃស្តង់ដានេះ។ ដោយសារសាលារៀនមួយចំនួនមានការខ្វះខាតសម្ភារបរិក្ខារសម្រាប់បន្ទប់ស្នាក់នៅរបស់គ្រូបង្រៀន និងសាលាភាគច្រើនមិនមានបន្ទប់គ្រូបង្រៀនស្នាក់នៅ។ សម្ភារសង្ហារឹមសម្រាប់បន្ទប់រដ្ឋបាលសាលារៀនក៏នៅមានការខ្វះខាតដែរ។

### ៤.១.២.៩ ហិរញ្ញប្បទាន និងការគ្រប់គ្រងហិរញ្ញវត្ថុ

តារាងទី១៤៖ ហិញ្ញប្បទាន និងការគ្រប់គ្រងហិញ្ញវត្ថុ

| | | | | |
|---|---|---|---|---|
| ស្តង់ដាទី៩.ហិរញ្ញប្បទាន និងការគ្រប់គ្រងហិរញ្ញវត្ថុ | | | | |
| ៩.១ | ថវិកាសាលារៀន ពីប្រភពផ្សេងៗបានទទួល ដាក់ស្តែងតាមត្រីមាស មានភាពប្រសើរឡើង | | ២ | |
| ៩.២ | ការចាត់ចែង ការប្រើប្រាស់និងតម្លភាពថវិកា សាលារៀនបានប្រសើរ (សរុប៥សូចនាករ) | | | ៣ |
| ៩.១ | ការរាយការណ៌ការចំណាយតាមខ្ទង់ចំណាយ ធំៗ (រដ្ឋបាល ការបង្រៀន និងរៀននិងបរិស្ថាន | | | ៣ |
| សរុបស្តង់ដាទី៩ | | ៨ | | |
| ពិន្ទុស្តង់ដាអប្បរមាគឺ ៦៥% មានន័យថាស្តង់ដានេះត្រូវមានពិន្ទុយ៉ាងតិច៦ ដើម្បីបំពេញបាននូវស្តង់ដាអប្បរមា | | | | |

តារាងទី១៤ បានបង្ហាញថា សាលារៀនទាំង១២ បានបំពេញនូវស្តង់ដាសាលារៀនមធ្យមសិក្សា បើធៀបនឹងស្តង់ដាសាលារៀនមធ្យមសិក្សា ត្រូវមានពិន្ទុអប្បរមាគឺ ៦៥% មានន័យថាស្តង់ដានេះត្រូវមានពិន្ទុយ៉ាងតិច៦។ តារាងទី១៤បានឆ្លុះបញ្ចាំងថា ការប្រើប្រាស់ហិរញ្ញប្បទាននិងការគ្រប់គ្រងហិរញ្ញវត្ថុតាមសាលារៀនមានតម្លាភាព គណនេយ្យភាព និងមានការចូលរួមពីភាគីពាក់ព័ន្ធ ដែលធ្វើឱ្យលោកគ្រូអ្នកគ្រូសហគមន៍ មាតាបិតាសិស្សានុសិស្សមានទំនុបចិត្តក្នុងដំណើរការអភិវឌ្ឍន៍សាលារៀន។

## ៤.២ លទ្ធផលនៃការអនុវត្តស្តង់ដាទាំង៩តាមសាលារៀននីមួយៗ

លទ្ធផលនៃស្រាវជ្រាវ លើការអនុវត្តស្តង់ដាទាំង៩ នៃការគ្រប់គ្រងសាលារៀន ប្រកបដោយប្រសិទ្ធភាពនៅសាលារៀនមធ្យមសិក្សានីមួយៗក្នុងរាជធានីភ្នំពេញ មានបង្ហាញដូចក្នុងតារាងទី១៥ខាងក្រោម៖

**តារាងទី១៥៖លទ្ធផលនៃការស្រាវជ្រាវនាំការអនុវត្តស្តង់ដាទាំង៩ តាមសាលារៀននីមួយៗ**

| សាលា ស្តង់ដា/ | អនុវិទ្យាល័យ | | | | | | វិទ្យាល័យ | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ព្រែកញ្ចៅ | អូរបែកក្អម | ហ ស ចម្រើនជាតិ | ទួល ស្នោរ | ត្រពាំង សាលា | ចតុមុខ | ហស . សំរោង | ជស . សន្ធរម៉ុក | ជស ចំ. រើនរដ្ឋ | កំបូល | ទួល អំពិល | វត្តភ្នំ |
| ស្តង់ដាទី១ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| ស្តង់ដាទី២ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | × | ✓ | ✓ | ✓ | ✓ | ✓ |
| ស្តង់ដាទី៣ | × | × | × | ✓ | × | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| ស្តង់ដាទី៤ | × | × | × | × | × | ✓ | × | ✓ | × | × | × | ✓ |
| ស្តង់ដាទី៥ | ✓ | × | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| ស្តង់ដាទី៦ | × | ✓ | ✓ | ✓ | ✓ | ✓ | ✓ | × | ✓ | ✓ | × | × |
| ស្តង់ដាទី៧ | ✓ | × | ✓ | ✓ | × | ✓ | × | ✓ | ✓ | ✓ | ✓ | ✓ |
| ស្តង់ដាទី៨ | × | × | × | × | × | ✓ | ✓ | ✓ | × | × | × | × |
| ស្តង់ដាទី៩ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |

សម្គាល់៖

- ✓ ជាសញ្ញាដែលសាលារៀន បំពេញបាននូវស្តង់ដាអប្បរមានៃការអនុវត្តស្តង់ដាសាលារៀនមានប្រសិទ្ធភាព
- × ជាសញ្ញាដែលសាលារៀន មិនបានបំពេញនូវស្តង់ដាអប្បរមានៃការអនុវត្តស្តង់ដាសាលារៀនមានប្រសិទ្ធភាព

## ៤.៣ បញ្ហាប្រឈមនៃការអនុវត្តស្តង់ដាទាំង៩គិតជារួម

តាមរយៈលទ្ធផលនៃការស្រាវជ្រាវនេះ  បានរកឃើញនូវបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម ដែលសាលាទាំង៩បានជួបប្រទះ៖ (១) សិស្សបោះបង់ និងត្រួតថ្នាក់នៅតែមាន ដោយសារជីវភាពខ្វះខាត សមត្ថភាពនៅមិនទាន់សមស្របនិងកម្រិតថ្នាក់ ការផ្លាស់ប្តូរទីលំនៅ ចំណាកស្រុកទៅធ្វើការងារកម្មកររោងចក្រ កម្មករសំណង់ ឬសិប្បកម្មក្នុងមូលដ្ឋាន (២) មិនទាន់មានបន្ទប់ និងកុំព្យូទ័រគ្រប់គ្រាន់ ខ្វះគ្រូ ICT (៣) ខ្វះគ្រូតាមមុខវិជ្ជានៅសាលាតូច តែលើសគ្រូតាមមុខវិជ្ជានៅសាលាធំ (៣) ខ្វះបន្ទប់ពិសោធន៍

សិស្សមិនសូវបានចូលទៅអនុវត្តផ្ទាល់ គ្រូមួយចំនួនធំមិនចេះប្រើប្រាស់សម្ភារៈពិសោធន៍ (៤) ការបង្រៀន និងរៀនរបស់គ្រូមួយចំនួនមិនទាន់មាន និងប្រើកិច្ចតែងការបង្រៀន និងសម្ភារៈឧបទ្ទេសបង្រៀននៅឡើយ (៥) នាយកសាលាមួយចំនួនមិនទាន់បានអនុវត្តឱ្យប្រសើរឡើងក្នុងការងារអធិការកិច្ចអចិន្ត្រៃយ៍ និងមិនទាន់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការធ្វើផែនអភិវឌ្ឍន៍សាលារៀនផ្អែកតាមស្តង់ដាទាំង៩ (៦) ចំនួនគ្រូបង្រៀនមុខវិជ្ជាគោលបានបំប៉នពីការប្រើប្រាស់សៀវភៅលំហាត់មិនទាន់បានល្អ (៧) មានបណ្ណាល័យដែរ តែមិនទាន់មានស្តង់ដា ដែលធ្វើឱ្យសិស្សមិនចង់ចូលអានសៀវភៅ (៨) ហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានសាលារៀនមិនទាន់ល្អ និងគ្រប់គ្រាន់ (៩) មិនទាន់បានទំនាក់ទំនងជាមួយអាព្យាបាលសិស្សរៀនយឺតជាប់ជាប្រចាំ ដោយសារការខ្វះទំនាក់ទំនងជាមួយមាតាបិតាសិស្ស និងខ្វះការចូលរួមជាប្រចាំរបស់មាតាបិតាសិស្ស (១០) មានការចំណាយលើថាមពលអគ្គិសនីច្រើន ធ្វើឱ្យសាលារៀនត្រូវចំណាយលើថាមពលអគ្គិសនី និង(១១)គ្រូមិនមានដំណើរទេស្សនកិច្ចសិក្សា ដើម្បីទទួលបាននូវបទពិសោធន៍ថ្មីបន្ថែម

# ជំពូកទី ៥
# សេចក្តីសន្និដ្ឋាន និងសំណូមពរ

# ជំពូកទី៥

# សេចក្តីសន្និដ្ឋាន និងសំណូមពរ

## ៥.១ សេចក្តីសន្និដ្ឋាន

ផ្អែកលើលទ្ធផលសិក្សាស្រាវជ្រាវ និងការអង្កេតតាមសាលារៀនទាំង១២នៅរាជធានីភ្នំពេញ លើប្រធានបទ"ប្រសិទ្ធភាពនៃការគ្រប់គ្រងសាលារៀនប្រកបដោយគុណភាពផ្អែកលើលទ្ធផលនៅរាជធានីភ្នំពេញ" មកបានរកឃើញ ចំណុចខាងក្រោម៖

**១. ស្ថានភាពនៃការគ្រប់គ្រងសាលារៀនផ្អែកលទ្ធផល** នៅកម្រិតមធ្យមសិក្សាដែលក្រៅពីសាលា NGS, សាលាធនធាន និងសាលាក្នុងគម្រោងSEIP មិនទាន់បានបំពេញនូវស្តង់ដាសាលាមានប្រសិទ្ធភាពកម្រិតអប្បបរមាទាំង៩នៅឡើយ បើពិនិត្យមើលជារួម នៃសាលាគោលដៅក្នុងការស្រាវជ្រាវនេះ។ ប៉ុន្តែបើពិនិត្យមើលការអនុវត្តស្តង់ដាទាំង៩តាមសាលានីមួយៗវិញឃើញថា៖

**ស្តង់ដាទី១៖** វត្ថុបំណងគោលនយោបាយសាលារៀនៈ មានសាលាចំនួន១២ អនុវត្តបានស្តង់ដាអប្បរមាគឺ៦៥%មានកម្រិតមធ្យម ដោយសារសាលាទាំងនោះបានអនុវត្តលក្ខណៈល្អប្រសើរលើផ្នែកមួយចំនួនដូចជាការប្រមូលសិស្សចូលរៀន អត្រាឡើងថ្នាក់ សិស្សថ្នាក់ទី៩ប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិក្នុងកម្រិតខ្ពស់។ អត្រាត្រួតថ្នាក់ និងបោះបង់ មានកម្រិតទាប ឆ្លុះបញ្ចាំងថាជាសញ្ញាល្អ។ ប៉ុន្តែក៏មានបញ្ហាប្រឈមមួយចំនួនដែលទាក់ទងលើមុខវិជ្ជា ICT ដំណើរការមិនល្អ ដោយសារខ្វះគ្រូ ICT ខ្វះឧបករណ៍និងសម្ភារបរិក្ខារ ហើយកុំព្យូទ័រភាគច្រើនចាស់ៗ និងខូចច្រើន ខ្វះការថែទាំ និងការជួសជុល។ ថវិកាមានកម្រិតក្នុងការថែទាំ ជួសជុល និងចំណាយលើអគ្គីសនី។

**ស្តង់ដាទី២៖** ការរៀននិងបង្រៀនៈ មានសាលាចំនួន ១១ អនុវត្តស្តង់ដាអប្បរមាគឺ៦៥% ចំណែកឯសាលាចំនួន ១ មិនទាន់អនុវត្តបាននៅឡើយ មានន័យថាសាលាទាំងនោះ បានអនុវត្តសម្រាប់ការបង្រៀន និងរៀនមានកម្រិតមធ្យម នៅក្នុងនោះសាលារៀនភាគច្រើន និងលោកគ្រូអ្នកគ្រូមានបំណែងចែកកម្មវិធីសិក្សាតាមមុខវិជ្ជាគ្រប់កម្រិតថ្នាក់ទាំងអស់តាម សប្តាហ៍ ខែ និងឆ្នាំ។ រីឯតេស្តល្បឿនអំណាន និងយល់ខ្លឹមសារ (២០០ពាក្យក្នុងមួយនាទី) តេស្តជាប់លើមុខវិជ្ជាគោលគ្រប់កម្រិតថ្នាក់ ប្រចាំឆមាសទី

១ និងទី២ ទទួលបានកម្រិតមធ្យម។ រីឯកង្វះចំនួនម៉ោងបង្រៀនជាមធ្យមគ្រប់កម្រិតថ្នាក់ និងភាគរយសិស្សអវត្តមានមានការថយចុះគួរឱ្យកត់សម្គាល់ ជាចំណុចល្អដែលធ្វើឱ្យសាលារៀន និងសិស្សានុសិស្សពុំមានការខ្វះម៉ោងសិក្សាដូចមុនឡើយ។ ប៉ុន្តែសាលាទាំងនោះក៏មានលោកគ្រូអ្នកគ្រូមួយចំនួនដែរ មិនទាន់បានប្រើប្រាស់កិច្ចតែងការបង្រៀន និងសម្ភារឧបទេសក្នុងម៉ោងបង្រៀនរបស់ខ្លួន ការប្រជុំរវាងគ្រូ និងគ្រូតាមក្រុមបច្ចេកទេស មាតាបិតាសិស្សរៀនយឺតនិងខ្សោយ មិនទាន់ដំណើរការល្អនៅឡើយទេ។ តែចំពោះមុខវិជ្ជាមួយចំនួនមិនសូវមានសកម្មភាពច្រើនឡើយ ដូចជាមុខវិជ្ជាអប់រំកាយ កីឡា សិល្បៈនិងបំណិនជីវិត។

**ស្តង់ដាទី៣៖** មាតាបិតា និងសហគមន៍ជួយដល់ការសិក្សារៀនសូត្រៈ មានសាលាចំនួន ៨ អនុវត្តស្តង់ដាអប្បរមាគឺ៦៥% ចំណែកឯសាលាចំនួន ៤ មិនទាន់អនុវត្តបាននៅឡើយ ដោយសារការទំនាក់ទំនងជាមួយមាតាបិតាសិស្ស និងសហគមន៍មិនបានល្អ និងខ្វះការចូលរួមគាំទ្រពីសំណាក់មាតាបិតាក្នុងការជួយជំរុញ និងតាមដានការសិក្សារបស់កូនៗ ដែលធ្វើឱ្យការសិក្សារបស់សិស្សមិនសូវបានល្អ រវល់ជាប់ប្រកបកិច្ចការចិញ្ចឹមគ្រួសារ បានប្រគល់ភារកិច្ចជូនលោកគ្រូ អ្នកគ្រូទាំងស្រុង។ ចំណែកឯសាលាប្រាំបីទៀតធ្វើបានល្អ ក្នុងការទំនាក់ទំនង មាតាបិតា និងសហគមន៍ ដោយសារគណៈកម្មការគ្រប់គ្រងសាលារៀនធ្វើការតាមដានការសិក្សានិងជំរុញឱ្យការសិក្សាទាំងនៅក្នុងសាលារៀន និងតាមផ្ទះធ្វើឱ្យសាលារៀនមានការរីកចម្រើន ជាពិសេសលទ្ធផលនៃការសិក្សារបស់សិស្សទទួលបានលទ្ធផលល្អ។

**ស្តង់ដាទី៤៖** សិស្សនិងសេវាសិស្សជួយសិស្សៈ មានសាលាចំនួន ៣ អនុវត្តស្តង់ដាអប្បរមាគឺ ៦៥% ចំណែកឯសាលាចំនួន ៩ មិនទាន់អនុវត្តបាននៅឡើយ។ បើធៀបទៅនឹងស្តង់ដាសាលារៀនមានប្រសិទ្ធភាព គឺសាលាភាគច្រើនអនុវត្តស្ថិតនៅក្នុងកម្រិតទាប។ ដោយសារសេវាការប្រើប្រាស់បណ្ណាល័យ បន្ទប់ពិសោធន៍ ការប្រើប្រាស់កុំព្យូទ័រ របស់សិស្សមានកម្រិតទាប សាលារៀន មានការខ្វះខាតសម្ភារបណ្ណាល័យ បណ្ណាល័យមិនទាន់មានស្តង់ដាគ្រប់គ្រាន់តាមនិយាម សាលាមិនមានបណ្ណារក្សសម្រាប់ការងារបណ្ណាល័យឱ្យធ្វើការពេញលេញ សាលាខ្លះពុំមានម៉ោងប្រើប្រាស់បណ្ណាល័យ រីឯបន្ទប់ពិសោធន៍សម្ភារៈ និងឧបករណ៍មិនសម្បូរបែប និងមិនសូវបានយកមកពិសោធន៍ឱ្យសិស្ស លើមុខវិជ្ជាវិទ្យាសាស្ត្រ គ្រូ

មួយចំនួនមិនទាន់ចេះប្រើប្រាស់ និងមានចំណេះដឹងដើម្បីបង្ហាញសិស្ស។ រីឯសេវាការប្រើប្រាស់កុំព្យូទ័រសម្រាប់សិស្សានុសិស្សវិញ នៅមានកម្រិតទាប សាលាភាគច្រើនខ្វះកុំព្យូទ័រ កុំព្យូទ័រចាស់ ខូច និងខ្វះអ្នកបច្ចេកទេសផ្នែកបច្ចេកវិទ្យា។

**ស្តង់ដាទី៥៖** ការដឹកនាំនិងគ្រប់គ្រងសាលារៀនៈ មានសាលាចំនួន ១១ អនុវត្តស្តង់ដាអប្បរមាគឺ៦៥% ចំណែកឯសាលាចំនួន ១ មិនទាន់អនុវត្តបាននៅឡើយ។ សាលារៀនបានរៀបចំអនុវត្តការងារបានល្អ ដូចជាការងាររដ្ឋបាល ការប្រជុំ ការបំពេញការងាររបស់បុគ្គលិកអប់រំ ការគ្រប់គ្រងនិងការកាត់បន្ថយបាតុភូតអវិជ្ជមាននានាបានល្អ។ តែក៏មានចំណុចខ្វះខាតមួយចំនួនផងដែរទៅលើការធ្វើអធិការកិច្ចអចិន្ត្រៃយ៍មិនទាន់បានល្អ និងការធ្វើការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀនដោយផ្អែកលើស្តង់ដាទាំង៩នៃសាលាមធ្យមសិក្សាមិនទាន់បានល្អ និងមិនមានចំណេះដឹងគ្រប់គ្រាន់ក្នុងការធ្វើផែនការអភិវឌ្ឍន៍សាលារៀន។

**ស្តង់ដាទី៦៖** ធនធានមនុស្សៈ មានសាលាចំនួន៨ អនុវត្តស្តង់ដាអប្បរមាគឺ៦៥% ចំណែកឯសាលាចំនួន៤ មិនទាន់អនុវត្តបាននៅឡើយ។ មានការខ្វះខាតគ្រូ នៅសាលាតូច តែបើជាលើសនៅសាលារៀនធំៗក្នុងកណ្តាលក្រុងទៅវិញ។ គ្រូបង្រៀនខ្លះកម្រិតបឋម មកបង្រៀននៅកម្រិតបឋមភូមិ។

**ស្តង់ដាទី៧៖** សៀវភៅសិក្សាគោល សម្ភាររៀននិងបង្រៀនៈ មានសាលាចំនួន៩ អនុវត្តស្តង់ដាអប្បរមាគឺ៦៥% ចំណែកឯសាលាចំនួន ៣ មិនទាន់អនុវត្តបាននៅឡើយ។ សៀវភៅសិក្សាគោល មានគ្រប់គ្រាន់សម្រាប់ចែកឱ្យសិស្សម្នាក់១ក្បាល តែខ្វះបណ្ណាល័យស្តង់ដា និងសម្ភាររៀននិងបង្រៀនខ្លះៗ។

**ស្តង់ដាទី៨៖** ហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានសាលារៀនៈ មានសាលាចំនួន ៣ អនុវត្តស្តង់ដាអប្បរមាគឺ៦៥% ចំណែកឯសាលាចំនួន ៩ មិនទាន់អនុវត្តបាននៅឡើយ ពោលគឺអនុវត្តមិនទាន់បានល្អ បរិស្ថានមិនទាន់ស្អាត ខ្វះបន្ទប់សម្រាប់គ្រូស្នាក់នៅ បន្ទប់រដ្ឋបាលមិនទាន់មានគ្រឿងសង្ហារឹមគ្រប់គ្រាន់នៅឡើយ បន្ទប់ទឹកមិនទាន់មានលក្ខណៈស្តង់ដាគ្រប់គ្រាន់តាមចំនួននិងតម្រូវការរបស់សិស្ស។

**ស្តង់ដាទី៩៖** ហិរញ្ញប្បទាន និងការគ្រប់គ្រងហិរញ្ញវត្ថុ: មានសាលាចំនួន ១២ អនុវត្តស្តង់ដាអប្បរមាគឺ៦៥% ចំណែកឯសាលាចំនួន ០ មិនទាន់អនុវត្តបាននៅឡើយ។ ការអនុវត្តស្តង់ដាទី៩ គឺបានល្អ មានតម្លាភាព គណនេយ្យភាព និងមានការចូលរួមបានល្អ។

**២.បញ្ហាប្រឈម**

តាមរយៈការសិក្សាស្រាវជ្រាវនេះ អ្នកសិក្សាស្រាវជ្រាវក៏បានរកឃើញនូវបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

- ខ្វះគ្រូមុខវិជ្ជាតាមសាលាតូចៗប៉ុន្តែលើសគ្រូតាមមុខវិជ្ជានៅសាលាធំៗហើយគ្រូមួយចំនួនធំមិនចេះប្រើប្រាស់សម្ភារពិសោធន៍
- ខ្វះបន្ទប់ពិសោធន៍ បន្ទប់កំព្យូទ័រ និងបណ្ណាល័យ ដែលធ្វើឱ្យសិស្សមិនបានចូលអនុវត្តផ្ទាល់ និងធ្វើការសិក្សាស្រាវជ្រាវបន្ថែម
- មិនទាន់ប្រើកិច្ចតែងការបង្រៀន និងសម្ភារឧបទេសបង្រៀនសម្រាប់ការបង្រៀន និងរៀនរបស់គ្រូមួយចំនួន
- មិនទាន់បានទំនាក់ទំនងជាមួយអាណាព្យាបាលសិស្សរៀនយឺតជាប់ជាប្រចាំដោយសារការខ្វះមធ្យោបាយទំនាក់ទំនង សហគមន៍មិនទាន់មានការចូលរួមក្នុងការជួយដល់ការសិក្សារបស់សិស្សនិងការចូលរួមក្នុងសាលារៀនឱ្យខ្លាំងក្លានៅឡើយទេ។
- មិនទាន់មានបណ្ណាល័យស្តង់ដាសម្រាប់សិស្សនិងសេវាជួយសិស្ស
- ការចូលបណ្ណាល័យ និងបន្ទប់ពិសោធន៍នៅមានតិចដោយសារសាលាខ្វះសម្ភារ និងសៀវភៅសិក្សា
- មានចំណាយលើថាមពលអគ្គិសនីច្រើន
- គ្រូមិនមានដំណើរទស្សនកិច្ចសិក្សា ដើម្បីទទួលបាននូវបទពិសោធន៍ថ្មីបន្ថែម

## ៥.២ សំណូមពរ

តាមរយៈការសិក្សាស្រាវជ្រាវនេះ អ្នកស្រាវជ្រាវយល់ថា ការគ្រប់គ្រងសាលារៀនប្រកបដោយប្រសិទ្ធភាពពិតជាមានសារៈសំខាន់ណាស់សម្រាប់អភិវឌ្ឍន៍វិស័យអប់រំឱ្យមានគុណភាព កាន់តែប្រសើរឡើងថែមទៀត ព្រមជាមួយគ្នានេះដែរ អ្នកស្រាវជ្រាវបានរកឃើញនូវបញ្ហាប្រឈមសំខាន់ៗ មួយចំនួនដែលរាំងស្ទះដល់ប្រសិទ្ធភាពនៃការគ្រប់គ្រងសាលារៀនទាំង១២នេះ។ ដើម្បីឆ្លើយតបនឹងបញ្ហា និងតម្រូវការទាំងនោះ អ្នកស្រាវជ្រាវសូមលើកនូវគំនិតយោបល់មួយចំនួន សម្រាប់ភាគីពាក់ព័ន្ធ ចូលរួមចំណែកធ្វើឱ្យការគ្រប់គ្រងសាលារៀនមានប្រសិទ្ធភាពកាន់តែខ្ពស់ សំដៅជំរុញដល់លទ្ធផលសិក្សា របស់សិស្សានុសិស្សឱ្យកាន់តែប្រសើរឡើង។

- **ក្រសួងអប់រំ យុវជន និងកីឡា**

គួរបើកវគ្គបំប៉នដល់នាយកសាលាពីវិធីសាស្ត្រក្នុងការធ្វើឱ្យសម្រេចបាននូវសូចនាករទាំងអស់ ដែលមានចែងក្នុងស្តង់ដាទាំង៩។ ចុះទៅជួយផ្ទាល់ដល់សាលារៀនឱ្យបានច្រើនក្នុងការអនុវត្តការគ្រប់គ្រងសាលាប្រកបដោយគុណភាព ផ្តល់អគារបណ្ណាល័យស្តង់ដា និងជ្រើសរើសគ្រូឯកទេសគ្រប់គ្រងបណ្ណាល័យ សម្រាប់ផ្តល់ដល់សាលាដែលមានបណ្ណាល័យស្តង់ដា ព្រមទាំងជួយផ្តល់គ្រូជំនាញ IT យ៉ាងតិចមួយនាក់ ក្នុងមួយសាលារៀន និងធ្វើអណត្តិ វេនផ្លាស់ប្តូរគ្រូបង្រៀនឱ្យបានទៀងទាត់ និងបំពេញតម្រូវការខ្វះគ្រូ ឯកទេសតាមសាលារៀន។

- **មន្ទីរអប់រំ យុវជន និងកីឡា**

ជួយសាលារៀបចំកម្មវិធីផ្សព្វផ្សាយ កម្មវិធីគ្រប់គ្រងតាមសាលារៀន ឱ្យបានទូលំទូលាយ ដល់សហគមន៍ និងអាណាព្យាបាលសិស្ស និងសហការជួយជំរុញអាជ្ញាធរដែនដី ឱ្យចូលរួមគ្រប់ពេលសាលាមានតម្រូវការ។

- **ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌនៃរដ្ឋបាលខណ្ឌ**

លើកទឹកចិត្តដល់សាលារៀនស្នើគ្នា និងជាពិសេសជួយសាលារៀន ដែលមានបញ្ហាប្រឈមច្រើន សាលាជួបការលំបាក និងជួយស្វែងរកដៃគូអភិវឌ្ឍន៍សាលាដែលមិនបានបំពេញស្តង់ដាសាលារៀនមានប្រសិទ្ធភាព។

❖ **សាលារៀន**

ខិតខំ លើកទឹកចិត្តខ្លួនឯង ទាំងគណៈនាយក បុគ្គលិកអប់រំ ឱ្យបំពេញការងារប្រកបដោយប្រសិទ្ធភាព គុណភាព ឆ្លើយតបទៅនឹងគោលនយោបាយអប់រំ។ គណៈនាយក គ្រូបង្រៀន ត្រូវខិតខំបង្កើនទំនាក់ទំនងល្អជាមួយអាណាព្យាបាល មាតាបិតាសិស្ស និងសហគមន៍ ឱ្យចូលរួមនិងគៀរគរ រកជំនួយក្នុងការអភិវឌ្ឍន៍សាលារៀន និងបង្កើនការសិក្សាសិស្សឱ្យខ្លាំងដើម្បីប្រកួតប្រជែងក្នុងតំបន់។

❖ **សម្រាប់ការស្រាវជ្រាវបន្ត៖**

គួរពង្រីកវិសាលភាពនៃការសិក្សាទៅលើការអនុវត្តស្តង់ដាទាំង៩ឱ្យបានទូទាំងប្រទេស គួរសិក្សាផងដែរពីការអនុវត្តស្តង់ដាទាំង៩នេះទៅដល់សាលាNGS សាលាធនធាន និងសាលាដែលទទួលបានគម្រោងSEIP។

# ឯកសារយោង

# ឯកសារយោង


ក្រសួងអប់រំ យុវជន និងកីឡា. (២០០៥). គោលនយោបាយនិងផែនការយុទ្ធសាស្រ្តវិស័យអប់រំ.

ក្រសួងអប់រំ យុវជន និងកីឡា. (២០១៧). *ការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល ឯកសារប្រតិបត្តិ ក្រុមប្រឹក្សាយុវជននិងកីឡា.* ភ្នំពេញ: ក្រសួងអប់រំយុវជននិងកីឡា.

ក្រសួងអប់រំ យុវជន និងកីឡា. (២០១៧). *ការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល ឯកសារប្រតិបត្តិ គណៈកម្មការអភិវឌ្ឍថ្នាក់រៀន.* ភ្នំពេញ: ក្រសួងអប់រំយុវជននិងកីឡា.

ក្រសួងអប់រំ យុវជន និងកីឡា. (២០១៧). *ការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល ឯកសារប្រតិបត្តិ គោលនយោបាយនិងនិតិវិធីគ្រប់គ្រងសាលារៀន.* ភ្នំពេញ: ក្រសួងអប់រំយុវជននិងកីឡា.

ក្រសួងអប់រំ យុវជន និងកីឡា. (២០១៨). សៀវភៅប្រតិបត្តិស្តីពីការគ្រប់គ្រងតាមសាលារៀន. គម្រោងកែលម្អអប់រំនៅមធ្យមសិក្សា.

ក្រសួងអប់រំ យុវជន និងកីឡា ស្តង់ដាសាលាមធ្យមសិក្សា. (២០១៨). *ស្តង់ដាសាលាមធ្យមសិក្សាចំណេះទូទៅ.* ភ្នំពេញ.

នាយកដ្ឋានជានាគុណភាពអប់រំ. (២០១៩). *របាយការណ៍អធិការកិច្ចតាមប្រធានបទ ការគ្រប់គ្រងនិងប្រើសៀវភៅសិក្សាគោល.* ភ្នំពេញ: នាយកដ្ឋានជានាគុណភាពអប់រំ.

ប្រាក់ពៅ ឃិនវណ្ណី បានកក្កដា. (២០១៩). *វិធីសាស្រ្តបង្រៀន.* ភ្នំពេញ: គ្រឹះស្ថានបោះពុម្ពឯកសារខ្មែរ.

យុទសាស្រ្តកំណែទម្រង់វិស័យអប់រំ. (២០១៨-២០២៣). ក្រសួងអប់រំ យុវជន និងកីឡា.

ADB. (2002). Technical Assistance to the Kingdom of Cambodia for performance management in the education sector. *Phnom Penh: Cambodia,Asian Development Bank*, 2.

Agih, A. A. ( July, 2015). Effective School Management and Supervision: Imperative for. *An International Multidisciplinary Journal, Ethiopia*, 62-74.

Bank, A. D. (2002).

Caldwell, B. (2009). *Centralization and decentralization in education: A New Dimension to policy.In.*

Cheng, Y. C. (1996). *School Effectiveness And School-Based Management: A Mechanism For Development.* British: Routledge, Jan 11, 2013 - Education - 210 pages.

Daniel J. Brown. (1990). *Decentralization and School-based Management.* London: Great Britain by Taylor&Francis.

David_Gamage. (2009). Decentralisation and School-Based Governance: A Comparative Study of Self-Governing School Models. In D. T. Gamage, *Decentralisation, School-Based Management, and Quality* (pp. pp.3-22)). Newcastle.

Duhou, I. (1999). *School-based management: Fundamentals of educational planing* . Paris: UNESCO: International Institute of Education Planning.
Dykstra,A.H,& Kucita.P. (1997). SBM througt cluster school: acase study from Cambodia. Retrieved May8,2006. *UNICEF*.
Dyskra,A.H,& Kucita,P. (1997, May). SMB through cluster school: A Case study from Cambodia. *Education resource in Cambodia*.
Gamage, D. Z. (2009). Decentralization and school-based management governane. *A Comparative study of self-governing school models. In Zajda, J.& Gamage,D.T. (Eds) Globalization , Comparative Education and Policy and Policy Research:,* pp. Decentralization, School-Based Management and Quality (pp2-33).
Lindquist and Maurie. (1989). Political Crossroads, Volumes 10-14. In J. Nicholas, *Political science* (pp. 47-48). James Nicholas Publishers,.
Margery Martin. (1993). *School-based management.* Menusota.
Ministry of Education, Y. a. (2000). *Education strategic plan 2001-2005.* Phnom Penh.
MoEYS. (2001). *Priority action program for improving the quality and effective of basic education 2001.* Phnom Penh : Ministry of Education, Youth and Sport.
MONO, H. (2029). *Effect of Implementation School Based Management in Secondary School.* Phnom Penh: National Institute of Education.
Shoraku. (2008). Education movement toward school-based Management in East Asia: Cambodia, Indonesia. and Thailand.Paper commissioned for the EFA Global Monitoring. *Overcoming Inequality:why govenment matter*.
Spillance,J.P.,Halverson,R.,&Diamond,J.B. (2004). Towards a theory of leadership practice: A distributed . *Joural of curriculum studies,* 36(1),3-34.
Tandon,Prateek. Fukao Tsuyoshi. (2015). *Educating the Next Generation: Improving Teacher Quality in Cambodia.* Washington: World Bank.

# ឧបសម្ព័ន្ធ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**វិទ្យាស្ថានជាតិអប់រំ**

## កម្រងសំណួរសម្រាប់សម្ភាសគណៈនាយក

ខ្ញុំបាទឈ្មោះ ញ៉ែម ពៅ ជានិសិត្សថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ នៃវិទ្យាស្ថានជាតិអប់រំ បាននឹងកំពុងធ្វើការសិក្សាស្រាវជ្រាវ ដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សាក្រោមប្រធានបទ៖ "**ប្រសិទ្ធភាពនៃការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល នៅសាលាមធ្យមសិក្សាក្នុងរាជធានីភ្នំពេញ**"។

ខ្ញុំបាទ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ លោកនាយក/នាយិកា ទាំងអស់ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការបំពេញនិងឆ្លើយកម្រងសំណួរ របស់ខ្ញុំបាទ។ ខ្ញុំបាទសូមធានាថា កម្រងសំណួរនេះនឹងត្រូវបានរក្សាការសម្ងាត់ ហើយព័ត៌មានដែលទទួលបាន សម្រាប់យកមកប្រើសម្រាប់ការស្រាវជ្រាវនេះតែប៉ុណ្ណោះ។ សូមលោក លោកស្រី លោកនាយក នាយិកា លោកគ្រូ/អ្នកគ្រូ មេត្តាជួយគូស សញ្ញា ✓ ឬឆ្លើយសំណួរខាងក្រោម៖

### ក. កម្រងសំណួរទម្រង់បិទ

**ផ្នែកទី១៖ ព័ត៌មានស្ថានភាពទូទៅរបស់លោកនាយក/នាយិកា**

១.ឈ្មោះសាលារៀន........................................................ខណ្ឌ.........................

២.ភេទ □ ប្រុស □ ស្រី

៣. កម្រិតវប្បធម៌ (ចំលើយតែមួយ)

1.□ ទុតិយភូមិ 2.□ បរិញ្ញាបត្រ

3.□ បរិញ្ញាបត្រជាន់ខ្ពស់ 4.□ បណ្ឌិត

5.□ ផ្សេងៗ (សូមបញ្ជាក់៖..................................)

៤. កម្រិតវិជ្ជាជីវៈ(ចំលើយតែមួយ)

1.□ មត្តេយ្យសិក្សា 2.□ បឋមសិក្សា

3.□ កម្រិតមូលដ្ឋាន 4.□ កម្រិតឧត្តម

៥.បទពិសោធការងារ

1.□ តិចជាង៥ឆ្នាំ 2.□ ពី៥-១០ឆ្នាំ

3.□ ពី១០-១៥ឆ្នាំ 4.□ លើស១៥ឆ្នាំ

**ផ្នែកទី២៖ ប្រសិទ្ធភាពនៃការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល**

សំគាល់៖ ១=ទាប ២=មធ្យម ៣=ខ្ពស់

| ល.រ | សូចនាករ | | កម្រិត | | |
|---|---|---|---|---|---|
| | | | ១= ទាប | ២= មធ្យម | ៣=ខ្ពស់ |
| | **ស្តង់ដា១៖ វត្ថុបំណងសាលារៀន** | | | | |
| ១.១ | ចូលរៀន ត្រួតថ្នាក់ បោះបង់ និងឡើងថ្នាក់ (ចំនួនសិស្ស) | ចូលរៀន | | | |
| | | ត្រួតថ្នាក់ | | | |
| | | បោះបង់ | | | |
| | | ឡើងថ្នាក់ | | | |
| ១.២ | ភាគរយសិស្សសម្រេចផលសិក្សាចុងឆ្នាំសិក្សា ជាពិន្ទុ ច្រើនជាង៦០%នៃពិន្ទុសរុបលើមុខវិជ្ជាគោលនីមួយៗ | ភាសាខ្មែរ | | | |
| | | គណិតវិទ្យា | | | |
| | | ភាសាបរទេស | | | |
| ១.៣ | ភាគរយសិស្សសម្រេចផលសិក្សាចុងឆ្នាំសិក្សា ជាពិន្ទុ ច្រើនជាង៦០%នៃពិន្ទុសរុបលើមុខវិជ្ជាគោលនីមួយៗ (មុខវិជ្ជាវិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម ប្រវត្តិវិទ្យា) | រូបវិទ្យា | | | |
| | | គីមីវិទ្យា | | | |
| | | ផែនដីវិទ្យា | | | |
| | | ប្រវត្តិវិទ្យា | | | |
| | | ICT | | | |
| ១.៤ | ភាគរយសិស្សថ្នាក់ទី៩ សម្រេចបានល្បឿនអានភាសាខ្មែរ ក្នុង១នាទី យល់ភាសា | | | | |
| ១.៥ | ភាគរយសិស្សថ្នាក់ទី៩ ប្រឡងជាប់សញ្ញាបត្របឋមភូមិ | | | | |
| សរុបស្តង់ដាទី១ | | | | | |
| | | | | | |

| ល.រ | សូចនាករ | កម្រិត | | |
|---|---|---|---|---|
| | | ១ | ២ | ៣ |
| **ស្តង់ដា២៖ ការបង្រៀន និងរៀន** | | | | |
| ២.១ | បំណែងចែកកម្មវិធីសិក្សាតាមមុខវិជ្ជានិងតាមកម្រិតថ្នាក់(ឆ្នាំ)? | | | |
| ២.២.១ | ចំនួនកិច្ចតែងការបង្រៀនបានរៀបចំតាមមុខវិជ្ជាគោល (ភាសាខ្មែរ គណិតវិទ្យា វិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម/ប្រវត្តិ) ថ្នាក់ទី៧ ទៅតាមក្រុមគោលដៅ(ឆ្នាំ) | | | |
| ២.២.២ | ចំនួនកិច្ចតែងការបង្រៀនបានរៀបចំតាមមុខវិជ្ជាគោល (ភាសាខ្មែរ គណិតវិទ្យា វិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម/ប្រវត្តិ) ថ្នាក់ទី៨ ទៅតាមក្រុមគោលដៅ(ឆ្នាំ) | | | |

| | | | | |
|---|---|---|---|---|
| ២.២.៣ | ចំនួនកិច្ចតែងការបង្រៀនបានរៀបចំតាមមុខវិជ្ជាគោល (ភាសាខ្មែរ គណិតវិទ្យា វិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម/ប្រវត្តិ) ថ្នាក់ទី៩ ទៅតាមក្រុមគោលដៅ(ឆ្នាំ) | | | |
| ២.៣ | ចំនួនសិស្សថ្នាក់ទី៩ មានពិន្ទុតេស្តជាប់ស្តង់ដាល្បឿនអំណាននិងយល់ខ្លឹមសារ(២០០ពាក្យក្នុងមួយនាទី) (ត្រួតពិនិត្យតាមដាន និងចុងឆមាសទី១ និងចុងឆមាសទី២) | | | |
| ២.៤.១ | ចំនួនសិស្សថ្នាក់ទី៧ មានពិន្ទុតេស្តជាប់លើមុខវិជ្ជាគោលធៀបជាមួយក្រុមគោលដៅគ្រោងទុក(ត្រូវពិនិត្យតាមដាននៅចុងឆមាសទី១ និងទី២) | | | |
| ២.៤.២ | ចំនួនសិស្សថ្នាក់ទី៨ មានពិន្ទុតេស្តជាប់លើមុខវិជ្ជាគោលធៀបជាមួយក្រុមគោលដៅគ្រោងទុក(ត្រូវពិនិត្យតាមដាននៅចុងឆមាសទី១ និងទី២) | | | |
| ២.៤.៣ | ចំនួនសិស្សថ្នាក់ទី៩ មានពិន្ទុតេស្តជាប់លើមុខវិជ្ជាគោលធៀបជាមួយក្រុមគោលដៅគ្រោងទុក(ត្រូវពិនិត្យតាមដាននៅចុងឆមាសទី១ និងទី២) | | | |
| ២.៥ | ភាគរយសិស្សថ្នាក់ទី៩ ប្រឡងជាប់ឆមាស(ត្រូវពិនិត្យតាមដាននៅចុងឆមាសទី១ និងទី២) | | | |
| ២.៦ | ភាគរយសិស្សប្រឡងឡើងថ្នាក់សម្រាប់សិស្សធ្លាក់មធ្យមភាគ (ប្រចាំឆ្នាំឬក្រៅថ្នាក់) | | | |
| ២.៧ | ចំនួនថ្នាក់មានការប្រជុំរវាងគ្រូបង្រៀន មាតាបិតានិងសិស្សរៀនយឺត((សិស្សត្រួតថ្នាក់ឆ្នាំមុន សិស្សដែលមានពិន្ទុទាបជា៦០%ពីចុងឆ្នាំសិក្សាមុន និងនៅបំណាច់ខែទី១)ធៀបជាមួយក្រុមគោលដៅ | | | |
| ២.៨.១ | កង្វះចំនួនម៉ោងបង្រៀនជាមធ្យមនៃថ្នាក់ទី៧ (ត្រូវពិនិត្យតាមដាននៅចុងឆមាសទី១ និងទី២) | | | |
| ២.៨.២ | កង្វះចំនួនម៉ោងបង្រៀនជាមធ្យមនៃថ្នាក់ទី៨ (ត្រូវពិនិត្យតាមដាននៅចុងឆមាសទី១ និងទី២) | | | |
| ២.៨.៣ | កង្វះចំនួនម៉ោងបង្រៀនជាមធ្យមនៃថ្នាក់ទី៩ (ត្រូវពិនិត្យតាមដាននៅចុងឆមាសទី១ និងទី២) | | | |
| ២.៩.១ | ភាគរយសិស្សអវត្តមានតិចជាង៥ដង | | | |
| ២.៩.២ | ភាគរយសិស្សអវត្តមានចាប់ពី៥ទៅ១០ដង | | | |
| ២.៩.៣ | ភាគរយសិស្សអវត្តមានច្រើនជាង១០ដង | | | |

| | | | | |
|---|---|---|---|---|
| ២.១០.១ | ភាគរយសិស្សថ្នាក់ទី៧ បានទទួលលំហាត់ឬកិច្ចការផ្ទះដាក់ឱ្យតាមមុខវិជ្ជាគោល (ភាសាខ្មែរ គណិត វិទ្យាសាស្ត្រ)ធៀបនឹងក្រុមគោដៅគ្រោងទុក | | | |
| ២.១០.២ | ភាគរយសិស្សថ្នាក់ទី៨ បានទទួលលំហាត់ឬកិច្ចការផ្ទះដាក់ឱ្យតាមមុខវិជ្ជាគោល (ភាសាខ្មែរ គណិត វិទ្យាសាស្ត្រ)ធៀបនឹងក្រុមគោដៅគ្រោងទុក | | | |
| ២.១០.៣ | ភាគរយសិស្សថ្នាក់ទី៩ បានទទួលលំហាត់ឬកិច្ចការផ្ទះដាក់ឱ្យតាមមុខវិជ្ជាគោល (ភាសាខ្មែរ គណិត វិទ្យាសាស្ត្រ)ធៀបនឹងក្រុមគោដៅគ្រោងទុក | | | |
| ២.១១.១ | ភាគរយសិស្សថ្នាក់ទី៧ បានទទួលកិច្ចការជាគម្រោងដាក់ឱ្យតាមមុខវិជ្ជាគោល (ភាសាខ្មែរ គណិតវិទ្យា និងវិទ្យាសាស្ត្រ) ធៀបជាមួយក្រុមគោលដៅគ្រោងទុក | | | |
| ២.១១.២ | ភាគរយសិស្សថ្នាក់ទី៨ បានទទួលកិច្ចការជាគម្រោងដាក់ឱ្យតាមមុខវិជ្ជាគោល (ភាសាខ្មែរ គណិតវិទ្យា និងវិទ្យាសាស្ត្រ) ធៀបជាមួយក្រុមគោលដៅគ្រោងទុក | | | |
| ២.១១.៣ | ភាគរយសិស្សថ្នាក់ទី៩ បានទទួលកិច្ចការជាគម្រោងដាក់ឱ្យតាមមុខវិជ្ជាគោល (ភាសាខ្មែរ គណិតវិទ្យា និងវិទ្យាសាស្ត្រ) ធៀបជាមួយក្រុមគោលដៅគ្រោងទុក | | | |
| ២.១២ | ចំនួនគ្រូបង្រៀនក្រោមគោលដៅបានទទួលការបំប៉ននិងជួយការបង្រៀននៅនឹងកន្លែង | | | |
| ២.១៣ | ចំនួនថ្នាក់រៀនបានបំពេញរដ្ឋបាលថ្នាក់រៀនតាមការណែនាំរបស់ក្រសួងធៀបជាមួយក្រុមគោលដៅ | | | |
| ២.១៤ | ភាគរយគ្រូបង្រៀនបើកថ្នាក់ឃើត និងបិទថ្នាក់មុនបានថយចុះធៀបជាមួយក្រុមគោលដៅ | | | |
| ២.១៥ | ចំនួនមុខវិជ្ជាអប់រំកាយកីឡា និងសិល្បៈបានបង្រៀនតាមក្រុមគោលដៅគ្រោង (សរុប១៤មុខវិជ្ជា) | | | |
| **សរុបស្តង់ដាទី២** | | | | |

| ល.រ | សូចនាករ | កម្រិត | | |
|---|---|---|---|---|
| | | ទាប | មធ្យម | ខ្ពស់ |
| **ស្តង់ដាទី៣ មាតាបិតានិងសហគមន៍ជួយដល់ការរៀនសូត្រសិស្ស** | | | | |
| ៣.១ | ភាគរយថ្នាក់រៀនបានប្រជុំប្រឹក្សាយោបល់រវាងគ្រូបង្រៀនមាតាបិតាសិក្សានិងសិស្ស(នៅដើមឆ្នាំសិក្សានិងតាមត្រី | | | |

| | | | | |
|---|---|---|---|---|
| | មាស) | | | |
| ៣.២ | ចំនួនប្រជុំគណៈកម្មការគ្រប់គ្រងសាលារៀនតាមការណែនាំ (ពេលបើកបវេសនកាល ចុងឆមាសទី២ និងទី២) | | | |
| ៣.៣ | ភាគរយសិស្សមករៀនយឺត | | | |
| ៣.៤ | ភាគរយសិស្សបានធ្វើកិច្ចការផ្ទះ ឬកិច្ចការគម្រោង | | | |
| **សរុបស្តង់ដាទី៣** | | | | |

| ល.រ | សូចនាករ | កម្រិត | | |
|---|---|---|---|---|
| | | ១ | ២ | ៣ |
| **ស្តង់ដាទី៤ សិស្ស និងសេវាសិស្សជួយសិស្ស** | | | | |
| ៤.១ | ភាគរយសិស្សប្រើបណ្ណាល័យ (ពិនិត្យតាមដានរាល់ត្រីមាស) | | | |
| ៤.២ | ភាគរយសិស្សប្រើបន្ទប់ពិសោធន៍ | | | |
| ៤.៣ | ភាគរយសិស្សប្រើកុំព្យូទ័រ | | | |
| ៤.៤ | ភាគរយថ្នាក់មានដំណើរការ (តាមការណែនាំរបស់ក្រសួង) ក្លឹបសិស្សានុសិស្ស | | | |
| ៤.៥ | ភាគរយសិស្សខ្សោយ គំហើញនិងខ្សោយស្តាប់ បានទទួលការគាំទ្រដើម្បីរៀនបានប្រសើរ | | | |
| ៤.៦ | ភាគរយសិស្សអាហារូបករណ៍បោះបង់ការសិក្សា | | | |
| សរុបស្តង់ដាទី៤ | | | | |

| ល.រ | សូចនាករ | កម្រិត | | |
|---|---|---|---|---|
| | | ១ | ២ | ៣ |
| **ស្តង់ដាទី៥៖ការដឹកនាំនិងគ្រប់គ្រងសាលារៀន** | | | | |
| ៥.១ | ចំនួនសូចនាករ រដ្ឋបាលសាលារៀនបានបំពេញតាមការណែនាំរបស់ក្រសួង (សរុបសូចនាករ១០) | | | |
| ៥.២ | ការអនុវត្តផែនការអធិការកិច្ចរបស់នាយកឬនាយករង | | | |
| ៥.៣ | ចំនួនការប្រជុំបច្ចេកទេសប្រចាំខែតាមការណែនាំរបស់ក្រសួង (សរុប៧ដងក្នុង១ឆ្នាំ) | | | |
| ៥.៤ | ចំនួនដងបំប៉ន និងដឹកដៃធ្វើការងារនៅនឹងកន្លែងដល់នាយក និងគណៈកម្មការគ្រប់គ្រងសាលារៀនដោយមន្ត្រីក្រសួងដើម្បីកែលម្អសូចនាការគ្រប់គ្រងសាលារៀន | | | |
| ៥.៦ | ចំនួនគ្រូបង្រៀន បានបំពេញការងារប្រសើរជាងមុន តាមរយៈការ | | | |

| | | | | |
|---|---|---|---|---|
| | វាយតម្លៃការអនុវត្តការងារប្រចាំឆ្នាំ | | | |
| ៥.៧ | ការបន្ថយភាពមិនប្រក្រតីនៅសាលារៀន (សរុប៩ភាពមិនប្រក្រតី) | | | |
| ៥.៨ | ចំនួនដងពិនិត្យតាមដាននិងគាំទ្រពីថ្នាក់ស្រុកមន្ទីរនិងក្រសួង | | | |
| សរុបស្តង់ដាទី៥ | | | | |
| | | | | |
| ល.រ | សូចនាករ | កម្រិត | | |
| | | ១ | ២ | ៣ |
| **ស្តង់ដាទី៦.ធនធានមនុស្ស** | | | | |
| ៦.១ | គុណវុឌ្ឍិគ្រូបង្រៀនធៀបជាមួយផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន | | | |
| ៦.២ | ចំនួនគ្រូខ្វះ មុខវិជ្ជាភាសាខ្មែរ គណិតវិទ្យា វិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម (ប្រវត្តិវិទ្យា) ចុះថយធៀបជាមួយបទដ្ឋាន | | | |
| ៦.៣ | គុណវុឌ្ឍិនាយក ឬនាយិកាសាលាធៀបជាមួយផែនការក្រសួង | | | |
| **សរុបស្តង់ដាទី៦** | | | | |
| | | | | |
| **ស្តង់ដាទី៧.សៀវភៅសិក្សាគោល និងសម្ភារៈរៀន និងបង្រៀន** | | | | |
| ៧.១ | ភាគរយសិស្សមានសៀវភៅគោលតាមមុខវិជ្ជានិងតាមកម្រិតថ្នាក់តាមបទដ្ឋាន | | | |
| ៧.២ | ចំនួនគ្រូបង្រៀនមុខវិជ្ជាគោលបានបំប៉នពីការប្រើប្រាស់សៀវភៅលំហាត់ | | | |
| ៧.៣ | បណ្ណាល័យបានបង្កើតនិងមានស្តង់ដា | | | |
| **សរុបស្តង់ដាទី៧** | | | | |
| | | | | |
| **ស្តង់ដាទី៨.ហេដ្ឋារចនាសម្ព័ន្ធនិងបរិស្ថានសាលារៀន** | | | | |
| ៨.១ | កង្វះបន្ទប់រៀនថយចុះរហូតមានចំនួនសិស្សក្នុងបន្ទប់រៀនតាមបទដ្ឋាន | | | |
| ៨.២ | បន្ទប់ស្នាក់នៅរបស់គ្រូបង្រៀនបានសាសង់តាមតម្រូវការ | | | |
| ៨.៣ | បន្ទប់រដ្ឋបាលសាលារៀននិងសង្ហារឹមបានផ្តល់តាមតម្រូវការ | | | |
| ៨.៤ | បន្ទប់ទឹកបានសាសង់តាមស្តង់ដា និងគ្រប់គ្រាន់តាមបទដ្ឋានសម្រាប់សិស្ស ទាំងប្រុស ទាំងស្រី | | | |
| **សរុបស្តង់ដាទី៨** | | | | |

| | | | | |
|---|---|---|---|---|
| | | | | |
| **ស្តង់ដាទី៩.ហិរញ្ញប្បទាន និងការគ្រប់គ្រងហិរញ្ញវត្ថុ** | | | | |
| ៩.១ | ថវិកាសាលារៀន ពីប្រភពផ្សេងៗបានទទួល ដាក់ស្តែងតាមត្រីមាសមានភាពប្រសើរឡើង | | | |
| ៩.២ | ការចាត់ចែង ការប្រើប្រាស់និងតម្លាភាពថវិកា សាលារៀនបានប្រសើរ (សរុប៥សូចនាករ) | | | |
| ៩.១ | ការរាយការណ៍ការចំណាយតាមខ្ទង់ចំណាយ ធំៗ (រដ្ឋបាល ការបង្រៀន និងរៀននិងបរិស្ថាន | | | |
| សរុបស្តង់ដាទី៩ | | | | |

**ខ កម្រងសំណួរសម្រាប់សម្ភាស**

១.តើសាលារៀនរបស់លោកនាយក/នាយិកា បានបង្កើតគណៈកម្មការគ្រប់គ្រងសាលារៀនដែរឬទេ? តើគណៈកម្មការធ្លាប់បានចូលរួមធ្វើផែនការអភិវឌ្ឍសាលារៀនដែរឬទេ? បើមិនធ្លាប់ តើមានមូលហេតុអ្វី?បើធ្លាប់ តើផែនការនោះផ្អែកទៅលើអ្វីខ្លះ?

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

